សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ប្រទេសកម្ពុជាក្នុងពេលបច្ចុប្បន្ន

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **លឹម រ័ត្ន**

**ប៉ូ មករា**

សាស្ត្រាចារ្យណែនាំ

**ហៀង សាង**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** ឆ្នាំចូលរៀន ២០១៨

ជំនាន់ទី ១៥ ឆ្នាំសរសេរសារណា ២០២២

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
# ប្រទេសកម្ពុជាក្នុងពេលបច្ចុប្បន្ន

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **លឹម រ័ត្ន**

**ប៉ូ មករា**

សាស្ត្រាចារ្យណែនាំ

**ហៀង សាង**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៥

ឆ្នាំចូលរៀន ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **លឹម រ័ត្ន** និង **ប៉ូ មករា** ជានិស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រផ្នែក រដ្ឋបាលសាធារណៈ ឆ្នាំទី ៤ ឆមាសទី ២ ជំនាន់ទី ១៥ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវការគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះលោកឪពុក និងអ្នកម្តាយ ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា អប់រំណែនាំ និងការឧបត្ថម្ភគ្រប់បែបយ៉ាងទាំងធនធាន (ថវិកា និងសម្ភារ)និងស្មារតីដល់ខ្ញុំគ្រប់បែបយ៉ាង រហូតដល់កូនមានឱកាសបានសិក្សារៀនសូត្រដល់ថ្ងៃ បញ្ចប់ថ្នាក់មហាវិទ្យាល័យដោយលោកទាំងពីរខិតខំ ជម្នះរាល់ឧបសគ្គ មិនខ្លាចនឿយហត់ ពុះពារឲ្យកូនបានរៀនសូត្រ មានចំណេះដឹងខ្ពង់ខ្ពស់ ដើម្បីរួមរស់នៅក្នុងសង្គមប្រកបដោយសុភវិនិច្ឆ័យហើយយើងខ្ញុំក៏សូមថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ បណ្ឌិតទាំងអស់ដែលបានខិតខំផ្ទេរចំណេះដឹង និងការស្វាគមន៍ដ៏រាក់ទាក់ កក់ក្តៅបំផុតក្នុងការជួយសម្រួលផ្នែកឯកសារ ទិន្នន័យ ស្មារតី និងសម្ភារផ្សេងៗ ដើម្បីបានផ្តល់លទ្ធភាពដល់យើងខ្ញុំក្នុងការបន្តការសិក្សា និងឈានដល់ការសរសេរសារណាប្រកបដោយជោគជ័យពីសំណាក់៖

**- លោកឪពុក នី ម៉ិក និង អ្នកម្តាយ ញឹម ដួង**

**- លោកឪពុក យង់ ធឿន និង អ្នកម្តាយ ប៉ូ សាត**

ដែលលោកបានផ្តល់កំណើត ចិញ្ចឹមបីបាច់ផ្តល់ដំបូន្មាន និងជួយឧបត្ថម្ភគាំទ្រទាំងកម្លាំងកាយចិត្ត និងជួយសម្របសម្រួលដំណើរការសរសេរសារណាគ្រប់បែបយ៉ាង។

- **ឯកឧត្តម លុយ ចណ្ណា** ជាសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង គណៈគ្រប់គ្រងទាំងអស់ដែលបានខិតខំដឹកនាំសាកលវិទ្យាល័យ និងសម្របសម្រួលរាល់តម្រូវការនៃការសិក្សារបស់និស្សិត។

- លោកសាស្ត្រាចារ្យ **ហៀង សាង** ជាសាស្ត្រាចារ្យណែនាំដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន អប់រំ ណែនាំ ផ្តល់មតិយោបល់ ផ្តល់ឯកសារ និងត្រួតពិនិត្យសារណាស្រាវជ្រាវនេះយ៉ាងយកចិត្តទុកដាក់ និងទឹកចិត្តរីករាយ។

- មិត្តរួមថ្នាក់ និងរួមជំនាន់ទាំងអស់គ្នា ដែលបានជំរុញលើកទឹកចិត្ត ផ្តល់ព័ត៌មាន ពិភាក្សាផ្លាស់ប្តូរយោបល់ ចំណេះដឹង រួមទាំងបទពិសោធន៍ល្អៗ ក្នុងការស្វែងរកដំណោះស្រាយក្នុងការស្រាវជ្រាវហើយខ្ញុំសូមថ្លែងអំណរគុណ ជូនពរលោកអ្នកទាំងអស់គ្នា សូមជួបតែពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ ស្ដីពី **ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ប្រទេសកម្ពុជាក្នុងពេលបច្ចុប្បន្ន** គឺជាស្នាដៃ និងជាសមិទ្ធផលនៃការខិតខំប្រឹងប្រែងក្នុងការសិក្សាស្រាវជ្រាវរបស់ក្រុមយើងខ្ញុំដោយបានស្វែងរកឯកសារពីគ្រប់មជ្ឈដ្ឋាន ដើម្បីគាំទ្រប្រធានបទ។ សារណានេះបានឆ្លុះបញ្ចាំង នូវសមត្ថភាពដែលខ្ញុំមាន និងទទួលបានពីការសិក្សាស្រាវជ្រាវពីឯកសារនានាដែលពាក់ព័ន្ធ ដើម្បីមកធ្វើការបកស្រាយនូវប្រធានបទមួយនេះឲ្យបានល្អ។

ប្រធានបទដែលយើងខ្ញុំទាំងពីរនាក់ឈ្មោះ **លឹម រ័ត្ន** និង **ប៉ូ មករា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាញរដ្ឋបាល សាធារណៈ ជំនាន់ទី ១៥ ក្នុងឆ្នាំសិក្សា២០២១-២០២២ បានសម្រេចចិត្តជ្រើសរើសមកសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ គឺជាប្រធានបទដែលកើតចេញពី ការសង្កេតឃើញជាក់ស្ដែង និងឆន្ទៈចង់សិក្សាស្រាវជ្រាវ ព្រមទាំងមានការជំរុញពីសាស្ត្រាចារ្យ និងមិត្តរួមថ្នាក់ផងដែរ។ ម្យ៉ាងទៀតដោយសង្កេតឃើញថា រាជរដ្ឋាភិបាលកម្ពុជាកំពុងតែយកចិត្តទុកដាក់យ៉ាងខ្លាំង ទៅលើការគ្រប់គ្រងរដ្ឋបាលថ្នាក់ឃុំ សង្កាត់នេះ។ ជាពិសេស ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ សម្រាប់អាណត្តិទី ៥ នៅក្នុងឆ្នាំ ២០២២នេះ។ ច្បាប់ស្ដីពីការគ្រប់គ្រង រដ្ឋបាលឃុំ សង្កាត់ បានផ្ដល់ឱកាសជាច្រើនដល់រាជរដ្ឋាភិបាល ក្នុងកិច្ចបន្តកំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ឃុំ សង្កាត់។ ជាក់ស្ដែង ក្របខណ្ឌយុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ តាមបែបវិមជ្ឈការ និងអភិបាលកិច្ចល្អ សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានបង្កើតក្នុងឆ្នាំ២០០១ ដូចគ្នា ដែលសម្ដៅឲ្យដំណើរការរដ្ឋបាលឃុំ សង្កាត់ កាន់តែល្អប្រសើរ។ ក្រៅពីនេះកម្មវិធីជាតិ និងកម្មវិធីនយោបាយនានារបស់រាជរដ្ឋាភិបាលក៏បានត្រួសត្រាយផ្លូវបន្ថែមបម្រើឲ្យការងារ ការគ្រប់គ្រងនេះបានសម្រេចដោយភាពជោគជ័យ។ ដោយមើលឃើញដូចនេះ ទើបយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយនេះមកសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។ សារណាមួយនេះ ត្រូវបានបញ្ចប់ដោយជោគជ័យតែមិនមែនមានន័យថាមិនមានកំហុសឆ្គងកើតឡើងនោះឡើយ។ ភាពខុសឆ្គងដែលកើតមានឡើងក្នុងសារណានេះគឺដោយសាតែចំណេះដឹងនូវមានកម្រិត ហើយមួយវិញទៀត ការរីករាលដាលនៃជំងឺដ៏កាចសាហាវដែលពិបាកក្នុងការធ្វើចរាចរ ដើម្បីស្វែងរក ទិន្នន័យ ឯកសារ និងព័ត៌មានដែលពាក់ព័ន្ធ ។

អាស្រ័យហេតុនេះ យើងខ្ញុំសូមការខន្តីអភ័យទោសចំពោះកំហុសខុសឆ្គងដែលអាចនឹងកើតមានឡើងដោយប្រការណាមួយពីសំណាក់ លោកគ្រូ សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ហើយយើងខ្ញុំក៏រីករាយនឹងទទួលយកនូវការរិះគន់ដើម្បីជាទុនក្នុងការស្ថាបនា និងការកែលម្អ ដើម្បីឲ្យកាន់តែមានភាពល្អប្រសើរក្នុងការសិក្សាស្រាវជ្រាវនៅលើកក្រោយទៀត ។

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ........ ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ ........ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ ៣

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤


## ជំពូកទី១
## រំលឹកទ្រឹស្តី


**១.១. និយមន័យ** ........ ៥

១.១.១ និយមន័យវិមជ្ឈការ ........ ៥

១.១.២ មុខងារវិមជ្ឈការ ........ ៥

១.១.៣ លក្ខណៈពិសេសនៃវិមជ្ឈការ ........ ៥

១.១.៤ ទម្រង់ផ្សេងៗនៃវិមជ្ឈការ ........ ៦

**១.២. ការរៀបចំរដ្ឋបាលឃុំ សង្កាត់** ........ ៦

១.២.១ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ........ ៦

១.២.២ រចនាសម្ព័ន្ធ និងតួនាទីរបស់រដ្ឋបាលឃុំ សង្កាត់ ........ ៧

១.២.៣ តួនាទី មុខងារ និងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ ........ ៩

**១.៣. កិច្ចការរដ្ឋបាលឃុំ សង្កាត់** ........ ១១

១.៣.១ លិខិតបទដ្ឋានគតិយុត្តឃុំ សង្កាត់ ........ ១១

១.៣.២ លិខិតរដ្ឋបាលឃុំ សង្កាត់ ........ ១២

១.៣.៣ ការគ្រប់គ្រងឯកសារ និងសម្ភារបរិក្ខារបស់ឃុំ សង្កាត់ ........ ១៤

១.៣.៤ ការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ........ ១៥

## ជំពូក២

## ស្ថានភាពទូទៅស្តីពីវិមជ្ឈការ

**២.១ ស្ថានភាពទូទៅ** ........ ២១

**២.២ ចំនួនឃុំ សង្កាត់** ........ ២១

**២.៣ ការវិវឌ្ឍន៍ឃុំ សង្កាត់ថ្មីបន្ថែម** ........ ២២

**២.៤ ទិដ្ឋភាពសំខាន់ៗនៅក្នុងវិមជ្ឈការ** ........ ២៣

**២.៥ ហេតុផលនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ** ........ ២៥

**២.៦ ទិសដៅវិមជ្ឈការ** ........ ២៦

២.៦.១ ការផ្តល់ឱកាសឲ្យប្រជាពលរដ្ឋចូលរួមពេញលេញ ........ ២៦

២.៦.២ ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃការរស់នៅ ........ ២៧

២.៦.៣ ប្រវត្តិនៃការគ្រប់គ្រងវិមជ្ឈការឃុំ សង្កាត់ ........ ២៨

## ជំពូកទី៣

## តួនាទី និងភារកិច្ចរដ្ឋបាលថ្នាក់ឃុំ សង្កាត់

**៣.១. ក្រុមប្រឹក្សាឃុំ សង្កាត់** ........ ៣១

**៣.២ រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់** ........ ៣២

៣.២.១ មេឃុំ ចៅសង្កាត់ ........ ៣២

៣.២.២ ជំទប់ ចៅសង្កាត់រង ........ ៣៤

៣.២.៣ ស្មៀន ........ ៣៥

៣.២.៤ មេភូមិ ........ ៣៧

**៣.៣ តួនាទី ភារកិច្ច** ........ ៣៨

៣.៣.១ ក្នុងឋានៈតំណាងឲ្យរាស្ត្រប្រជា ........ ៣៩

៣.៣.២ ក្នុងឋានៈតំណាងឲ្យរដ្ឋ ........ ៤០

**៣.៤ ការត្រួតពិនិត្យលើរដ្ឋបាលឃុំ សង្កាត់** ........ ៤១

៣.៤.១ ការត្រួតពិនិត្យលើអង្គការឃុំ សង្កាត់ ........ ៤១

៣.៤.២ ការត្រួតពិនិត្យលើសេចក្តីសម្រេច ........ ៤១

## ជំពូកទី៤

## បញ្ហាប្រឈម និងដំណោះស្រាយ

**៤.១ បញ្ហាប្រឈម** ........ ៤៣

៤.១.១ ការចូលរួម និងភាពជាម្ចាស់ ........ ៤៣

៤.១.២ ធនធានហិរញ្ញវត្ថុ ........ ៤៣

៤.១.៣ ធនធានមនុស្ស និងការអភិវឌ្ឍសមត្ថភាព ........ ៤៣

៤.១.៤ ប្រព័ន្ធ និងរចនាសម្ព័ន្ធ ........ ៤៤

**៤.២. ដំណោះស្រាយ** ........ ៤៤

៤.២.១ ការចូលរួម និងភាពជាម្ចាស់........៤៤

៤.២.២ ធនធានហិរញ្ញវត្ថុ........៤៤

៤.២.៣ ធនធានមនុស្ស និងការអភិវឌ្ឍសមត្ថភាព........៤៥

៤.២.៤ ប្រព័ន្ធ និងរចនាសម្ព័ន្ធ........៤៥

**សេចក្តីសន្និដ្ឋាន**........ ៤៦

**អនុសាសន៍**........ ៤៨

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងបណ្តាប្រទេសប្រើប្រាស់ការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យត្រូវបានប្រទេសជាតិមួយចំនួនធំក្នុងពិភពលោកបានទទួលស្គាល់ថាវាជាកត្តាមួយដែលជំរុញឲ្យប្រទេសជាតិមានការរីកចម្រើនប្រកបដោយចីរភាព។ ដោយហេតុថា ការគ្រប់គ្រងប្រភេទនេះបានផ្តល់ឱកាសដល់ប្រជារាស្ត្រគ្រប់រូបចូលរួមកសាងប្រទេសជាតិរួបរួមគ្នា និងការការពារនូវផលប្រយោជន៍រួមដែលស្តែងចេញតាមរយៈ ការបោះឆ្នោតជ្រើសរើសអ្នកតំណាងដើម្បីការពារផលប្រយោជន៍របស់ពួកគេ។ បែបនេះហើយទើបបច្ចុប្បន្នគេអាចសម្គាល់ប្រទេសមួយថាជាប្រទេសដែលប្រកាន់របបប្រជាធិបតេយ្យដោយសារតែ នៅក្នុងប្រទេសមួយនោះមានការបោះឆ្នោតជ្រើសរើសអ្នកកាន់កាប់អំណាចដើម្បីបម្រើផលប្រយោជន៍រួម។ ជាក់ស្តែង វត្តមានលទ្ធិប្រជាធិបតេយ្យមានរយៈពេលជាយូរលង់ណាស់មកហើយ បើយើងគិតចាប់ពីពេលដែល មនុស្សជាតិចាប់ផ្តើមរស់នៅជាមួយគ្នាជាកុលសម្ព័ន្ធដែលក្នុងនោះធ្វើការជ្រើសរើសក្នុងចំណោមញាតិព័ន្ធរបស់ខ្លួន។ ដោយមើលឃើញថាការវិវត្តរបបនយោបាយនៅប្រទេសនីមួយៗមានភាពខុសគ្នាហើយរយៈពេលក៏ខុសៗគ្នាទៅតាមបរិបទក្នុងសង្គមរបស់ប្រទេសទាំងនោះ។ ដោយខ្លះនៅតែរក្សាការគ្រប់គ្រងប្រទេសរបស់ពួកគេតាមបែបសង្គមនិយមខ្លះទៀត ក៏វិវត្តន៍មកជារបបសេរីនិយម ឬតាមបែបលទ្ធិប្រជាធិបតេយ្យ។ ការគ្រប់គ្រងតាមបែបលទ្ធិប្រជាធិបតេយ្យនេះទៀតសោតមានច្រើនរបៀបច្រើនទម្រង់ទៅតាមប្រភេទនៃរដ្ឋនីមួយៗ (រដ្ឋទោល ឬ រដ្ឋសហព័ន្ធ)។

ជាមួយគ្នានេះដែរ ប្រទេសកម្ពុជាយើង បានឆ្លងកាត់របបគ្រប់គ្រងជាច្រើនដោយគ្រាន់តែរាប់បញ្ចូលរបបគ្រប់គ្រងមុនសម័យអាណានិគមបារាំងយើងក៏បានឃើញថា ការគ្រប់គ្រងតាមបែបរាជានិយមផ្តាច់ការរហូតមកដល់មានការបោះឆ្នោត និងគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ។ ដោយយោងទៅតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា[1] ប្រទេសកម្ពុជាប្រកាន់ខ្ជាប់នូវ របបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញហើយប្រជាពលរដ្ឋប្រើប្រាស់អំណាចរបស់ខ្លួនតាមរយៈរដ្ឋសភាព្រឹទ្ធសភារដ្ឋាភិបាល និងតុលាការ។ ដូចនេះហើយអំណាចនៃការគ្រប់គ្រងជាតិគឺមិនប្រមូលផ្តុំតែបុគ្គលតែម្នាក់ ឬស្ថាប័នណាមួយឡើយអំណាចត្រូវបានបែងចែកជាបីគឺ អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។

មិនតែប៉ុណ្ណោះ កម្ពុជាក៏បានកំពុងនឹងព្យាយាមក្នុងការធ្វើកំណែទម្រង់អភិវឌ្ឍន៍រដ្ឋបាលរបស់ខ្លួនយ៉ាងស្វិតស្វាញផងដែរ។ ដំណាក់ការនៃការវិវត្តរដ្ឋបាលកម្ពុជាត្រូវបានបែងចែកចេញជា ៣ ដំណាក់កាលគឺ៖ ដំណាក់កាលនៃការកសាងមូលដ្ឋានគ្រឹះ (១៥ឆ្នាំ ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០៨) ដំណាក់កាលនៃការអភិវឌ្ឍ (១៥ឆ្នាំ ពីឆ្នាំ

[1] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣)

១៩៩៣ ដល់ឆ្នាំ២០០៨) ដំណាក់ការនៃការពង្រឹងប្រសិទ្ធភាព (ពីឆ្នាំ២០០៨ ដល់បច្ចុប្បន្ននេះ)[2]។ កម្ពុជាបានរៀបចំរដ្ឋបាលឲ្យមានភាពប្រសើរឡើងដោយបង្កើតឲ្យមានការបែងចែកអំណាច និងការផ្ទេរអំណាចពីរដ្ឋបាលថ្នាក់ជាតិមករដ្ឋបាលថ្នាក់ក្រោមជាតិតាមបែប (វិមជ្ឈការ និង វិសហមជ្ឈការ)។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទខាងលើនេះស្តីអំពី **ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ប្រទេសកម្ពុជាក្នុងពេលបច្ចុប្បន្ន** បានបង្ហាញឲ្យឃើញនូវបញ្ហាចោទដូចខាងក្រោម៖

- តើដំណើរការនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការប្រព្រឹត្តទៅ និងអនុវត្តយ៉ាងដូចម្តេច?
- តើការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការអាចឲ្យប្រជាពលរដ្ឋនៅក្នុងសហភាពមូលដ្ឋានទទួលបាននូវអត្ថប្រយោជន៍អ្វីខ្លះ?
- តើការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការផ្តល់នូវគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

មូលហេតុដែលក្រុមយើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើនេះ គឺ ក្នុងគោលបំណងរកឲ្យឃើញថា ការបំពេញតួនាទីរបស់មន្ត្រីក្នុងមូលដ្ឋានមានការអនុវត្ត និងផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាននោះ ប្រព្រឹត្តទៅប្រកបដោយ ប្រសិទ្ធភាព តម្លាភាព និងសមធម៌ដែរឬទេ? ហើយការសិក្សាស្រាវជ្រាវនេះដើម្បីធ្វើការវាយតម្លៃអំពី៖

- ការបំពេញតួនាទី ភារកិច្ច និងការគ្រប់គ្រងនៅក្នុងឃុំ សង្កាត់
- កំណត់អំពីសមត្ថភាពរបស់មន្ត្រីទៅលើការអនុវត្តការងារ
- វាយតម្លៃអំពីសមិទ្ធផលដែលសម្រេចបាន

របបគំហើញនៃការស្រាវជ្រាវលើប្រធានបទមួយនេះ គឺដើម្បីធ្វើការកែលម្អ បំពេញបន្ថែមនូវចំណុចដែលមានភាពខ្វះខាតនៅក្នុងមូលដ្ឋាន ឃុំ សង្កាត់ ដោយតែប៉ះពាល់ដល់ការងារដល់ប្រជាពលរដ្ឋ ព្រោះបើ ការគ្រប់គ្រង និងបំពេញតួនាទីរបស់មន្ត្រីនៅក្នុងថ្នាក់មូលដ្ឋានមានភាពខ្វះខាត មិនបានគ្រប់ជ្រុងជ្រោយមិនមានភាពអំណោយផលអាចនឹងជះឥទ្ធិពលដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិទាំងមូល។

[2] សួង លាងហៃ (២០១០).ការវិវត្តនៃរដ្ឋបាលកម្ពុជា(១៩៩៣-២០០៨) [និក្ខេបបទបណ្ឌិតវិទ្យាសាស្ត្រនយោបាយ]មហាវិទ្យាល័យមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះ គឺសំដៅទៅលើការគ្រប់គ្រងឃុំ សង្កាត់ ដោយវិធីណាទើបប្រកបដោយប្រសិទ្ធភាព តម្លាភាព និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋដើម្បីមានការអភិវឌ្ឍទៅតាមឃុំ សង្កាត់របស់ខ្លួន។ ហេតុផលដែលរាជរដ្ឋាភិបាលធ្វើការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការនេះឡើង និងសមិទ្ធផលដែលការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ទទួលបានក្នុងឆ្នាំ២០០២ មកទល់ពេលបច្ចុប្បន្ននេះដោយ ផ្អែកលើច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់ ឆ្នាំ២០០១។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់ដែលទទួលបានពីការសិក្សាស្រាវជ្រាវនេះវាអាចជាចំណេះដឹង និងគោលការណ៍ក្នុងការអភិវឌ្ឍប្រទេសជាតិ។ ហើយវាក៏អាចជាឯកសារសំខាន់សម្រាប់ឲ្យនិស្សិត អ្នកសិក្សាស្រាវជ្រាវ ប្រជាពលរដ្ឋ និងមន្ត្រីរាជការទាំងអស់បានឈ្វេងយល់ និងបំពេញបន្ថែមនូវចំណុចខ្វះខាត និងធ្វើយ៉ាងណាដើម្បីធានានូវការគ្រប់គ្រង និងអនុវត្តប្រកបដោយប្រសិទ្ធភាព និងអភិបាលកិច្ចល្អ នៅក្នុងថ្នាក់ឃុំ សង្កាត់ដែលជាកត្តានាំឲ្យមានការវិវឌ្ឍរបស់សង្គម។

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីធ្វើការប្រមូលព័ត៌មាន និងឯកសារយកមកចងក្រងជាឯកសារណាមួយឲ្យបានល្អ គឺមានការធ្វើសកម្មភាពស្រាវជ្រាវតាមវិធីសាស្ត្រជាច្រើនដូចជា៖

- បណ្ណាល័យ
- ដកស្រង់ចេញពីសៀវភៅដែលពាក់ព័ន្ធនឹង
- ចំណេះដឹងដែលសិក្សាកន្លងមក
- ដកស្រង់ចេញពីប្រសាសន៍របស់សាស្ត្រាចារ្យណែនាំផ្ទាល់
- ទិន្នន័យចម្បង៖ សៀវភៅគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា
- ទិន្នន័យបន្តបន្ទាប់ក្រៅពីមានការប្រមូលបាននូវអនុក្រឹត្យខាងលើយើងខ្ញុំក៏បានស្រាវជ្រាវបន្ថែមទៀតចេញពីសៀវភៅនីតិរដ្ឋបាលទូទៅបណ្ឌិតសាយ ប៊ុរី បោះពុម្ពលើកទី៤ ទំព័រ៣៩៣-៤០១។

ក្រោយពីក្រុមយើងខ្ញុំបានប្រមូលនូវប្រភពទិន្នន័យដ៏សំខាន់ៗខាងលើនេះរួចមកក្រុមយើងខ្ញុំក៏បានប្រើប្រាស់នូវការវិភាគទិន្នន័យបែបពិពណ៌នាដោយផ្អែកលើទិន្នន័យ ដែលមានស្រាប់ខាងលើនេះដើម្បីយកមកសរសេររៀបចំឡើងដើម្បី មានភាពជឿជាក់ និងទទួលយកបាន។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

**ជំពូកទី១៖** ជំពូកនេះបង្ហាញអំពី និយមន័យ និយមន័យវិមជ្ឈការ មុខងារវិមជ្ឈកា លក្ខណៈពិសេសនៃ វិមជ្ឈការ ការរៀបចំរដ្ឋបាលឃុំ សង្កាត់ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ រចនាសម្ព័ន្ធ និងតួនាទីរបស់រដ្ឋបាលឃុំ សង្កាត់ តួនាទី មុខងារ និងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ កិច្ចការរដ្ឋបាលឃុំ សង្កាត់ លិខិតបទដ្ឋានរដ្ឋបាលឃុំ សង្កាត់ លិខិតរដ្ឋបាលឃុំ សង្កាត់ ការគ្រប់គ្រងបុគ្គលិក ឯកសារ និងសម្ភារបរិក្ខារបស់ឃុំ សង្កាត់ ការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

**ជំពូកទី២៖** ជំពូកនេះបង្ហាញអំពី ស្ថានភាពទូទៅ ចំនួនឃុំ សង្កាត់ ការវិវឌ្ឍឈ្មោះឃុំ សង្កាត់ ទិដ្ឋភាពសំខាន់ៗនៅក្នុងវិមជ្ឈការ ហេតុផលនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ តាមបែបវិមជ្ឈការ ទិសដៅវិមជ្ឈការ ប្រវត្តិនៃគ្រប់គ្រងវិមជ្ឈការឃុំ សង្កាត់ ការផ្តល់ឱកាសឲ្យប្រជាពលរដ្ឋចូលរួមពេញលេញ ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃការរស់នៅ។

**ជំពូកទី៣៖** ជំពូកនេះបង្ហាញអំពី ដំណើរការនៃការគ្រប់គ្រងកិច្ចការរដ្ឋបាល ឃុំ សង្កាត់ កិច្ចការរដ្ឋបាលឃុំសង្កាត់ និងការគ្រប់គ្រងឯកសារ ឃុំ សង្កាត់ ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ប្រភពចំណូល របាយការណ៍ហិរញ្ញវត្ថុ ផលិតកម្ម ឃុំ សង្កាត់ ប្រព័ន្ធកសាងផែនការឃុំ សង្កាត់ គោលការណ៍សំខាន់ៗនៃការកសាងផែនការអភិវឌ្ឍន៍កម្មវិធីវិនិយោគ ឃុំ សង្កាត់ ដំណើរការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ ការជ្រើសរើសមេភូមិ និងជំនួយការមេភូមិ បែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ និងជំនួយការមេភូមិ អាណត្តិការងាររបស់មេភូមិ អនុប្រធានភូមិ និងសមាជិក ភូមិ។

**ជំពូកទី៤៖** ជំពូកនេះនិយាយអំពីបញ្ហាប្រឈម និងដំណោះស្រាយ

**សេចក្តីសន្និដ្ឋាន៖** តាមរយៈការស្រាវជ្រាវលើប្រធានបទខាងលើនេះ យើងខ្ញុំយល់ឃើញថារាជរដ្ឋាភិបាលបានខិតខំកែប្រែ និងអនុវត្តនូវគោលនយោបាយក្នុងការគ្រប់គ្រង ឃុំ សង្កាត់ តាមបែបវិមជ្ឈការ គឺដើម្បីសម្រួលឲ្យមានភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ឲ្យកាន់តែមានភាពរហ័ស និងងាយស្រួលជាងមុនជាពិសេសកាត់បន្ថយការចំណាយរបស់ប្រជាពលរដ្ឋឲ្យបានកាន់តែតិច និងចំណេញពេលវេលា។ ម្យ៉ាងវិញទៀត ការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការនេះ បានចូលរួមក្នុងការផ្តល់អំណាចដល់រាស្ត្រក្នុងការជ្រើសរើសអ្នកតំណាងតាមរយៈការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រដែលពួកគេស្រឡាញ់។

**អនុសាសន៍**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# ជំពូកទី១
# រំលឹកទ្រឹស្តី

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១ និយមន័យ

### ១.១.១ និយមន័យវិមជ្ឈការ

វិមជ្ឈការ មានន័យថា រាជរដ្ឋាភិបាលប្រគល់ឲ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធាន(ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់មូលដ្ឋាន។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋលើបញ្ហាទាំងនេះ។[3]

វិមជ្ឈការឃុំ សង្កាត់មានន័យថា សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធានមួយចំនួនត្រូវបានផ្ទេរពីរដ្ឋបាលថ្នាក់ជាតិទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានបោះឆ្នោតជ្រើសរើសដោយ ប្រជាពលរដ្ឋតាមលក្ខណៈប្រជាធិបតេយ្យ។

### ១.១.២ មុខងារវិមជ្ឈការ

វិមជ្ឈការមានមុខងារពីរខុសគ្នាគឺ៖

- **មុខងារនៃធម្មានរូបកម្មនៃអំណាចរបស់រដ្ឋ** ពោលគឺនៅពេលធ្វើវិមជ្ឈការអំណាចរបស់រដ្ឋបង្ហាញឲ្យឃើញសេរីភាវូបនីយកម្ម និងរបបមួយមានលក្ខណៈប្រជាធិបតេយ្យ។ ហេតុនេះ នយោបាយក្នុងការធ្វើវិមជ្ឈការរបស់រដ្ឋ គឺនយោបាយមួយចំណេញខាងស្មារតី ឬចិត្តសាស្ត្រ និយាយរួមអំណាចកណ្តាលត្រូវបានគោរពដោយប្រជាជន។
- **មុខងារនៃការបំពេញចិត្តទាមទារចេញមកពីកម្លាំងនយោបាយ និងសង្គម** ដែលមិនត្រួត ពិនិត្យដោយឧបករណ៍រដ្ឋ និងជាកម្លាំងដែលទាមទារសេរីភាពជាសមូហភាពមួយផ្នែក។

### ១.១.៣ លក្ខណៈពិសេសនៃវិមជ្ឈការ

បច្ចេកទេសនៃការគ្រប់គ្រងតាមនយោបាយវិមជ្ឈការមានលក្ខណៈពិសេសចំនួន បីគឺ៖

- **បុគ្គលភាពគតិយុត្ត** សម្តៅដល់ប្រព័ន្ធវិមជ្ឈការដែលមានបុគ្គលភាពគតិយុត្តខុសពីរដ្ឋ។ ប្រព័ន្ធនេះ ជាប្រធាននៃនីតិខុសពីរដ្ឋ។ ប្រព័ន្ធទាំងនេះមានសិទ្ធិ និងកាតព្វកិច្ចផ្ទាល់ខ្លួន មានគោលដៅ សិទ្ធិអំណាច និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន (ថវិកា សម្ភារ និងធនធានមនុស្ស)។
- **សមត្ថកិច្ចផ្ទាល់** សម្តៅដល់ប្រព័ន្ធវិមជ្ឈការខុសពីសមត្ថកិច្ចរដ្ឋ។ ពោលគឺមានលក្ខណៈគតិយុត្តពីរគឺ៖ (១)មិនមែនជាសមត្ថកិច្ចជាគោលការណ៍ទេ ប៉ុន្តែជាសមត្ថកិច្ចដែលកំណត់ដោយច្បាប់ និង(២)នៅ

[3] ក្រសួងមហាផ្ទៃ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ តាមបែបវិមជ្ឈការ ទំព័រ១

ពេលរដ្ឋកំណត់ភារកិច្ចរួចហើយ រដ្ឋមិនអាចចូលធ្វើអន្តរាគមន៍បានឡើយ។

- **ការប្រើប្រាស់សមត្ថកិច្ចស្វយ័ត** មានន័យថាគ្មានក្របឋានានុក្រមទេ រវាងរដ្ឋ និងប្រព័ន្ធវិមជ្ឈការ។ គ្មានអំណាចបង្គាប់បញ្ជាទេ ប៉ុន្តែ ការត្រួតពិនិត្យរបស់អំណាចកណ្តាលនៅតែមាននូវឡើយ ព្រោះរដ្ឋនៅតែជារដ្ឋទោលដដែល។ ហើយស្វ័យភាពមិនមែនឯករាជ្យភាពទេ។ ការត្រួតពិនិត្យនេះ ត្រូវធ្វើឡើងតាមរបៀបពីរយ៉ាងដែលអង្គការត្រួតពិនិត្យអាចជាអង្គការតុលាការ ឬអាជ្ញាធររដ្ឋបាល។

### ១.១.៤ ទម្រង់ផ្សេងៗនៃវិមជ្ឈការ

ទម្រង់ផ្សេងៗនៃវិមជ្ឈការ មានការកំណត់ជាច្រើនប្រភេទទៅតាមការបោះពុម្ពផ្សាយរបស់បុគ្គលល្បីៗ និងស្ថាប័នផ្សេងៗលើសកលលោក ក្នុងការគ្រប់គ្រងរដ្ឋបាលសាធារណៈ។ ចំណែកឯការបោះពុម្ពផ្សាយរបស់ United Nation Development Program (UNDP) ត្រូវបានបកស្រាយយ៉ាងសាមញ្ញនៃទ្រឹស្តីវិមជ្ឈការ ដោយផ្តោតលើការគ្រប់គ្រងវិស័យសាធារណៈ។ ទម្រង់វិមជ្ឈការនីមួយៗត្រូវឈរលើគោលការណ៍អភិបាលកិច្ចល្អ និងអាស្រ័យតាមករណីពិសេសរបស់ប្រទេសនីមួយៗ ។

## ១.២ ការរៀបចំរដ្ឋបាលឃុំ សង្កាត់

### ១.២.១ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយ ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួន តាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ស្របទៅតាមនីតិវិធីដូចមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវធ្វើឡើងរៀងរាល់ ០៥ (ប្រាំ) ឆ្នាំម្តង។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវរៀបចំធ្វើឡើងនៅថ្ងៃជាមួយគ្នា។ កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ នាយករដ្ឋមន្ត្រីត្រូវប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ០៩ (ប្រាំបួន) ខែ យ៉ាងតិចមុនថ្ងៃបោះឆ្នោត។ ការបោះឆ្នោតត្រូវធ្វើនៅថ្ងៃអាទិត្យ តែមួយថ្ងៃ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ដោយអ្នកបោះឆ្នោតដែល៖

- បានចុះឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅតាមឃុំ សង្កាត់នោះ
- មានសិទ្ធិបោះឆ្នោតបានតែមួយសន្លឹកប៉ុណ្ណោះ តាមរយៈការបោះឆ្នោតជាសម្ងាត់។

អ្នកបោះឆ្នោតម្នាក់ៗមានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់តែមួយប៉ុណ្ណោះ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវកាន់កាប់តំណែងរបស់ខ្លួនរហូតទាល់តែមានក្រុមប្រឹក្សាថ្មីដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងចូលកាន់តំណែងជំនួស។

## ១.២.២ រចនាសម្ព័ន្ធ និងតួនាទីរបស់រដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់នីមួយៗ ត្រូវមានរចនាសម្ព័ន្ធជាក់លាក់របស់ខ្លួនដោយផ្អែកតាមបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។[4]

- ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិក៥, ៧, ៩, ឬ១១ រូបផ្អែកតាមភូមិសាស្ត្រ និងចំនួនប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងឃុំ សង្កាត់។ ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ។
- ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗមានប្រធាន ០១រូប ដែលហៅថា ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាមេឃុំ ចៅសង្កាត់។
- ឃុំ សង្កាត់នីមួយៗមានមេឃុំ ចៅសង្កាត់ម្នាក់ ។ ស្ត្រី និងបុរស អាចត្រូវបានជ្រើសរើសឲ្យធ្វើជាមេឃុំ ចៅសង្កាត់ ដោយផ្អែកតាមលទ្ធផលនៃការបោះឆ្នោត ។
- មេឃុំ ចៅសង្កាត់មានជំនួយការ ០២រូប គឺជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ ។
- ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឲ្យមានមេភូមិម្នាក់សម្រាប់ភូមិនីមួយៗ ក្នុងឃុំ សង្កាត់របស់ខ្លួនដោយអនុវត្តតាមសេចក្តីណែនាំលេខ០០៤ស.ណ.ន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃស្តីពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែងការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ចរបៀបរបបធ្វើការងាររបស់ភូមិ ។ មេភូមិ គឺជាតំណាងឲ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ និងជាខ្សែ រយៈចម្បងសម្រាប់តភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់ ។ មេភូមិត្រូវមានជំនួយការរបស់ខ្លួន០២រូប ម្នាក់ជាអនុប្រធានភូមិ និងម្នាក់ទៀតជាសមាជិកភូមិ ។
- មេឃុំ ចៅសង្កាត់អាចចាត់តាំងបង្កើតគណៈកម្មាធិការនានាបានតាមការចាំបាច់ ។ គណៈ កម្មាធិការនីមួយៗមានសមាជិកយ៉ាងតិច០៣នាក់ ដើម្បីផ្តល់យោបល់ និងជួយការងារដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់អំពីបញ្ហាជាក់លាក់ណាមួយ។ គណៈកម្មាធិការនេះអាចយកសមាជិកណាម្នាក់

[4] ក្រសួងមហាផ្ទៃ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ ទំព័រ៩

ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ឲ្យធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឲ្យធ្វើជាប្រធានក៏បាន ។

- ឃុំសង្កាត់នីមួយៗ មានស្មៀនមួយរូបដែលត្រូវបានតែងតាំងនឹងបម្រើការងារនៅក្នុងក្របខ័ណ្ឌរដ្ឋបាលក្រសួងមហាផ្ទៃ ។ ស្មៀនឃុំ សង្កាត់ទទួលខុសត្រូវចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ ។ នៅក្នុងការបំពេញមុខងាររបស់ខ្លួនស្មៀនឃុំ សង្កាត់ត្រូវតែអព្យាក្រឹត្យមិនលម្អៀង ហើយត្រូវប្រកាន់ឥរិយាបទឲ្យបានស្មើៗគ្នាចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សាគ្រប់រូបដោយ មិនប្រកាន់និន្នាការនយោបាយ និងចំពោះគណៈកម្មាធិការនានា ។




រូបភាពដកស្រង់ចេញពី៖ ក្រសួងមហាផ្ទៃ **ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ**

### ១.២.៣ តួនាទី មុខងារ និងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់

មាត្រា៤១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ចែងថា រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញ និងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចីរភាពសម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍ជាតិស្របតាមគោលនយោបាយទូទៅរបស់រដ្ឋ។[5]

ផ្អែកតាមបទប្បញ្ញត្តិក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានផ្ទេរឲ្យនូវតួនាទី មុខងារ និងអំណាចមួយចំនួនសម្រាប់បម្រើប្រជាពលរដ្ឋ និងការអភិវឌ្ឍនៅមូលដ្ឋានរបស់ខ្លួន។

**ក. អំណាចរបស់រដ្ឋបាលឃុំ សង្កាត់៖** រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ រដ្ឋបាលឃុំ សង្កាត់មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ។

**-អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់៖** ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់ តាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ សម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឲ្យ។ ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ស្មារតីរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធឡើយ។ បើដីកាណាមួយដែលផ្ទុយនឹងលិខិតបទដ្ឋានគតិយុត្តខាងលើនេះ ដីកានោះនឹងត្រូវបានចាត់ទុកជាមោឃៈដាច់ខាត។

**-អំណាចប្រតិបត្តិរបស់ឃុំ សង្កាត់៖** មានន័យថារដ្ឋបាលឃុំ សង្កាត់មានសិទ្ធិអនុវត្តសេចក្តីសម្រេចរបស់ខ្លួននៅក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឲ្យ។ អំណាចប្រតិបត្តិនេះត្រូវបានធ្វើប្រតិភូកម្មឲ្យទៅមេឃុំ ចៅសង្កាត់ ជាអ្នកអនុវត្តក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។

**ខ. តួនាទី និងមុខងាររបស់រដ្ឋបាលឃុំ សង្កាត់**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទ គឺ៖

១. តួនាទីបម្រើកិច្ចការមូលដ្ឋានសម្រាប់បម្រើផលប្រយោជន៍ឃុំ សង្កាត់នឹងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន

២. តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។

**ក្នុងតួនាទីបម្រើកិច្ចការមូលដ្ឋាន** រដ្ឋបាលឃុំ សង្កាត់មានភារកិច្ច៖

- ធានារក្សាសន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ

[5] ក្រសួងមហាផ្ទៃ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ ទំព័រ៦

- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវឲ្យកិច្ចការទាំងនោះដំណើរការបានល្អ
- លើកទឹកចិត្តឲ្យមានការបង្កើនផាសុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋ ដើម្បីឲ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក
- បំពេញកិច្ចការជាទូទៅ ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

**ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ** ៖ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។ ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាព និងផ្តត់ផ្គង់មធ្យោបាយ សម្ភារ ថវិកាសម្រាប់អនុវត្ត។ ឧទាហរណ៍ដូចជាការចុះបញ្ជីអត្រានុកូលដ្ឋាន និងការចុះឈ្មោះអ្នកបោះឆ្នោតនៅក្នុងឃុំ សង្កាត់ជាដើម។

**គ. ព្រំដែននៃអំណាច**

រដ្ឋបាលឃុំ សង្កាត់អាចធ្វើសកម្មភាពបានតែនៅក្នុងក្របខ័ណ្ឌអំណាច តួនាទី និងមុខងារដែលច្បាប់បានប្រគល់ឲ្យប៉ុណ្ណោះ។ នេះមានន័យថា រដ្ឋបាលឃុំ សង្កាត់មិនអាចធ្វើសកម្មភាពណាមួយដែលផ្ទុយនឹងគោលការណ៍ និងបទប្បញ្ញត្តិដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានាឡើយ។

រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសម្រេចលើវិស័យ ៖

- ព្រៃឈើ
- ប្រៃសណីយ៍ និងទូរគមនាគមន៍
- ការពារជាតិ
- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ និង

វិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។

# ១.៣ កិច្ចការរដ្ឋបាលឃុំ សង្កាត់

## ១.៣.១ លិខិតបទដ្ឋានគតិយុត្តឃុំ សង្កាត់

### ក. និយមន័យលិខិតបទដ្ឋានគតិយុត្ត

លិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលឃុំ សង្កាត់ គឺជាលិខិតដែលកំណត់នូវវិធាន បទប្បញ្ញត្តិ បទបញ្ជា ឬគោលការណ៍នានាសម្រាប់ការគ្រប់គ្រង ការតែងតាំង ការបង្កើតឡើងនូវយន្តការ និងការណែនាំអនុវត្តកិច្ចការនានា។

### ខ. ប្រភេទលិខិតបទដ្ឋានគតិយុត្ត

លិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលឃុំ សង្កាត់ រួមមានដីកា និងសេចក្តីសម្រេច។

### ខ.១ ដីកា

ដីកាឃុំ សង្កាត់ គឺជាលិខិតបទដ្ឋានគតិយុត្តដែលកំណត់នូវបទប្បញ្ញត្តិទាំងឡាយដែលរដ្ឋបាលឃុំ សង្កាត់បង្កើតឡើង សំដៅបម្រើផលប្រយោជន៍ប្រជាពលរដ្ឋទូទៅក្នុងឃុំ សង្កាត់ដោយស្មើភាព មិនរើសអើង និងសម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចអនុវត្តក្នុងរង្វង់ដែនដីរបស់ខ្លួន។

ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងច្បាប់ និងលិខិតបទដ្ឋាននានារបស់រដ្ឋឡើយ។ ដីកាឃុំ សង្កាត់ត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។

### ខ.២ សេចក្តីសម្រេច

សេចក្តីសម្រេចឃុំ សង្កាត់ គឺជាលិខិតបទដ្ឋានគតិយុត្តដែលបង្កើតឡើង ដើម្បីអនុវត្តដីការបស់ខ្លួន ឬលិខិតបទដ្ឋាននានារបស់រដ្ឋ ឬចែងអំពីការបង្កើតការតែងតាំងការរៀបចំ ឬការគ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចអនុវត្តក្នុងរង្វង់ដែនដីរបស់ខ្លួន។

សេចក្តីសម្រេចមានលក្ខណៈប្រហាក់ប្រហែលនឹងដីកាឃុំ សង្កាត់ដែរ ប៉ុន្តែមានឋានានុក្រមទាបជាងដីកា និងខ្ពស់ជាងលិខិតរដ្ឋបាលសាមញ្ញធម្មតាផ្សេងៗទៀតក្នុងឃុំ សង្កាត់។

សេចក្តីសម្រេចឃុំ សង្កាត់មិនត្រូវផ្ទុយនឹងច្បាប់ និងលិខិតបទដ្ឋាននានារបស់រដ្ឋ និងដីការបស់ខ្លួនឡើយ។ សេចក្តីសម្រេចឃុំ សង្កាត់ត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។

ក្នុងករណីប្រធានសក្តិ និងបន្ទាន់បំផុតដែលមិនអាចកោះប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បាន មេឃុំ ចៅសង្កាត់

អាចចេញសេចក្តីសម្រេច ដើម្បីដោះស្រាយស្ថានភាពបន្ទាន់នោះ។ សេចក្តីសម្រេចនេះ និងត្រូវដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់នៅកិច្ចប្រជុំបន្ទាន់ ដើម្បីពិនិត្យឡើងវិញអំពីភាពត្រឹមត្រូវតាមច្បាប់។

### ១.៣.២ លិខិតរដ្ឋបាលឃុំ សង្កាត់

**ក. និយមន័យលិខិតរដ្ឋបាល**

លិខិតរដ្ឋបាល គឺជាលិខិតដែលរៀបចំកាត់តែងឡើងជាលាយលក្ខណ៍អក្សរសម្រាប់ជាមធ្យោបាយទំនាក់ទំនងផ្លូវការរបស់រដ្ឋបាលឃុំ សង្កាត់ជាមួយស្ថាប័ន អង្គភាព និងបុគ្គលនានា ក្នុងគោលបំណងជូនព័ត៌មាន ណែនាំ អញ្ជើញ រាយការណ៍ ផ្សព្វផ្សាយ ឆ្លើយតប ឬចាត់តាំង បុគ្គលណាមួយឲ្យទៅបំពេញបេសកកម្ម។

**ខ. ប្រភេទលិខិតរដ្ឋបាល**

លិខិតរដ្ឋបាលឃុំ សង្កាត់ដែលប្រើប្រាស់ជាផ្លូវការ រួមមាន (១)លិខិតស្នើ (២)សេចក្តីជូនដំណឹងឬលិខិតជូនដំណឹង (៣)លិខិតអញ្ជើញ (៤)លិខិតបញ្ជាបេសកកម្ម (៥)របាយការណ៍ (៦)កំណត់ហេតុ (៧)លិខិតផ្ទេរសិទ្ធិ និង (៨)ដីកាអម។

**ខ.១ លិខិតស្នើ**

លិខិតស្នើ គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីបង្ហាញពីគោលបំណង និងមូលហេតុនៃតម្រូវការជាក់លាក់ណាមួយរបស់ខ្លួនថ្លែងទៅកាន់រូបវន្តបុគ្គល នីតិបុគ្គលសាធារណៈ ឯកជន ក្រសួង ស្ថាប័ន អង្គការ ឬសង្គមស៊ីវិលដែលមានសិទ្ធិអំណាចសម្រេច ឬដោះស្រាយចំពោះការស្នើសុំនោះ។

**ខ.២ សេចក្តីជូនដំណឹង**

សេចក្តីជូនដំណឹង គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីធ្វើការទំនាក់ទំនងជាមួយបុគ្គលក្រសួងស្ថាប័ន អង្គការសង្គមស៊ីវិលមានខ្លឹមសារជាការឆ្លើយបំភ្លឺចំពោះបញ្ហា ឬជាការឆ្លើយតបចំពោះសំណើ ឬជាការជូនដំណឹងឲ្យសាធារណៈជនបានដឹងនូវព័ត៌មានទាំងឡាយដែលឃុំ សង្កាត់ត្រូវការផ្សព្វផ្សាយ។

**ខ.៣ លិខិតអញ្ជើញ**

លិខិតអញ្ជើញ គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីធ្វើការអញ្ជើញបុគ្គល ឬតំណាងក្រសួងស្ថាប័ន អង្គការសង្គមស៊ីវិលឲ្យចូលរួមក្នុងសកម្មភាពរបស់ឃុំ សង្កាត់ ចំពោះកិច្ចការដែលពាក់ព័ន្ធទៅនឹងបុគ្គលឬអង្គភាពទាំងនោះ ដោយមានបញ្ជាក់ឈ្មោះនិងឋានៈ (អ្នកដែលត្រូវអញ្ជើញ) ទីកន្លែងប្រជុំ ឬប្រារព្ធពិធី កាលបរិច្ឆេទកម្មវិធី ឬរបៀបវារៈប្រជុំ (និងអាចមានឯកសារដែលពាក់ព័ន្ធនឹងការប្រជុំភ្ជាប់ជាមួយ)។

**ខ.៤ លិខិតបញ្ជាបេសកកម្ម**

លិខិតបញ្ជាបេសកកម្ម គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើង ដើម្បីចាត់តាំងមន្ត្រី បុគ្គលិកឃុំ សង្កាត់ឲ្យចូលរួមក្នុងសកម្មភាពនានានៅក្រៅឃុំ សង្កាត់។ លិខិតនេះមានភ្ជាប់ជាមួយនូវទិដ្ឋាការធ្វើដំណើរ។

ទិដ្ឋាការធ្វើដំណើរ គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់ឲ្យអ្នកដែលមានភារកិច្ចទៅបំពេញបេសកកម្មយកទៅចុះទិដ្ឋាការនូវទីកន្លែងកាលបរិច្ឆេទ មធ្យោបាយធ្វើដំណើរ និងហត្ថលេខារបស់អង្គភាពមានសមត្ថកិច្ចដែលបានអនុញ្ញាត និងអង្គភាពដែលបានទទួលដឹងឮអំពីការចេញដំណើរ និងការមកដល់ពីដំណាក់មួយទៅដំណាក់មួយទៀត។

នៅពេលត្រឡប់មកវិញ ត្រូវធ្វើរបាយការណ៍ ឬរាយការណ៍ជូនមេឃុំ ចៅសង្កាត់ ឬក្រុមប្រឹក្សាឃុំ សង្កាត់ឲ្យបានជ្រាបអំពីលទ្ធផល ឬបញ្ហា សំខាន់ៗដែលខ្លួនបានទៅចូលរួម។

**ខ.៥ របាយការណ៍**

របាយការណ៍ គឺជាសេចក្តីរាយការណ៍អំពីសកម្មភាព ដំណើរការ និងលទ្ធផលការងាររបស់ឃុំ សង្កាត់ ឬបុគ្គលិកណាម្នាក់ ឬមួយក្រុមដែលរដ្ឋបាលឃុំ សង្កាត់បានបំពេញ ឬឃុំ សង្កាត់បានចាត់តាំងឲ្យទៅបំពេញដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំ និងអង្គភាពពាក់ព័ន្ធ។

ទម្រង់របាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ត្រូវអនុវត្តតាមសេចក្តីណែនាំលេខ ០៣៥ស.ណ.ន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្រៅពីទម្រង់របាយការណ៍ប្រចាំខែ និងទម្រង់របាយការណ៍ប្រចាំឆ្នាំខាងលើនេះ ឃុំ សង្កាត់អាចបង្កើត និងប្រើប្រាស់ទម្រង់របាយការណ៍ផ្សេងទៀតសម្រាប់ប្រើប្រាស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន។

**ខ.៦ កំណត់ហេតុ**

កំណត់ហេតុ គឺជាការកត់ត្រាស្រង់យកមតិយោបល់សេចក្តីសម្រេច និងការឯកភាពលើសកម្មភាព ដែលត្រូវអនុវត្តពីគ្រប់សមាជិកអង្គប្រជុំ និងការសម្រេចរបស់អង្គប្រជុំ ឬជាការកត់ត្រារាល់ហេតុការណ៍ណាមួយដែលបានកើតឡើងជាក់ស្តែង ដើម្បីរក្សាទុកជាសក្ខីភាពនៅពេលដែលមានតម្រូវការ។

**ខ.៧ លិខិតផ្ទេរសិទ្ធិ**

លិខិតផ្ទេរសិទ្ធិ គឺជាលិខិតរបស់មេឃុំ ចៅសង្កាត់ប្រកាសជាលាយលក្ខណ៍អក្សរប្រគល់សិទ្ធិឲ្យជំទប់ចៅសង្កាត់រងតាមឋានានុក្រមដើម្បីធ្វើជាមេឃុំ ចៅសង្កាត់ស្តីទីក្នុងអំឡុងពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន។

**ខ.៨ ដីកាអម**

ដីការអម គឺជាឯកសាររដ្ឋបាលដែលឃុំ សង្កាត់រៀបចំឡើង ផ្ញើអមភ្ជាប់ជាមួយសំណុំលិខិត ដែលត្រូវផ្ញើចេញទៅឲ្យអង្គភាព ក្រសួង ស្ថាប័នណាមួយ ដោយមានកត់ត្រាឈ្មោះ និងចំនួនលិខិត (ឯកសារ)លើដីការអមនោះ។ ឃុំ សង្កាត់ប្រើដីការអម ដើម្បីជៀសវាងការបាត់បង់ឯកសារដែលរដ្ឋបាលឃុំ សង្កាត់ផ្ញើចេញ។

### ១.៣.៣ ការគ្រប់គ្រងឯកសារ និងសម្ភារបរិក្ខារបស់ឃុំ សង្កាត់

#### ក. ការគ្រប់គ្រងសម្ភារបរិក្ខារឃុំ សង្កាត់

គ្រប់សម្ភារបរិក្ខាររបស់ឃុំ សង្កាត់ត្រូវចុះបញ្ជីឲ្យបានត្រឹមត្រូវ។ បញ្ជីគ្រប់គ្រងសម្ភារបរិក្ខារនេះត្រូវរក្សាទុកឲ្យបានល្អ ប្រកបដោយសុវត្ថិភាព និងធ្វើបច្ចុប្បន្នភាពជាប្រចាំ។

គ្រប់សម្ភារបរិក្ខាររបស់ឃុំ សង្កាត់ដែលកាត់ចេញពីបញ្ជីត្រូវធ្វើឡើងស្របតាមនីតិវិធី និងត្រូវសម្រេចដោយអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

#### ខ. ការគ្រប់គ្រងឯកសារឃុំ សង្កាត់

យោងតាមអនុក្រឹត្យលេខ ២២ អនក្រ.បក ស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ត្រង់មាត្រា៩ ចែងថា ៖

- ឃុំ សង្កាត់ គឺជាម្ចាស់លើរាល់លិខិត និងឯកសារដែលរៀបចំឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ឬក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ និងជាម្ចាស់កម្មសិទ្ធិលើតែមប្រ៊ី ត្រាឃុំ សង្កាត់ព្រមទាំងឧបករណ៍ផ្សេងៗទៀតទាំងអស់របស់ឃុំ សង្កាត់។
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាទុកដាក់ឯកសារ លិខិតស្នាមតែមប្រ៊ី ត្រាឲ្យបានត្រឹមត្រូវ និងគង់វង្ស។

#### ខ.១ និយមន័យនៃការគ្រប់គ្រងឯកសារ

ការគ្រប់គ្រងឯកសារ គឺជាការរៀបចំទុកដាក់ និងថែរក្សាឯកសារទាំងឡាយតាមប្រព័ន្ធមួយ មានសណ្តាប់ធ្នាប់ និងសុវត្ថិភាព។

#### ខ.២ ផលប្រយោជន៍នៃការគ្រប់គ្រងឯកសារ

ការគ្រប់គ្រងឯកសារនឹងផ្តល់នូវផលប្រយោជន៍មួយចំនួនដូចជា ៖

- បង្កលក្ខណៈងាយស្រួលក្នុងការស្វែងរក ព័ត៌មាន និងទិន្នន័យ សម្រាប់ដឹកនាំនៅក្នុងការពិភាក្សា និងការធ្វើសេចក្តីសម្រេច
- ជួយបន្តនិរន្តរភាពព័ត៌មាន នៅពេលមានអ្នកកាន់ការងារថ្មី និងអ្នកផ្លាស់ចេញ
- ផ្តល់នូវភស្តុតាងជាក់លាក់ពីកិច្ចការ ឬព្រឹត្តិការណ៍ដែលកើតរួចមកហើយ

- បង្កើនប្រសិទ្ធភាព និងសន្សំពេលវេលាដល់ការងាររដ្ឋបាលឃុំ សង្កាត់។

**ខ.៣ ប្រភេទឯកសារ**

ជាទូទៅ ឯកសារឃុំ សង្កាត់ មាន២ប្រភេទ គឺឯកសារផ្ទៃក្នុង និងឯកសារសាធារណៈ ។

ឯកសារផ្ទៃក្នុង គឺជាឯកសារទាំងឡាយណាដែលត្រូវបានប្រើប្រាស់ និងផ្សព្វផ្សាយសម្រាប់តែផ្ទៃក្នុងរបស់រដ្ឋបាលឃុំ សង្កាត់ និងបុគ្គលពាក់ព័ន្ធផ្ទាល់ប៉ុណ្ណោះ ។

**ឧទាហរណ៍ ៖**

- ផែនការអភិវឌ្ឍន៍
- កម្មវិធីវិនិយោគបីឆ្នាំរំកិល
- របាយការណ៍ហិរញ្ញវត្ថុ...។ល។

### ១.៣.៤ ការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់៖

- មាត្រា២១ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំយ៉ាងតិចណាស់ចំនួនមួយដងក្នុងមួយខែ។
- មាត្រា២៣ ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើជាសាធារណៈ និងមានលក្ខណៈប្រជាធិបតេយ្យ។ ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រជុំជាសម្ងាត់បាន។

**ក. លក្ខណៈនៃការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់**

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំជាទៀងទាត់យ៉ាងតិចម្តងក្នុងមួយខែ
- ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាអាចធ្វើការប្រជុំពិសេសបាន ដើម្បីពិភាក្សាលើបញ្ហាទាំងឡាយណាដែលក្រុមប្រឹក្សាបានកំណត់ថាជាកិច្ចការពិសេស ឬកិច្ចការបន្ទាន់ចាំបាច់
- រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការជំនួយការត្រូវធ្វើឡើងជាសាធារណៈ
- ក្រុមប្រឹក្សាឃុំ សង្កាត់អាចចាត់ឲ្យមានកិច្ចប្រជុំជាសម្ងាត់ ដើម្បីពិភាក្សាបញ្ហា ដូចខាងក្រោម ៖
  - ការដាក់វិន័យ ឬបញ្ឈប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
  - បញ្ហាសន្តិសុខក្នុងឃុំ សង្កាត់
  - ការរៀបចំសំណុំរឿងដើម្បីតវ៉ា ឬការពារក្តីអ្វីមួយ
  - ការដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងឯកត្តិយសបុគ្គល។
- ក្នុងកិច្ចប្រជុំសម្ងាត់មានតែក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់តែប៉ុណ្ណោះដែលមាន

សិទ្ធិចូលរួមក្នុងអង្គប្រជុំ។[6]

**បញ្ជាក់ ៖** សេចក្ដីលម្អិតសម្រាប់ការរៀបចំ និងការប្រព្រឹត្តទៅនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានចែងនៅក្នុង »បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការ»

### ខ. ការត្រៀមរៀបចំកិច្ចប្រជុំ

#### ខ.១ លិខិតអញ្ជើញ

មេឃុំ ចៅសង្កាត់ត្រូវតែធានាថា លិខិតអញ្ជើញត្រូវបានរៀបចំ និងផ្ញើជូនដល់អ្នកដែលត្រូវចូលរួមប្រជុំគ្រប់គ្នា ទាំងអស់ឲ្យបានមុនពេលប្រជុំ។

លិខិតអញ្ជើញត្រូវតែបញ្ជាក់ឲ្យបានច្បាស់លាស់អំពី ៖

- ពេលវេលា
- ទីកន្លែង និង
- បញ្ហាសំខាន់ដែលត្រូវពិភាក្សា ឬជម្រាបនៅពេលប្រជុំ និងឯកសារពាក់ព័ន្ធដែលភ្ជាប់ជាមួយលិខិតអញ្ជើញ។

#### ខ.២ ការបង្កើតរបៀបវារៈប្រជុំ

គ្រប់ការប្រជុំទាំងអស់ត្រូវមានរបៀបវារៈ ហើយត្រូវផ្ញើជូនដល់អ្នកចូលរួមជាមុន។ ជាការប្រសើរ អ្នកចូលរួមគួរមានឱកាសចូលរួមក្នុងការរៀបចំរបៀបវារៈ ៖

- ការងារដែលត្រូវពិភាក្សា និងសម្រេច
- ព័ត៌មានដែលត្រូវជម្រាប
- ពេលវេលាសម្រាប់កិច្ចប្រជុំ (តាមរបៀបវារៈនីមួយៗ)។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ច្រើនជាងមួយភាគបី អាចបន្ថែមប្រធានបទផ្សេងទៀតដែលស្ថិតនៅក្នុងអំណាច និងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដាក់បញ្ចូលក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

ចំនួនប្រជាពលរដ្ឋដែលអាចដាក់ស្នើបញ្ចូលបញ្ហាទៅរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បានមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

#### ខ.៣ ការផ្សព្វផ្សាយអំពីកិច្ចប្រជុំដល់សាធារណៈជន

កាលបរិច្ឆេទ និងទីកន្លែងនៃកិច្ចប្រជុំ ត្រូវផ្សព្វផ្សាយជាសាធារណៈដោយបិទផ្សាយនៅលើក្តារខៀន

[6] ក្រសួងមហាផ្ទៃ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ ទំព័រ២៧

ព័ត៌មានឃុំ សង្កាត់ និងនៅកន្លែងសាធារណៈក្នុងភូមិទាំងអស់ និងមធ្យោបាយផ្សព្វផ្សាយសមស្របដែលមាននៅមូលដ្ឋាន។

**គ. ការប្រព្រឹត្តទៅនៃកិច្ចប្រជុំ**

**គ.១ សមាជិករបស់អង្គប្រជុំ**

- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវចូលរួមរាល់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ និងអាចអវត្តមានបានលុះត្រាតែមានការអនុញ្ញាតជាមុន។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានសិទ្ធិបញ្ចេញមតិ និងនិយាយដោយគ្មានការភ័យខ្លាច ការរំខាន ឬការបំភិតបំភ័យឡើយ
- ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ស្ដីទីត្រូវដឹកនាំរាល់កិច្ចប្រជុំក្រុមប្រឹក្សា
- ស្មៀនឃុំ សង្កាត់ និងបុគ្គលិកដទៃទៀតរបស់ឃុំ សង្កាត់មានសិទ្ធិចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់
- ប្រជាពលរដ្ឋមានសិទ្ធិចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ លើកលែងតែកិច្ចប្រជុំសម្ងាត់។ ស្មៀនឃុំ សង្កាត់ និងប្រជាពលរដ្ឋមិនត្រូវបានអនុញ្ញាតឲ្យចូលរួម នៅក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងការបោះឆ្នោតឡើយ។

**គ.២ កូរ៉ុមនៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់**

កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រព្រឹត្តទៅបាន លុះត្រាណាតែមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់លើសពីពាក់កណ្ដាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលចូលរួមនៅក្នុងកិច្ចប្រជុំនោះ។

**បញ្ជាក់ ៖** ចំនួនក្រុមប្រឹក្សាឃុំ សង្កាត់លើសពីពាក់កណ្ដាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលមានដូចខាងក្រោម ៖

| ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចូលរួមយ៉ាងតិច |
|---|---|
| ៥ រូប | ៣ រូប |
| ៧ រូប | ៤ រូប |
| ៩ រូប | ៥ រូប |
| ១១ រូប | ៦ រូប |

### គ.៣ សកម្មភាពសំខាន់ៗនៅក្នុងកិច្ចប្រជុំ

កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រព្រឹត្តទៅតាមលំដាប់លំដោយដូចខាងក្រោម ៖

១. ពិនិត្យកូរ៉ុមនៃកិច្ចប្រជុំ

២. ពិនិត្យ និងអនុម័តរបៀបវារៈនៃកិច្ចប្រជុំ

៣. ពិនិត្យ និងអនុម័តកំណត់ហេតុនៃកិច្ចប្រជុំលើកមុន

៤. ពិភាក្សាតាមរបៀបវារៈនីមួយៗ ដូចជាពិនិត្យឯកសារ និងលិខិតផ្សេងៗដែលបានដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងសម្រេច

៥. បញ្ហាផ្សេងទៀត។

### គ.៤ ការដឹកនាំកិច្ចប្រជុំ

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាថា កិច្ចប្រជុំប្រព្រឹត្តទៅក្នុងលក្ខណៈប្រជាធិបតេយ្យមានសណ្តាប់ធ្នាប់ល្អ និងគ្មានការរំខាន។ អ្នកដឹកនាំកិច្ចប្រជុំល្អត្រូវបំពេញកិច្ចការមួយចំនួនដូចខាងក្រោម ៖

- ធានាថា សមាជិកអង្គប្រជុំទាំងអស់មានសិទ្ធិបញ្ចេញមតិ ហើយមតិរបស់សមាជិកម្នាក់ៗត្រូវបានពិចារណា។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រកាន់ឥរិយាបទឲ្យបានដូចគ្នាចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ ទោះបីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នោះមានមតិផ្ទាល់ខ្លួនបែបណាក៏ដោយ។
- ធានាថា ស្ត្រី និងបុរសមានឱកាសស្មើគ្នាក្នុងការបញ្ចេញមតិ។
- មានលទ្ធភាពធ្វើការប្រាស្រ័យទាក់ទងដោយច្បាស់លាស់ និងយ៉ាងប៉ិនប្រសព្វ។
- សម្របសម្រួលការពិភាក្សាដោយលើកយកបញ្ហានៅក្នុងរបៀបវារៈមកពិនិត្យម្តងមួយ ហើយពិភាក្សាបញ្ហានោះយ៉ាងល្អិតល្អន់។
- បោះឆ្នោតលើបញ្ហាណាដែលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មិនឯកភាពគ្នា។
- ប្រើប្រាស់ពេលវេលាដែលមានឲ្យបានល្អដើម្បីកុំឲ្យកិច្ចប្រជុំចំណាយពេលវេលាច្រើនជាងការចាំបាច់។
- ធានាថា ប្រជាពលរដ្ឋដែលបានអញ្ជើញចូលរួមនៅក្នុងការពិភាក្សាលើបញ្ហាជាក់លាក់ណាមួយ និងមានឱកាសសួរសំណួរ។

### គ.៥ ការធ្វើសេចក្តីសម្រេច

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់គ្រប់រូប មានសិទ្ធិបោះឆ្នោតនៅក្នុងគ្រប់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ទាំង

អស់ ។ ការបោះឆ្នោតត្រូវធ្វើឡើងដោយការលើកដៃ ។ សំឡេងគាំទ្រ និងសម្លេងមិនគាំទ្រត្រូវប្រកាសឲ្យដឹងភ្លាម ហើយកត់ត្រាទុកនៅក្នុងកំណត់ហេតុ ។ ស្មៀនឃុំ សង្កាត់ បុគ្គលិក និងអ្នកផ្សេងទៀតដែលចូលរួមប្រជុំ មិនអាចបោះឆ្នោតបានទេ ។

- សេចក្តីសម្រេចនៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ អាចចាត់ទុកជាបានការ លុះត្រាតែសេចក្តីសម្រេចនេះ ត្រូវបានអនុម័តដោយសំឡេងលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ជាពិសេសការអនុម័តលើបញ្ហា ដូចមានចែងក្នុងមាត្រ២២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។
- ចំពោះសេចក្តីសម្រេចលើកិច្ចការផ្សេងពីនេះ អាចចាត់ទុកជាបានការ លុះត្រាតែមានសំឡេងគាំទ្រភាគច្រើននៃចំនួនសមាជិកក្រុមប្រឹក្សា ដែលមានវត្តមានក្នុងអង្គប្រជុំ ។

## ឃ. ក្រោយកិច្ចប្រជុំ

### ឃ.១ កំណត់ហេតុប្រជុំ

ស្មៀនឃុំ សង្កាត់ត្រូវទទួលខុសត្រូវក្នុងការធ្វើកំណត់ហេតុប្រជុំដោយពិគ្រោះយោបល់ជាមួយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់គ្រប់រូប និងទទួលបានកំណត់ហេតុដែលមានចុះហត្ថលេខារបស់ប្រធានអង្គប្រជុំ ចំនួន០១ ច្បាប់ម្នាក់នៅក្នុងប្រជុំបន្ទាន់។

កំណត់ហេតុប្រជុំត្រូវយកចិត្តទុកដាក់លើចំណុចមួយចំនួនដូចខាងក្រោម ៖

- កាលបរិច្ឆេទពេលវេលា និងទីកន្លែងនៃកិច្ចប្រជុំ
- បញ្ជាក់អំពីសមាសភាពអ្នកចូលរួម រួមទាំងចំនួនវត្តមាន និងអវត្តមាន
- របៀបវារៈនៃកិច្ចប្រជុំ
- សេចក្តីសម្រេច និងបញ្ហានានាដែលបានលើកឡើងក្នុងអង្គប្រជុំ
- ពេលវេលាបិទអង្គប្រជុំ

កំណត់ហេតុប្រជុំផ្តល់ផលប្រយោជន៍ដូចខាងក្រោម ៖

- រក្សាទុកការរៀបរាប់ដោយសង្ខេប ប៉ុន្តែច្បាស់លាស់ពីអ្វីដែលបានពិភាក្សា និងសម្រេចនៅក្នុងកិច្ចប្រជុំ
- ធ្វើជាឯកសារសំអាងនៅពេលក្រោយ
- អាចប្រាប់ឲ្យដឹងថា ហេតុអ្វីបានជាសេចក្តីសម្រេចត្រូវបានធ្វើឡើង?
- អាចប្រាប់ព័ត៌មានអំពីអ្នកដែលត្រូវបានប្រគល់ភារកិច្ចជូន។

**ឃ.២ ការផ្សព្វផ្សាយលទ្ធផលប្រជុំដល់សាធារណជន**

បន្ទាប់ពីកិច្ចប្រជុំចប់ភ្លាម ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឲ្យធ្វើការជូនដំណឹងដល់សាធារណជន អំពីសេចក្តីសម្រេចនានារបស់ខ្លួនដោយបិទផ្សាយនៅលើក្តារព័ត៌មានឃុំ សង្កាត់។

**ឃ.៣ ការអនុវត្តសេចក្តីសម្រេចរបស់អង្គប្រជុំ**

សេចក្តីសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុវត្តនៅក្នុងរង្វង់ដែនដីឃុំ សង្កាត់របស់ខ្លួន បន្ទាប់ពីបញ្ចប់កិច្ចប្រជុំភ្លាម ។

# ជំពូកទី២
# ស្ថានភាពទូទៅស្តីពីវិមជ្ឈការ

# ជំពូកទី២
# ស្ថានភាពទូទៅស្ដីពីវិមជ្ឈការ

## ២.១ ស្ថានភាពទូទៅ

ឃុំ សង្កាត់ នៅក្នុងប្រទេសកម្ពុជា គឺជាបំណែងចែករដ្ឋបាលថ្នាក់ទី៣ បន្ទាប់ពីក្រុង ស្រុក ខណ្ឌ ដែលជាចែករដ្ឋបាលថ្នាក់ទី២ ។ ឃុំ សង្កាត់មួយមានភូមិដែលយ៉ាងហោចណាស់មានចំនួនពី ៣ភូមិ ឬរហូតដល់ទៅ ៣០ភូមិ អាស្រ័យលើស្ថានភាពប្រជាជនរស់នៅ។[7]

នៅក្នុងឆ្នាំ១៩៩៨ មានឃុំ សង្កាត់ចំនួន ១.៦០៩ឃុំ សង្កាត់ និងភូមិចំនួន ១៣.៤០៦ភូមិ នៅក្នុងប្រទេសកម្ពុជា។ ដោយផ្អែកលើជំរឿនក្នុងឆ្នាំ២០០៨ ឃើញថា មានឃុំ សង្កាត់ចំនួន ១.៦២១ឃុំ សង្កាត់ និងមានភូមិចំនួន ១៤.០៧៣ភូមិ។ ប៉ុន្តែតាមរបាយការណ៍ គណៈកម្មាធិការជាតិអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បច្ចុប្បន្នប្រទេសកម្ពុជាមានឃុំ សង្កាត់ចំនួន ១.៦៥២ឃុំ សង្កាត់ (១.៤០៩ឃុំ ២៤៣សង្កាត់) និងមានភូមិចំនួន ១៤.១៦៨ភូមិ។

## ២.២ ចំនួនឃុំ សង្កាត់

ចំនួនឃុំ សង្កាត់នៅក្នុងព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នមានចំនួនដូចខាងក្រោម ៖

០១. **ខេត្តបន្ទាយមានជ័យ** មានឃុំចំនួន៥៥ សង្កាត់ចំនួន១០

០២. **ខេត្តបាត់ដំបង** មានឃុំចំនួន៩២ សង្កាត់ចំនួន១០

០៣. **ខេត្តកំពង់ចាម** មានឃុំចំនួន១០៥ សង្កាត់ចំនួន០៤

០៤. **ខេត្តកំពង់ឆ្នាំង** មានឃុំចំនួន៦៦ សង្កាត់ចំនួន០៤

០៥. **ខេត្តកំពង់ស្ពឺ** មានឃុំចំនួន៨២ សង្កាត់ចំនួន០៥

០៦. **ខេត្តកំពង់ធំ** មានឃុំចំនួន៧៣ សង្កាត់ចំនួន០៨

០៧. **ខេត្តកំពត** មានឃុំចំនួន៨៨ សង្កាត់ចំនួន០៥

០៨. **ខេត្តកណ្ដាល** មានឃុំចំនួន១១៧ សង្កាត់ចំនួន១០

០៩. **ខេត្តកោះកុង** មានឃុំចំនួន២៦ សង្កាត់ចំនួន០៣

១០. **ខេត្តក្រចេះ** មានឃុំចំនួន៤២ សង្កាត់ចំនួន០៥

១១. **ខេត្តមណ្ឌលគិរី** មានឃុំចំនួន១៧ សង្កាត់ចំនួន០៤

១២. **រាជធានីភ្នំពេញ** មានសង្កាត់ចំនួន១០៥

---

[7] ដកស្រង់ចេញពី https://km.m.wikipedia.org/wiki/ឃុំ_សង្កាត់នៃកម្ពុជា

១៣. **ខេត្តព្រះវិហារ** មានឃុំចំនួន៤៩ សង្កាត់ចំនួន០២

១៤. **ខេត្តព្រៃវែង** មានឃុំចំនួន១១២ សង្កាត់ចំនួន០៤

១៥. **ខេត្តពោធិ៍សាត់** មានឃុំចំនួន៤២ សង្កាត់ចំនួន០៧

១៦. **ខេត្តរតនគិរី** មានឃុំចំនួន៤៦ សង្កាត់ចំនួន០៤

១៧. **ខេត្តសៀមរាប** មានឃុំចំនួន៨៨ សង្កាត់ចំនួន១២

១៨. **ខេត្តព្រះសីហនុ** មានឃុំចំនួន២៣ សង្កាត់ចំនួន០៦

១៩. **ខេត្តស្ទឹងត្រែង** មានឃុំចំនួន៣០ សង្កាត់ចំនួន០៤

២០. **ខេត្តស្វាយរៀង** មានឃុំចំនួន៦៨ សង្កាត់ចំនួន១២

២១. **ខេត្តតាកែវ** មានឃុំចំនួន៩៧ សង្កាត់ចំនួន០៣

២២. **ខេត្តឧត្តរមានជ័យ** មានឃុំចំនួន១៩ សង្កាត់ចំនួន០៥

២៣. **ខេត្តកែប** មានឃុំចំនួន០២ សង្កាត់ចំនួន០៣

២៤. **ខេត្តប៉ៃលិន** មានឃុំចំនួន០៤ សង្កាត់ចំនួន០៤

២៥. **ខេត្តត្បូងឃ្មុំ** មានឃុំចំនួន៦២ សង្កាត់ចំនួន០២។[8]

សរុបរាជធានី ខេត្តទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នមានចំនួន ១.៦៥២ ឃុំ សង្កាត់ គឺកើនឡើង០៦ឃុំ សង្កាត់ បើធៀបជាមួយនិងឆ្នាំ២០១៧ មានចំនួន១.៦៤៦ឃុំ សង្កាត់។

## ២.៣ ការវិវឌ្ឍឃុំ សង្កាត់ថ្មីបន្ថែម

ឃុំ សង្កាត់ដែលទើបបង្កើតថ្មីទាំង០៦ ឃុំ សង្កាត់គឺស្ថិតនៅក្នុងខេត្តបាត់ដំបង ចំនួន១ឃុំ នៅក្នុងខេត្តក្រចេះ ចំនួន១ឃុំ នៅក្នុងខេត្តកំពង់ស្ពឺ ចំនួន១ឃុំ នៅក្នុងខេត្តបន្ទាយមានជ័យ ចំនួន១ឃុំ និងនៅក្នុងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ចំនួន២សង្កាត់។[9] នេះបើយោងតាម អនុក្រឹត្យ ស្តីពី ការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ចុះហត្ថលេខាដោយសម្តេចតេជោ នាយករដ្ឋមន្ត្រី ហ៊ុន សែន នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ហើយត្រូវបានផ្សព្វផ្សាយកាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ បង្ហាញថា នៅទូទាំងប្រទេសកម្ពុជា មានឃុំ សង្កាត់ សរុបចំនួន ១៦៥២ឃុំ សង្កាត់។ ក្នុងនោះ ឃុំ សង្កាត់ បង្កើតថ្មីមានចំនួន ០៦ឃុំ សង្កាត់ (៤ឃុំ និង២សង្កាត់ ) ។ ពោលគឺនៅទូទាំងប្រទេសយើង

មាន ១៤០៩ឃុំ និង ២៤៣សង្កាត់ ។

---

[8] ដកស្រង់ចេញពី https://data.opendevelopmentmekong.net/km/library_record/book-record-of-names-and-numbers-of-capital-province-municipality-district-khan-commune-sangkat-and

[9] ដកស្រង់ចេញពី https://kohsantepheapdaily.com.kh/article/1390795.html

រាជរដ្ឋាភិបាល បានសម្រេចបង្កើតឃុំ សង្កាត់ថ្មី ចំនួន០៦ ថែមទៀតនេះ ត្រូវចូលជាធរមាន សម្រាប់ការបោះឆ្នោតឃុំ សង្កាត់ អាណត្តិទី៥ នាថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២ នេះ។

កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ រាជរដ្ឋាភិបាល បានចេញអនុក្រឹត្យ ដាច់ដោយឡែកពីគ្នាចំនួន ០៦ ស្តីពី ការសម្រេចបង្កើតឃុំ សង្កាត់ថ្មី ចំនួន ០៦ឃុំ សង្កាត់។ ឃុំ សង្កាត់ថ្មីទាំង ០៦រួមមាន ៖

១. ឃុំឬស្សីរិល ក្នុងស្រុកបវេល ខេត្តបាត់ដំបង

២. ឃុំយាយម៉ៅពេជ្រនិល ក្នុងស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

៣. ឃុំអូរកណ្តៀរសែនជ័យ ក្នុងស្រុកសំបូរ ខេត្តក្រចេះ

៤. ឃុំបុស្បូវ ក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

៥. សង្កាត់អូរជ្រៅ ក្នុងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

៦. សង្កាត់អូរឫស្សី ក្នុងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

ក្រៅពីសម្រេចបង្កើតឃុំ សង្កាត់ថ្មី សម្តេចប្រមុខរាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ ២០២១ ក៏បានចេញអនុក្រឹត្យ ស្តីពី ការកែសម្រួលព្រំប្រទល់រដ្ឋបាលឃុំមួយចំនួនផងដែរ។ ក្នុងនោះរួមមាន ៖ ឃុំបឹងល្វា ឃុំកំពង់ថ្ម និងឃុំប្រាសាទ ក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ ជាដើម។ ការបំបែក ឬបង្កើតរដ្ឋបាលឃុំ សង្កាត់ថ្មីៗនេះ ត្រូវបានផ្អែកលើកត្តា២ គឺកត្តាប្រជាសាស្ត្រ និងកត្តាភូមិសាស្ត្រ ក្នុងន័យដើម្បីឲ្យការបម្រើសេវាសាធារណៈជូនដល់ប្រជាពលរដ្ឋបានកាន់តែល្អប្រសើរ។

## ២.៤ ទិដ្ឋភាពសំខាន់ៗនៅក្នុងវិមជ្ឈការ

ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់មានសិទ្ធិបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។ ហើយប្រជាពលរដ្ឋ ត្រូវបានផ្តល់សិទ្ធិ និងការទទួលខុសត្រូវ ឲ្យចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការអភិវឌ្ឍមូលដ្ឋានឃុំ សង្កាត់របស់ខ្លួន។ លើសពីនេះទៅទៀតក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងតាមលក្ខណៈប្រជាធិបតេយ្យ ដូច្នេះ ក្រុមប្រឹក្សានេះជាតំណាងឲ្យប្រជាពលរដ្ឋ នៅក្នុងឃុំ សង្កាត់របស់ខ្លួន។

ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ៥ឆ្នាំ ហើយត្រូវបានផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង។ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានផ្តល់ការទទួលខុសត្រូវ និងភារកិច្ចជាច្រើនដែលខុសប្លែកទាំងស្រុងពី ការទទួលខុសត្រូវ និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់កាលពីមុនបោះឆ្នោតឆ្នាំ ២០០២។ ជាពិសេស ភារកិច្ចសំខាន់បំផុតរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ គឺអភិវឌ្ឍឃុំ សង្កាត់ហើយលើកកម្ពស់សុខុមាលភាព និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួនថែមទៀតផង។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ

ធានាឲ្យបានថា សហគមន៍នៅមូលដ្ឋានចូលរួមយ៉ាងពេញលេញ និងសកម្មនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងសេចក្តីសម្រេចនានា ដែលមានឥទ្ធិពលទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដូចជាសេចក្តីសម្រេចលើការប្រើប្រាស់ធនធាន សម្រាប់ការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនជាដើម។ ការធ្វើសេចក្តីសម្រេចដែលមានការចូលរួមពីប្រជាពលរដ្ឋ ទើបសេចក្តីសម្រេចនោះទទួលបាននូវប្រសិទ្ធភាព ខ្ពស់។

ហេតុនេះជាការពិតណាស់ អ្វីក៏ដោយបើគ្មានការចូលរួមពីប្រជារាស្ត្រនោះទេ ទោះបីរដ្ឋខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ ក៏វាមិនអាចទៅរួចដែរ ដូចជាការងារអភិវឌ្ឍនានាជាដើម។ ឃើញស្រាប់ ហើយបើរាស្ត្រគ្មានលទ្ធភាព និងចូលរួមនោះទេ ការអភិវឌ្ឍពិតប្រាកដវាបានត្រឹមតែ អភិវឌ្ឍខ្លួនឯងប៉ុណ្ណោះ។ ឧទាហរណ៍ៈ ក្រុមមន្ត្រីដែលទទួលភារកិច្ច តួនាទី ជាអ្នកជួយរាស្ត្រ សម្រាប់ធ្វើការអភិវឌ្ឍកិច្ច ការណាមួយ ហើយរាស្ត្រមើលឃើញថា មន្ត្រីនោះបានអភិវឌ្ឍខ្លួនឯង ជាជាងការអភិវឌ្ឍនៅក្នុងមូលដ្ឋានរបស់ខ្លួនគ្រប់គ្រង ដែលវាបញ្ជាក់ថាការអភិវឌ្ឍដែលខ្វះដៃគូ គឺមិនទទួលបាននូវប្រសិទ្ធភាពទេ

- ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់នីមួយៗមានសិទ្ធិបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ប្រជាពលរដ្ឋត្រូវបានផ្តល់សិទ្ធិ និងការទទួលខុសត្រូវ ដើម្បីចូលរួមយ៉ាងសកម្មក្នុងដំណើរការនៃការអភិវឌ្ឍមូលដ្ឋានឃុំ សង្កាត់របស់ខ្លួន
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោតដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួន
- ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងឲ្យប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន
- ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលមកកាន់តំណែង
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានផ្តល់ការទទួលខុសត្រូវ និងភារកិច្ចជាច្រើនដែលខុសប្លែកទាំងស្រុងពីការទទួលខុសត្រូវ និងភារកិច្ចរបស់ឃុំ សង្កាត់កាលពីមុនបោះឆ្នោតឆ្នាំ២០០២។ ភារកិច្ចសំខាន់បំផុតរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ គឺអភិវឌ្ឍឃុំ សង្កាត់ និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាឲ្យមានការចូលរួមយ៉ាងពេញលេញពីប្រជាពលរដ្ឋនៅក្នុង

ដំណើរការធ្វើសេចក្តីសម្រេច និងអនុវត្តសេចក្តីសម្រេចរបស់ខ្លួន។ ការចូលរួមនេះមានសារៈសំខាន់ណាស់គឺដើម្បីធានាថា បញ្ហា តម្រូវការ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋគ្រប់រូបត្រូវបានប្រមូល និងវិភាគគ្រប់ជ្រុងជ្រោយ មុននឹងធ្វើសេចក្តីសម្រេចចិត្ត

- ក្រុមប្រឹក្សាឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុ ថវិកា ទ្រព្យសម្បត្តិ និងបុគ្គលិកផ្ទាល់ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន
- ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗមានស្មៀនមួយរូបដែលត្រូវតែងតាំងដោយក្រសួងមហាផ្ទៃ។

**បញ្ជាក់ ៖** ទិដ្ឋភាពសំខាន់ៗទាំងអស់ដែលទាក់ទងនឹងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ត្រូវបានកំណត់នៅក្នុង **ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។**

## ២.៥ ហេតុផលនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ

ប្រទេសដែលអនុវត្តតាមគោលការណ៍វិមជ្ឈការ នាំមកនូវការរីកចម្រើនខាងសេដ្ឋកិច្ចខ្លាំងឡើងៗយ៉ាងឆាប់រហ័សក៏ដូចជាការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងដោះស្រាយ ក្នុងការគ្រប់គ្រងឲ្យកាន់តែមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ ហើយការផ្តល់សេវាសាធារណៈកាន់តែប្រសើរឡើងថែមទៀតក្នុងនោះគឺមានការផ្តោតយកចិត្តទុកដាក់ថែមទៀតទៅលើការធ្វើប្រតិភូកម្មថវិកា ភារកិច្ច និងការទទួលខុសត្រូវខ្ពស់នៅក្នុងមូលដ្ឋាន។ ក្រៅពីនេះគឺ ការធ្វើឲ្យប្រសើរឡើងថែមទៀតក្នុងការធ្វើសេចក្តីសម្រេចចិត្តទាំងឡាយបានត្រឹមត្រូវទៅតាមទីកន្លែង និងពេលវេលា ព្រោះមានការ ចូលរួមដោយប្រជាពលរដ្ឋនៅតាមមូលដ្ឋានផ្ទាល់។

ហើយនរណានឹងទទួលបានផលប្រយោជន៍ទាំងនោះ?

វិមជ្ឈការ ឃុំ សង្កាត់នេះគឺត្រូវបានអ្នកនយោបាយទាំងឡាយផ្តួចផ្តើមឡើង និងអនុម័តយល់ស្របអំពីកំណែទម្រង់វិមជ្ឈការនេះដូចនេះអ្នកនយោបាយ និងទទួលបានផលប្រយោជន៍ ពីវាជាមិនខាន(បើមិនដូច្នោះទេពួកគេ មិនយល់ព្រមធ្វើការកំណែទម្រង់វិមជ្ឈការនោះទេ)។ ក្រៅពីអ្នកនយោបាយទាំងនេះមានប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ព្រោះវិមជ្ឈការបានផ្តល់នូវ អង្គភាពរដ្ឋបាលពោរពេញទៅដោយការប្រជែងខ្លាំងក្លាដែលអាចឆ្លើយតបបានច្រើនជាងមុនចំពោះតម្រូវការរបស់ប្រជាពលរដ្ឋគ្រប់រូប ព្រោះគេចង់បានការគាំទ្រពីប្រជាពលរដ្ឋនៅតាមមូលដ្ឋានរបស់គេ។

ដូចនេះរដ្ឋាភិបាលបានខិតខំធ្វើកំណែទម្រង់ការគ្រប់គ្រងវិមជ្ឈការនៅឃុំ សង្កាត់ដើម្បីទទួលបាននូវសមិទ្ធផលជាច្រើនដូចជា៖

- កាត់បន្ថយនូវភាពមិនអើពើចំពោះការអភិវឌ្ឍនៅមូលដ្ឋាន

- ជំរុញឲ្យមានការចូលរួម និងសកម្មនៃអង្គភាពរួបរួមផ្សេងៗរបស់ប្រជាពលរដ្ឋ នៅតាមមូលដ្ឋាន ឲ្យកាន់តែខ្លាំងឡើង ។

ពង្រឹងការឆ្លើយតប ឲ្យបានឆាប់រហ័ស និងយល់ច្បាស់ អំពីតម្រូវការរបស់ប្រជាពលរដ្ឋ

- បង្កើននូវលំហូរព័ត៌មានពីរដ្ឋបាលថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់មូលដ្ឋាន
- ធ្វើឲ្យគម្រោងអភិវឌ្ឍន៍កាន់តែមានចីរភាព
- ពង្រឹងនូវតម្លាភាព
- ដើម្បីជំរុញការទទួលខុសត្រូវឲ្យកាន់តែខ្ពស់
- ធ្វើឲ្យសម្រេចបាននូវកិច្ចប្រឹងប្រែងថ្មីៗ
- កាត់បន្ថយឥទ្ធិពលអវិជ្ជមាន
- ធ្វើឲ្យកម្មវិធីអភិវឌ្ឍន៍កាន់តែរលូនជាងមុននៅមូលដ្ឋាន
- កាត់បន្ថយនូវសកម្មភាពពុករលួយ
- ពង្រឹងលទ្ធិប្រជាធិបតេយ្យនៅក្នុងមូលដ្ឋាន ។

កត្តាទាំងអស់នេះហើយថាប្រទេសកម្ពុជាយើងសម្រេចចិត្តធ្វើការគ្រប់គ្រងនៅរដ្ឋបាលឃុំសង្កាត់តាមបែបវិមជ្ឈការបន្តទៀត ។

## ២.៦ ទិសដៅវិមជ្ឈការ

ការធ្វើវិមជ្ឈការនេះ គឺដើម្បីផ្តល់ឱកាសដល់ប្រជាពលរដ្ឋឲ្យចូលរួមកាន់តែទូលំទូលាយនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលមានផលប៉ះពាល់ទៅ និងជីវភាពរស់នៅ និងអនាគតរបស់ខ្លួន។ លើសពីនេះទៅទៀតដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។ ហើយធានាការអភិវឌ្ឍន៍ប្រកបដោយចីរភាពរួមទាំងការផ្តល់សេវាឲ្យនៅជិតប្រជាពលរដ្ឋ និងយល់ច្បាស់អំពីតម្រូវការចាំបាច់របស់ពួកគាត់។

ទិសដៅវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គឺៈ

- ផ្តល់ឱកាសដល់ប្រជាពលរដ្ឋឲ្យចូលរួមកាន់តែទូលំទូលាយនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលមានផលប៉ះពាល់ទៅលើជីវភាពរស់នៅ និងអនាគតរបស់ខ្លួន
- លើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃជីវភាពរស់នៅ
- ធានាការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងការផ្តល់សេវាជាមូលដ្ឋានផងដែរ។

### ២.៦.១ ការផ្តល់ឱកាសឲ្យប្រជាពលរដ្ឋចូលរួមពេញលេញ

តាមរយៈប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននៅថ្នាក់ឃុំ សង្កាត់ ប្រជាពលរដ្ឋគ្រប់រូប (ស្ត្រី បុរស ចាស់ ក្មេង ជនងាយរងគ្រោះ) មានសិទ្ធិចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពរបស់ឃុំ សង្កាត់ និងដំណើរការនៃការអភិវឌ្ឍមូលដ្ឋាន ដូចជា ការបញ្ចេញមតិ និងការរួមចំណែកតាមមធ្យោបាយផ្សេងៗ។ ប្រជាពលរដ្ឋមានសិទ្ធិលើកឡើងអំពីសេចក្តីត្រូវការ និងផលប្រយោជន៍របស់ខ្លួន តាមរយៈនីតិវិធី និងយន្តការដែលបានកំណត់ក្នុងលិខិតបទដ្ឋាន និងសេចក្តីណែនាំនានា។

ប្រជាពលរដ្ឋអាចចូលរួមតាមមធ្យោបាយជាច្រើន ដូចជា ៖

- បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលពួកគាត់គិតថាអាចតំណាងឲ្យផលប្រយោជន៍របស់ពួកគាត់បានប្រសើរបំផុត
- បង្កើតទំនាក់ទំនងជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំពោះការងារពាក់ព័ន្ធនឹងការអភិវឌ្ឍឃុំ សង្កាត់
- លើកឡើងអំពីបញ្ហា និងផលប្រយោជន៍របស់ពួកគាត់ជាមួយសមាជិកក្រុមប្រឹក្សា ដើម្បីឲ្យសមាជិកក្រុមប្រឹក្សាលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ឬតាមរយៈការចាត់ចែងកិច្ចការប្រចាំថ្ងៃរបស់រដ្ឋបាលឃុំ សង្កាត់ ដោយមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រងស្មៀនឃុំ សង្កាត់
- ពិនិត្យតាមដានការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដូចជាការផ្តល់សេវា ការអនុវត្តគម្រោងអភិវឌ្ឍន៍ និងការអនុវត្តសកម្មភាពនានានៅក្នុងមូលដ្ឋានរបស់ខ្លួន
- សិទ្ធិចូលរួមទទួលបាននូវព័ត៌មានពីក្រុមប្រឹក្សាឃុំ សង្កាត់ ឬប្រជាពលរដ្ឋអាចទៅកាន់សាលាឃុំ សង្កាត់ដើម្បីទទួលព័ត៌មានផ្សេងៗដែលខ្លួនចង់ដឹង។

ការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាភារកិច្ចយ៉ាងសំខាន់របស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ការចូលរួមនេះជួយឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ស្វែងយល់ពីសេចក្តីត្រូវការ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ហើយបង្កើតកម្មវិធីដើម្បីដោះស្រាយសេចក្តីត្រូវការទាំងនោះ។ ប្រសិនបើ ប្រជាពលរដ្ឋបានចូលរួម ប្រជាពលរដ្ឋមានអារម្មណ៍ថានឹងមានការទទួលខុសត្រូវចំពោះការអភិវឌ្ឍនៅក្នុងមូលដ្ឋានរបស់ខ្លួន។

### ២.៦.២ ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃការរស់នៅ

វិមជ្ឈការត្រូវបានចាត់ទុក ប្រហែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការជំរុញអភិបាលកិច្ចល្អ។ អភិបាលកិច្ចល្អ គឺជាការអនុវត្តការងារឲ្យបានសមស្របទៅនឹងទិដ្ឋភាពសំខាន់ៗ មួយចំនួនដូចខាងក្រោម៖

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញការងារដោយអនុលោមទៅតាមច្បាប់ និងលិខិតបទដ្ឋាននានា។

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋ របស់ខ្លួនតាមបែបលទ្ធិប្រជាធិបតេយ្យ។ ដូច្នេះអ្វីដែលក្រុមប្រឹក្សាឃុំ សង្កាត់បានសម្រេច និងអនុវត្តគឺត្រូវទទួលខុសត្រូវយ៉ាងពេញលេញចំពោះប្រជាពលរដ្ឋរបស់ខ្លួន។ នេះមានន័យថាក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ
  - ធ្វើផែនការឲ្យឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ
  - ផ្តល់ព័ត៌មានពីរបៀបប្រើប្រាស់ធនធានដែលខ្លួនមាន និង
  - ធានាថាធនធានទាំងនោះពិតជាត្រូវបានប្រើប្រាស់ដើម្បីបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋប្រកបដោយតម្លាភាព និងគណនេយ្យភាព
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានតម្លាភាពនៅក្នុងការងារទាំងអស់ដែលខ្លួនបានបំពេញ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជម្រាបជូនសាធារណជនរាយការណ៍នានាដែលខ្លួនបានពិភាក្សា ឬសេចក្តីសម្រេចថាខ្លួនបានធ្វើ ដូចជា ការផ្សព្វផ្សាយដល់សាធារណជន និងការទទួលមតិយោបល់របស់សាធារណជនអំពីការកសាងផែនការអភិវឌ្ឍ និងការរៀបចំថវិកាឃុំ សង្កាត់ការផ្សព្វផ្សាយជាសាធារណៈអំពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តាមរយៈការបិទផ្សាយនៅលើក្តារខៀនព័ត៌មាន ឬតាមមធ្យោបាយផ្សេងៗទៀតនៅមូលដ្ឋាន
- ការចូលរួមជាមួយប្រជាពលរដ្ឋ គឺជាសមាសធាតុយ៉ាងសំខាន់មួយទៀតនៅក្នុងអភិបាលកិច្ចល្អ ។

## ២.៦.៣ ប្រវត្តិនៃការគ្រប់គ្រងវិមជ្ឈការឃុំ សង្កាត់

ឃុំ សង្កាត់មិនដែលធ្លាប់មានអទិភាពទេ នៅក្នុងប្រទេសកម្ពុជាតាំងពីមុនការមកដល់នៃពួកអាណានិគមនិយមបារាំង។ នាឆ្នាំ១៨៧៥ ប្រព័ន្ធគ្រប់គ្រងរដ្ឋនៅក្រោមការគ្រប់គ្រងបារាំងផង និងសៀមផងកត្តាទាំងអស់ខាងលើនេះហើយជាបទពិសោធន៍ និងជាកញ្ចក់ឆ្លុះបញ្ចាំងអំពីសង្គមខ្មែរនាអតីតកាលយកធ្វើជាមូលដ្ឋានសិក្សាដើម្បីរៀបចំកែប្រែវាសនាអនាគតសង្គមជាតិខ្មែររបស់យើង ។

ព្រះរាជក្រឹត្យចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩០៨ បានបង្កើតនូវក្របខណ្ឌរដ្ឋបាលស៊ីវិលមួយដែល **«ឃុំ»** គេអាចនិយានបានថាជាប្រភពនៃច្បាប់គ្រប់គ្រង «ឃុំ» របស់ប្រទេសកម្ពុជាដែលមានចែងអំពីនិយមន័យ **«ឃុំ»** ថារួមមានការបញ្ចូលគ្រួសារជាច្រើនរួមគ្នាឲ្យបង្កើតបានជាភូមិហើយភូមិជាច្រើនរួមគ្នាបង្កើតបានជាឃុំមួយ។

នៅឆ្នាំ១៩១៩ ដល់១៩៤៣ ដើម្បីឲ្យមានភាពកាន់តែជិតស្និទ្ធរវាងប្រជាជន និងរាជការក្នុងការបំពេញការងាររបស់ខ្លួនឲ្យបានឆាប់រហ័ស និងមានប្រសិទ្ធិភាពរដ្ឋាភិបាលអាណានិគមនិយមបារាំង បានផ្តួចផ្តើមឲ្យមានព្រះរាជក្រឹត្យចំនួន២ទៀតគឺ ៖

- ព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩១៩ដែលរដ្ឋាភិបាលកណ្តាលបានប្រគល់ប្រភពធនធានហិរញ្ញវត្ថុរបស់ខ្លួនដល់ឃុំជាអ្នកគ្រប់គ្រង និងអំណាចឲ្យមេឃុំជាអ្នករៀបចំអភិវឌ្ឍមូលដ្ឋានឃុំរបស់ខ្លួនផ្ទាល់

- ព្រះរាជក្រឹត្យ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩២៥ រដ្ឋាភិបាលអាណានិគមនិយមបារាំងផ្តល់ឲ្យមេឃុំនូវអំណាចក្នុងការរៀបចំចាត់ចែងការងារយុត្តិការការងារគ្រប់គ្រងរដ្ឋបាល ឃុំ ការងារហិរញ្ញវត្ថុដោយមានកម្រិតអត្រាពន្ធអាករ ឃុំកំណត់តម្លៃសម្រាប់ការងាររដ្ឋបាល និងការធ្វើបុណ្យប្រទាន។ ហើយព្រះរាជក្រឹត្យនេះ ក៏នៅបានផ្តល់ឲ្យឃុំបោះឆ្នោតរៀបចំនូវក្រុមជំនុំរបស់ខ្លួន ដែលកើតចេញពីការបោះឆ្នោត ហើយជ្រើសរើសមេឃុំម្នាក់ដែលជាអ្នកទទួលខុសត្រូវចំពោះការអនុវត្តសេចក្តីសម្រេចរបស់ក្រុមជំនុំដែលជានីតិបុគ្គល និងមានអាណត្តិ៤ឆ្នាំ។ បន្ទាប់ពីការបោះឆ្នោតគេ សង្កេតឃើញថា មានការអភិវឌ្ឍយ៉ាងច្រើន និងប្រជាពលរដ្ឋរស់នៅសមរម្យ ដោយសារមានការចុះពង្រឹងនៅតាមមូលដ្ឋានរដ្ឋបាលកណ្តាល ។

នៅឆ្នាំ១៩៤៣ ដោយសារប្រទេសកម្ពុជាមានសង្គ្រាមឈ្លានពានប្រព័ន្ធបោះឆ្នោតនៅឃុំមានការលុបចោល ស្ទើតែទាំងស្រុង ដោយដាក់ជំនួសការតែងតាំងមេឃុំ និងជំទប់ ពីសំណាក់អភិបាលខេត្ត និងដោយមានការយល់ព្រមពីរ៉េស៊ីដង់។ ព្រះរាជក្រមលេខ ៤០នស ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៤៣ បានប្រកាសឲ្យឃុំដែលមានចំនួនប្រជាជនច្រើន មិនឲ្យមានការបោះឆ្នោតទេ ចំណែកឯ ឃុំដែលមានប្រជាជនតិចអនុញ្ញាតឲ្យមានការបោះឆ្នោត ដដែលប៉ុន្តែមិនត្រូវបានអនុវត្តទេ ។ រហូតដល់ឆ្នាំ១៩៤៨ ការបោះឆ្នោតជ្រើសរើសក្រុមជំនុំត្រូវបានផ្អាកទាំងស្រុង។ ហើយនៅក្នុងឆ្នាំ១៩៥៥ មានសារាចរណែនាំមួយឲ្យការបោះឆ្នោតមេឃុំឡើងវិញតែវាមិនសូវមានប្រសិទ្ធភាពដូចពីមុនទេ។

ដោយយល់ឃើញអំពីសារៈសំខាន់នៃការបោះឆ្នោតជ្រើសរើសក្រុមជំនុំទើបនៅឆ្នាំ១៩៥៩ មានព្រះរាជក្រម មួយទៀតលេខ៣៤០នស ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៥៩ បានតម្រូវឲ្យមានការបោះឆ្នោតជ្រើសរើសក្រុមជំនុំឃុំ ជានីតិបុគ្គល ដូចនៅឆ្នាំ១៩២៥ សម្រាប់រយៈពេល៤ឆ្នាំ។ ហើយមេឃុំ និងជំទប់ ត្រូវជ្រើសរើសពីក្នុងក្រុមជំនុំ ដែលជាប់ឆ្នោតដោយយកតាមសំឡេងភាគច្រើន។ រចនាសម្ព័ន្ធដែលមាននៅពេលនោះគឺមាន មេឃុំ ជំទប់ស្មៀន គឺជាអ្នកដឹកនាំអនុវត្តផ្ទាល់(អង្គការប្រតិបត្តិ ឃុំ) និងក្រុមជំនុំ ដឹកនាំអង្គការបញ្ញត្តិឃុំ ដោយមានមេឃុំ ជាប្រធាននៃក្រុមជំនុំ។ ហើយចៅហ្វាយខេត្តគឺជាអ្នកចេញដីកាខេត្តប្រកាសសុពលភាព និងតែងតាំងមេឃុំ និងក្រុមជំនុំតាមដីកាខេត្ត។

តែមិនដល់រយៈពេល ៣ខែ ផងព្រះរាជក្រមនេះត្រូវបានគេដាក់ព្យួរទុកក្នុងរយៈពេលមិនកំណត់បន្ទាប់ពីបានធ្វើប្រជាមតិនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៥៩។ ដូចនេះមេឃុំ និងជំទប់ មិនត្រូវបានបោះឆ្នោតទេហើយនៅតែមានការតែងតាំងពីអភិបាលខេត្ត។ រហូតមកដល់ឆ្នាំ១៩៦៩ តាមព្រះរាជក្រឹត្យលេខ៣៨៣/៦៩CE/ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៦៩ បានប្រកាសកែប្រែឲ្យឈប់ធ្វើការបោះឆ្នោតជ្រើសរើសក្រុមជំនុំ មេឃុំ និងជំទប់។ ហើយមេឃុំ

ជំទប់ត្រូវបានតែងតាំងតាមរយៈដីកាខេត្តតាមសំណើរបស់អភិបាលស្រុក។ ចាប់ពីពេលនោះមក ឃុំលែងមានថវិកាផ្ទាល់ខ្លួន និងគ្មានការបោះឆ្នោតទៀតហើយ ។

បន្ទាប់ពីសមាជិកជាតិលើកទី២០ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៦៥ គេបានស្នើសុំឲ្យប្តូរពាក្យ «**ឃុំ**» ទៅជា «**សង្កាត់**» សម្រាប់ហៅនៅក្នុងទីក្រុង ហើយរក្សាពាក្យ «**ឃុំ**» សម្រាប់ការហៅនៅ «**ខេត្ត**» ដដែល។

ហើយនៅឆ្នាំ១៩៩៦-១៩៩៧ ក្នុងនីតិកាលទី១ នៃរដ្ឋសភាក្រសួងមហាផ្ទៃដែលទទួលបានការណែនាំគោលនយោបាយពីរាជរដ្ឋាភិបាលហើយបានសិក្សាស្រាវជ្រាវរៀបចំតាក់តែងច្បាប់ និងលិខិតបទដ្ឋានគ្រប់គ្រងឃុំ សង្កាត់ឲ្យក្លាយជានីតិបុគ្គល។ សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់ និងសេចក្តីព្រាងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានរៀបចំរួចហើយប៉ុន្តែដោយសារស្ថានភាពនយោបាយនៅកម្ពុជាមានបញ្ហាបន្តិចបន្តួចទើបមិនអាចយកមកពិភាក្សានៅក្នុងគណៈរដ្ឋមន្ត្រីបាន។

ក្រោយពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រសម្រាប់នីតិកាលទី២ រួចរាល់ហើយក្រសួងមហាផ្ទៃបានបន្តលើកយកសេចក្តីព្រាងច្បាប់ទាំងពីរខាងលើ ធ្វើសាជាថ្មីម្តងទៀត ដោយផ្អែកលើសភាពការណ៍ជាក់ស្តែង នៃនិន្នាការវិវត្តន៍នៃសង្គមជាតិ និងភាពចាំបាច់សម្រាប់លុបបំបាត់ភាពអសកម្មនៅមូលដ្ឋានការប្រឆាំងអំពើពុករលួយកាត់បន្ថយភាពក្រីក្រ និងចង់ឲ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាជននៅក្នុងដំណើរការអភិវឌ្ឍសង្គមជាតិ។ ហើយព្រាងច្បាប់ទាំងពីរខាងលើ ហេតុនេះត្រូវបានដាក់ជូនរដ្ឋសភាពិនិត្យ និងអនុម័តនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០០១។ ហើយការគ្រប់គ្រងឃុំ សង្កាត់តាមបែបវិមជ្ឈការនៅកម្ពុជាក៏ចាប់ផ្តើមអនុវត្តឡើងវិញសាជាថ្មីទៀតចាប់ពីពេលនោះរហូតមកដល់ពេលបច្ចុប្បន្ន។

សរុបមក ប្រវត្តិនៃការអនុវត្តរដ្ឋបាលឃុំ សង្កាត់នៃប្រទេសកម្ពុជាគេសង្កេតឃើញមានការកែប្រែជាញឹកញាប់ក្នុងគោលបំណងធ្វើឲ្យមានការគ្រប់គ្រងនៅតាមមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការប្រជាពលរដ្ឋ។ ក្នុងនោះគេសង្កេតឃើញថាចាប់តាំងពីឆ្នាំ១៨៨៩ ដល់ឆ្នាំ១៩៥៣ មានការកែប្រែធំៗចំនួន៧ គឺនៅក្នុងឆ្នាំ១៨៨៩ គឺបារាំងបានកែសម្រួលរដ្ឋបាលទាំងស្រុងហើយ ឆ្នាំ១៩០១ បារាំងបានបញ្ចូលគោលការណ៍ជ្រើសរើស មេឃុំ និងក្រុមជំនុំ។ បន្ទាប់នៅឆ្នាំ១៩០២ បារាំងឲ្យប្រាក់កម្រៃដល់ មេឃុំ និងក្រុមជំនុំហើយឆ្នាំ ១៩១៩ បារាំងបានប្រគល់ប្រភពធនធានហិរញ្ញវត្ថុឲ្យដល់ឃុំជាអ្នកគ្រប់គ្រង និងផ្តល់អំណាចឲ្យ មេឃុំខាងរៀបចំអភិវឌ្ឍមូលដ្ឋាននៅឃុំរបស់ខ្លួនផ្ទាល់។ នៅក្នុងឆ្នាំ១៩២៥ រដ្ឋាភិបាលអាណានិគមនិយមបារាំងបានផ្តល់ឲ្យមេឃុំ នូវអំណាចក្នុងការរៀបចំចាត់ចែងការងារ យុត្តាធិការ ការងារគ្រប់គ្រងរដ្ឋបាលឃុំ ការងារហិរញ្ញវត្ថុ ដើម្បីឲ្យការងារកាន់តែមានប្រសិទ្ធភាពនៅថ្នាក់មូលដ្ឋាន ។

# ជំពូកទី៣
# តួនាទី និងការកិច្ចរដ្ឋបាលឃុំ សង្កាត់

# ជំពូកទី៣
# តួនាទី និងភារកិច្ចរដ្ឋបាលថ្នាក់ឃុំ សង្កាត់

## ៣.១. ក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួន និងជាភ្នាក់ងារតំណាងរដ្ឋដែលស្ថិតក្រោមការប្រគល់អំណាចរបស់រដ្ឋ។[10] ក្នុងនាមតំណាងប្រជាពលរដ្ឋ ក្រុមប្រឹក្សាមានតួនាទី ធំធេងក្នុងការបម្រើកិច្ចការមូលដ្ឋាន រៀបចំសណ្តាប់ធ្នាប់សាធារណៈ សេវាសាធារណៈ ផាសុកភាព និងសុខុមាលភាពសេដ្ឋកិច្ច សង្គមកិច្ច ថែរក្សាបរិស្ថាន ។ល។ ក្នុងក្របខណ្ឌនយោបាយវិមជ្ឈការ។ ហើយតាមរយៈច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ គឺមានសមជិកពី ៥ ទៅ ១១ នាក់ ដោយយោងទៅតាមលក្ខខណ្ឌភូមិសាស្ត្រ និងប្រជាសាស្ត្រ។ ក្រុមប្រឹក្សានេះត្រូវបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួន[11] ស្របតាមនីតិវិធីដែលបានកំណត់ ហើយ ឃុំ សង្កាត់មានភារកិច្ចទទួលខុសត្រូវក្នុងការអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួន ដោយត្រូវមានប្រធាន ក្រុមប្រឹក្សា ជាមេឃុំ ចៅសង្កាត់។

ក្រុមប្រឹក្សាឃុំ សង្កាត់ មានសមាជិក ៥, ៧, ៩ ឬ ១១នាក់ ផ្អែកតាមភូមិសាស្ត្រ និងចំនួនប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងឃុំ សង្កាត់នោះ។[12] ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ។ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ មានប្រធាន ០១រូប ដែលហៅថា ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ គឺជា **មេឃុំ ចៅសង្កាត់** ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទី៖

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ធានាឲ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចឲ្យបានមួយដងក្នុងមួយខែ
- ធានាឲ្យសម័យប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ របស់ខ្លួនដំណើរការបានត្រឹមត្រូវទៅតាមវិធាន និងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់
- រក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទី ភារកិច្ច ដូចខាងក្រោម ៖

- ធានាក្រុមប្រឹក្សាឃុំ សង្កាត់ប្រើប្រាស់អំណាចតួនាទី និងមុខងារដូចមានចែងក្នុងច្បាប់ និង

[10] មាត្រា៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

[11] មាត្រា២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

[12] មាត្រា១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

លិខិតបទដ្ឋានពាក់ព័ន្ធ

- ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសហប្រតិបត្តិការជាមួយនឹងប្រជាពលរដ្ឋ ។

## ៣.២. រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

ដោយសារតែមានកិច្ចព្រមព្រៀងសន្តិភាពនាឆ្នាំ១៩៩១ ប្រទេសកម្ពុជាបានរៀបចំចងក្រងឡើងវិញនៃប្រព័ន្ធរដ្ឋបាល មិនមែនកុម្មុយនីស្តរបស់ខ្លួន ស្របទៅតាមឆន្ទៈមោះមុតរបស់ អ្នកនយោបាយខ្មែរ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់នៅកម្ពុជាដែលឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្រជាតិស្តីពី វិមជ្ឈការ។ ហើយច្បាប់នេះ គឺជាក្របខណ្ឌគតិយុត្តជាមូលដ្ឋានសម្រាប់អនុវត្ត ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ។

នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០២ អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ប្រទេសកម្ពុជា បានរៀបចំការបោះឆ្នោតរបស់ខ្លួនតាមលក្ខណៈប្រជាធិបតេយ្យដោយធានា សេរីភាព ភាពត្រឹមត្រូវ និងយុត្តិធម៌ ក្នុងការបោះឆ្នោតជ្រើសរើសតំណាងក្រុមប្រឹក្សាឃុំ សង្កាត់។

### ៣.២.១. មេឃុំ ចៅសង្កាត់

មេឃុំ ចៅសង្កាត់ជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួន។ ហើយក៏ជាអ្នកដឹកនាំបញ្ជាប្រតិបត្តិ ដោយរួមមានកិច្ចការរដ្ឋបាលឃុំ សង្កាត់ផងដែរ។ ដោយសារគេមិនអាចញែកឲ្យដាច់រវាងអំណាចប្រតិបត្តិ និងអំណាចបញ្ញត្តិដែលមាននៅក្នុងថ្នាក់រដ្ឋបាលឃុំ សង្កាត់វាធ្វើឲ្យមេឃុំ ចៅសង្កាត់ មានតួនាទី ជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើជាអធិបតីនៃ កិច្ចប្រជុំ របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវជំរុញឲ្យមានការប្រជុំយ៉ាងតិចម្តងក្នុងមួយខែ និងជាអ្នកធានាការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។[13]

មេឃុំ ចៅសង្កាត់ គឺជាអ្នកប្រតិបត្តិតាមការប្រគល់អំណាចពីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការអនុវត្តផែនការអភិវឌ្ឍឃុំ សង្កាត់ និងទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាថែមទៀតផង។ ហើយមេឃុំ ចៅសង្កាត់ ក៏មានភារកិច្ចទទួលខុសត្រូវចំពោះម្ចាស់សន្លឹកឆ្នោត ជាពិសេសចំពោះគោលនយោបាយបក្ស ដែលមេឃុំ ចៅសង្កាត់ ក៏មិនអាចល្មើសបានដែរ។ វាជាបញ្ហារដ្ឋបាលឃុំ សង្កាត់ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា កំពុងប្រកាន់យកគឺ "បក្ស" ជាធំលើអ្វីៗទាំងអស់ក្នុងកិច្ចការអភិវឌ្ឍ និងដឹកនាំឃុំ សង្កាត់ដែលមានលំនាំដូចគ្នាចំពោះរបបនយោបាយមិនមែនសេរីនិយមគឺអ្វីៗ សុទ្ធតែត្រូវបាន បក្សជាអ្នកកំណត់។

[13] មាត្រា១៣ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

មេឃុំ ចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានា ដើម្បីផ្តល់យោបល់ និងជួយកិច្ចការទាំងឡាយណាដែលចាំបាច់។[14] ហើយមេឃុំ ចៅសង្កាត់មានសិទ្ធិជ្រើសរើសបុគ្គលិកក្រៅក្របខណ្ឌ សម្រាប់ផ្តល់យោបល់ចំពោះកិច្ចការទាំងឡាយណាដែលមេឃុំ ចៅសង្កាត់យល់ឃើញថា ជាកិច្ចការបច្ចេកទេស ហើយដែលខ្លួនមិនមានលទ្ធភាព និងត្រូវធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់។ ហេតុនេះមេឃុំ ចៅសង្កាត់ មានសិទ្ធិជ្រើសរើសគណៈកម្មាការនានា ដើម្បីស្រាវជ្រាវចំពោះកិច្ចការជំនាញ និងរាយការណ៍ឲ្យខ្លួនវិញ ហើយ គណៈកម្មាធិការនេះអាចបញ្ឈប់ពេលណាក៏បានដែរ ។

មេឃុំ ចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋានក្នុងដែនដីឃុំ សង្កាត់ដែលខ្លួនគ្រប់គ្រង[15] ដែលមានភារកិច្ចដូចមានចែងក្នុងមាត្រា៩ នៃអនុក្រឹត្យ លេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៣។ ក្នុងតួនាទីនេះមេឃុំ ចៅសង្កាត់មានអំណាច ខ្លាំងបំផុតក្នុងការកំណត់ថានរណាម្នាក់បានកើត ឬរស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន។ បើសិនជាមេឃុំ ចៅសង្កាត់យកអំណាចនេះទៅប្រើក្នុងន័យល្អវាជាការប្រសើរណាស់ ចំពោះអភិបាលកិច្ចនៅមូលដ្ឋានរបស់ខ្លួន តែផ្ទុយទៅវិញ បើមេឃុំ ចៅសង្កាត់អាចបង្កើតនូវបរិយាកាសពុករលួយ និងការគាបសង្កត់ទៅលើការធ្វើសំបុត្រកំណើត សំបុត្រអាពាហ៍ ពិពាហ៍ និងសំបុត្រមរណៈឲ្យនរណាម្នាក់ និងបន្លំ សំបុត្រទាំង៣ នេះសម្រាប់ឲ្យនរណាម្នាក់ដែលមិនមែនជាជនជាតិខ្មែរពិតប្រាកដ ដូចនេះវា និងធ្វើឲ្យសង្គមជាតិមានភាពច្របូកច្របល់។

បើយើងពិនិត្យមើលពីតួនាទីរបស់មេឃុំ ចៅសង្កាត់ ដូចជាមានអំណាចច្រើនពេកហើយ។ ដូចជា មេឃុំ ចៅសង្កាត់ អាចតែងតាំងគណៈកម្មការណាមួយសម្រាប់ឲ្យធ្វើកិច្ចការដែលខ្លួនយល់ ថាចាំបាច់ និងការទទួលខុសត្រូវជ្រើសរើសមេភូមិជាដើម ដែលគេមើលទៅហាក់បីដូចមិនមែន ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទេ គឺជាការបោះឆ្នោតជ្រើសរើស មេឃុំ ចៅសង្កាត់ទៅវិញ ។ តាមការអនុវត្តជាក់ស្តែង តើមេឃុំ ចៅសង្កាត់ អាចបង្កើតគណៈកម្មាធិការតាមការចាំបាច់របស់ខ្លួនបាន ដែរឬទេ?

តាមពិតមាត្រានេះគ្រាន់តែមានក្នុងក្រដាសច្បាប់ទេ។ ដូចករណី សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិរបស់ខ្លួនមួយចំនួនដូចជា គណៈកម្មាធិការសេដ្ឋកិច្ច គណៈកម្មាធិការហិរញ្ញវត្ថុ គណៈកម្មាធិការរដ្ឋបាល គណៈកម្មាធិការសង្គមកិច្ច គណៈកម្មាធិការសេវាសាធារណៈ និងគណៈកម្មាធិការសណ្តាប់ធ្នាប់សាធារណៈ ហើយមានចែងអំពីតួនាទី និងភារកិច្ច តាមដីកាសង្កាត់ លេខ ០០១/០២ ដ.ក ហើយពេលនោះមានការចេញប្រកាសបដិសេធ ដោយក្រសួងមហាផ្ទៃ លេខ២៤៨ប្រ.ក ចុះថ្ងៃ

[14] មាត្រា២៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

[15] មាត្រា៨ នៃអនុក្រឹត្យលេខ ១០៣អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន

ទី០២ ខែកញ្ញា ឆ្នាំ២០០២ ដោយគ្រាន់តែលើកឡើងនូវមូលហេតុ ៣ យ៉ាងរបស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន គឺ (១) មិនស្របច្បាប់នីតិវិធីដែលបានកំណត់, (២) ការកំណត់សមាសភាពគណៈកម្មាធិការនីមួយៗពុំបានសម្រេចដោយក្រុមប្រឹក្សាសង្កាត់, (៣) ការកំណត់អំពីភារកិច្ចរបស់គណៈកម្មាធិការមួយចំនួនដែលច្បាប់ពុំទាន់ចេញ។

ឃុំ សង្កាត់នីមួយៗ មានមេឃុំ ឬចៅសង្កាត់ ម្នាក់។ ស្ត្រី និងបុរសអាចត្រូវបានជ្រើសរើសឲ្យធ្វើជាមេឃុំ ឬចៅសង្កាត់។[16] មេឃុំ ឬសង្កាត់ មានតួនាទីភារកិច្ចដូចខាងក្រោម៖

- ធានាថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុវត្ត
- រាយការណ៍អំពីការបំពេញការងារប្រចាំខែ ជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្តល់យោបល់ និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់លើការងារកសាងផែនការ ការរៀបចំហិរញ្ញវត្ថុ និងការអនុវត្តអំណាច តួនាទី និងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- បំពេញការងារ ផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់ប្រគល់ឲ្យ
- ផ្ទេរសិទ្ធិដល់ជំទប់ ឬចៅសង្កាត់រងតាមឋានានុក្រមនៅពេលខ្លួនអវត្តមាន ។

### ៣.២.២. ជំទប់ ចៅសង្កាត់រង

ជំទប់ ឬ ចៅសង្កាត់រងជាជំនួយការមេឃុំ ចៅសង្កាត់មានភារកិច្ចផ្សេងក្រៅពីបទបញ្ញត្តិអាស្រ័យដោយមេឃុំ ចៅសង្កាត់ប្រគល់ឲ្យ។ ជំទប់ទី១ ឬ ចៅសង្កាត់រងទី១ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយមេឃុំ ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមទៀតបានដល់ជំទប់ទី១ ចៅសង្កាត់រងទី១។ ជាពិសេស ជំទប់ទី១ ចៅសង្កាត់រងទី១ អាចបំពេញការងារជាមេឃុំ ចៅសង្កាត់ ស្តីទីក្នុងករណីដែលមេឃុំ ចៅសង្កាត់អវត្តមាន។ ហើយជំទប់ទី២ ចៅសង្កាត់រងទី២ ទទួលជួយមេឃុំ ចៅសង្កាត់ លើកិច្ចការផ្នែករដ្ឋបាលសេវាសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ។[17] ហើយអាចបំពេញការងារជាមេឃុំ ចៅសង្កាត់ ក្នុងករណីដែលមេឃុំ ចៅសង្កាត់ និងជំទប់ទី១ចៅសង្កាត់រងទី១ អវត្តមាន។

មេឃុំ ឬចៅសង្កាត់ត្រូវមានជំនួយការ ០២រូប ចាំបាច់គឺជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ ដែលមានតួនាទីភារកិច្ចដូចខាងក្រោម៖

- **ជំទប់ទី១ ឬចៅសង្កាត់រងទី១**
  - ទទួលជួយមេឃុំ ឬចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  - មេឃុំ ឬចៅសង្កាត់អាចប្រគល់ភារៈកិច្ចបន្ថែមដល់ជំទប់ទី១ ឬចៅសង្កាត់រងទី១

[16] ក្រសួងមហាផ្ទៃ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ ទំព័រ១៣

[17] មាត្រា២៦ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

- ◦ បំពេញការងារជាមេឃុំ ចៅសង្កាត់ស្ដីទីករណីមេឃុំ ចៅសង្កាត់អវត្តមាន ។
- **ជំទប់ទី២ ឬចៅសង្កាត់រងទី២**
  - ◦ ជួយមេឃុំ ឬចៅសង្កាត់ក្នុងការងារផ្នែករដ្ឋបាល សេវាសង្គមកិច្ចសេវាសាធារណៈ និងកិច្ចការពារសណ្ដាប់ធ្នាប់សាធារណៈនៅក្នុងមូលដ្ឋាន
  - ◦ មេឃុំ ចៅសង្កាត់អាចប្រគល់ការងារបន្ថែមដល់ជំទប់ទី២ ឬចៅសង្កាត់រងទី២
  - ◦ បំពេញការងារជាមេឃុំ ឬចៅសង្កាត់ស្ដីទីក្នុងករណីមេឃុំ ចៅសង្កាត់ និងជំទប់ទី១ឬចៅសង្កាត់រងទី១ អវត្តមាន ។

### ៣.២.៣. ស្មៀន

ស្មៀនឃុំ សង្កាត់ គឺជាមន្ត្រីស្ថិតនៅក្នុងក្របខណ្ឌលេខាធិការនៃក្រសួងមហាផ្ទៃ ដែលតែងតាំងឡើងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ[18] តាមរយៈការប្រឡងជ្រើសរើសពីមន្ត្រីរាជការ សិស្ស និស្សិត មានភារកិច្ចជួយកិច្ចការឃុំ សង្កាត់។ ស្មៀនឃុំ សង្កាត់ អាចនឹងត្រូវផ្លាស់ប្ដូរក្នុងករណី បើមានសំណើរពីមេឃុំ ចៅសង្កាត់ អនុលោមតាមការសម្រេចពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ តាមសំឡេងភាគច្រើនដាច់ខាត។ ហើយច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលចែងថា ស្មៀន គឺជាអ្នកធានានិរន្តរភាពនៃកិច្ចការរដ្ឋបាល ហើយតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ដូចនេះនៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់ មួយចំនួនធំ ដែលមិនស្ថិតនៅក្នុង គណបក្សដូចគ្នា វានឹងនាំឲ្យមានការលំបាកក្នុងការសហការពីស្មៀន និងមេឃុំ ចៅសង្កាត់ ដែលមាននិន្នាការនយោបាយខុសគ្នា។

ដូចនេះបើសិនជាស្មៀនឃុំ សង្កាត់ មិនព្រមស្ដាប់តាមបញ្ជារបស់មេឃុំ ចៅសង្កាត់ ដែលមាននិន្នាការនយោបាយខុសគ្នា តើមេឃុំ ចៅសង្កាត់មានវិធានការបែបណា សម្រាប់គ្រប់គ្រងស្ថានភាព និងធានាឲ្យការងារមានប្រសិទ្ធភាព?

យោងតាមមាត្រា២៨ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បានទុកឲ្យមេឃុំ ចៅសង្កាត់ អាចមានសិទ្ធិដកស្មៀន បានគ្រប់ពេលវេលា។ ហើយមាត្រា២៩ នៃច្បាប់នេះ ក៏បានផ្ដល់ការអនុញ្ញាតឲ្យមេឃុំ ចៅសង្កាត់ ជ្រើសរើសបុគ្គលិករដ្ឋបាល ផ្សេងទៀត ក្រៅពីស្មៀនបាន តាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឲ្យគ្រប់គ្រងការងារមួយចំនួន ដូចជាការងារខាងច្បាប់ ខាងបច្ចេកទេស ថវិកា ជាដើម ហើយបុគ្គលទាំងនេះមិនស្ថិតក្រោមការបង្គាប់បញ្ជារបស់ស្មៀនឡើយ គឺស្ថិតក្រោមការបង្គាប់បញ្ជារបស់មេឃុំ ចៅសង្កាត់ និងក្រុមប្រឹក្សាឃុំ

[18] មាត្រា២៨ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

សង្កាត់ទាំងមូល ដើម្បីធានាឲ្យកិច្ចការនៅក្នុងឃុំ សង្កាត់របស់ខ្លួនទទួលបាននូវប្រសិទ្ធភាព និងមានការអភិវឌ្ឍ។

ហើយនៅក្នុងការអនុវត្តជាក់ស្តែង បើស្មៀនឃុំ សង្កាត់មានប្រភពពីគណបក្សដូចគ្នា គឺក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចធ្វើទៅរួចទេ និងមានឧបសគ្គជាច្រើនក្នុងការដកសិទ្ធិពីស្មៀន ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប៉ុន្តែអាចធ្វើទៅរួចប្រសិនជាមានការគាំទ្រពីបណ្តាលទំនាក់ទំនងជាមួយ អភិបាល ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលមនុស្សនៅក្នុងបក្សតែមួយ យល់ព្រម ដោយឆ្លងតាមការពិនិត្យ ពិចារណាឲ្យមានភាពសមហេតុផលក្នុងផ្លូវនយោបាយ ឬភាពយកចំណេញ ខាងនយោបាយដែលស្មៀននោះមានការបម្រើយ៉ាងស្មោះត្រង់ ឬក៏សកម្មភាពរបស់ស្មៀន ធ្វើឲ្យប៉ះពាល់ដល់ប្រជាប្រិយភាពរបស់បក្ស និងមិនស្មោះត្រង់ចំពោះក្រុមគណបក្សនយោបាយរបស់ ខ្លួន។ ឧទាហរណ៍ៈ ស្មៀនឃុំ សង្កាត់បានកំណត់សេវារដ្ឋបាល ក្នុងតម្លៃខ្ពស់ដើម្បីជាប្រយោជន៍ដល់ខ្លួនដោយសំអាងថាថ្នាក់លើជាអ្នកកំណត់មកអញ្ចឹង ដែលជាគណបក្សដឹកនាំប្រទេសជាតិ ដូចនេះវា និងអាចប៉ះពាល់ដល់ការបោះឆ្នោតអាណត្តិក្រោយរបស់បក្ស ដូចនេះ ស្មៀនរូបនេះប្រាកដជាត្រូវទំលាក់ជាមិនខាន។

សព្វថ្ងៃរដ្ឋបាលនៃប្រទេសកម្ពុជាបានកំពុងធ្វើនយោបាយភាវូបនីយកម្ម តាំងពីថ្នាក់ភូមិ រហូតដល់រចនាសម្ពន្ធថ្នាក់កំពូល ដូចជារដ្ឋមន្ត្រី អភិបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវជ្រើសរើសមនុស្សរបស់បក្ស។

ដូចនេះសម្រាប់អ្នកធ្វើការរាជការសុទ្ធសាធ ដែលមានចំណេះដឹង និងសមត្ថភាព ប៉ុន្តែគ្មានខ្សែ និងបក្សពួក ពិតជាមិនអាចមាននូវឱកាស និងបានឡើងកាន់តំណែង និងការងារក្នុងតួនាទីជាថ្នាក់ដឹកនាំណាស់ សូម្បីថ្នាក់ការិយាល័យ និងនាយកដ្ឋាន។ នេះហើយជាបញ្ហានៃការគ្រប់គ្រងរដ្ឋបាលសាធារណៈនៅកម្ពុជា ដែលត្រូវធ្វើការកែទម្រង់ក្នុងទស្សនទានដើម្បីប្រយោជន៍ជាតិ។ តើដល់ពេលណា អាណត្តិណា ដែលគេអាចរៀបចំការគ្រប់គ្រងរដ្ឋបាលឲ្យមានតម្លាភាព និងកាត់បន្ថយនូវប្រភេទមនុស្សដែលចូលចិត្តឡេមឡើមអែបអប ដែលគ្មានចំណេះដឹង និងសមត្ថភាព។

ឃុំ សង្កាត់នីមួយៗ មានស្មៀនមួយរូបដែលត្រូវបានតែងតាំង និងបម្រើការងារនៅក្នុងក្រមខណ្ឌរដ្ឋលេខាធិការរដ្ឋបាលនៃ ក្រសួងមហាផ្ទៃ។[19] ស្មៀនឃុំ សង្កាត់ទទួលខុសត្រូវចំពោះក្រុមប្រឹក្សាឃុំ សង្កាត់មានន័យថា ការអនុវត្តការងាររបស់ស្មៀនឃុំ សង្កាត់ត្រូវស្ថិតក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ស្មៀនឃុំ សង្កាត់មានតួនាទីដូចខាងក្រោមៈ

- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងគណៈកម្មាធិការនានាបំពេញ

[19] ក្រសួងមហាផ្ទៃ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ ទំព័រ១៤

តួនាទី និងមុខងារស្របតាមតម្រូវការច្បាប់

- បំពេញការងាររដ្ឋបាល
- ធានាថា សេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ស្របទៅនឹងលក្ខខណ្ឌច្បាប់
- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំ និងអនុវត្តន៍ កិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានារបស់ឃុំ សង្កាត់
- ចូលរួមគោរពកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ លើកលែងតែបានទទួលការអនុញ្ញាតឲ្យអនុវត្តជាមុនពីក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់
- ជួយដល់ ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំឲ្យមានក្តារខៀនព័ត៌មានមួយ ឬច្រើនកន្លែងដើម្បី បិទ តាមសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ ផ្សាយសេចក្តីជូនដំណឹង សេចក្តីសម្រេច និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

### ៣.២.៤. មេភូមិ

- លេខ004 សណន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ ដែលយោងទៅលើច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់ គឺបានកំណត់ច្បាស់លាស់អំពីលក្ខខណ្ឌ នៃការបាត់តំណែង របស់មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ។ លក្ខខណ្ឌទាំងនោះរួមមានសាមីខ្លួនមរណៈភាព សាមីខ្លួនសុំលាឈប់ពីតំណែងជាលាយលក្ខណ៍អក្សរ សាមីខ្លួនបាត់កាយសម្បទាវិជ្ជាជីវៈ សាមីខ្លួនត្រូវលុបឈ្មោះពីបញ្ជីបោះឆ្នោតឃុំ សង្កាត់ សាមុីខ្លួនត្រូវផ្តន្ទាទោស សាមីខ្លួនផ្លាស់ទៅនៅភូមិផ្សេង និងសាមីខ្លួនមានកំហុសក្នុងការងារត្រូវបញ្ឈប់ដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។

មានមូលហេតុមួយចំនួននៃការបញ្ឈប់មុខតំណែងមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិមានដូចខាងក្រោម៖

- ករណី មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិណាមួយដែលប្រព្រឹត្តខុសឆ្គងក្នុងការងារ មេឃុំ ចៅសង្កាត់សាមុី ត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរឲ្យកែចំណុចខុសឆ្គង និងរាយការណ៍ជូនកិច្ចប្រជុំបន្ទាន់របស់ក្រុមប្រឹក្សាឃុំ សង្កាត់។
- នៅក្នុងករណីដែលទទួលការណែនាំហើយ សាមុីខ្លួននៅតែប្រព្រឹត្តខុសឆ្គង មេឃុំ ចៅសង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សា ហើយក្រុមប្រឹក្សា អញ្ជើញសាមីខ្លួនមកទទួលការណែនាំ ដោយមានការចុះក្នុងកំណត់ហេតុនៃកិច្ចប្រជុំ។

- ក្រោយពីទទួលការណែនាំហើយសាមីខ្លួនមិនរាងចាល មេឃុំ ចៅសង្កាត់ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់ និង សុំឲ្យក្រុមប្រឹក្សាសម្រេចបញ្ឈប់ជននោះពីមុខតំណែង តាមសំឡេងលើសពីពាក់កណ្ដាល នៃក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។
- ករណីមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ បាត់បង់ពីមុខតំណែងតាមករណីណាមួយ ខាងលើ ក្រុមប្រឹក្សាត្រូវធ្វើការជ្រើសរើសបេក្ខជនសម្រាប់កន្លែងដែលទំនេរ ឲ្យក្រុមប្រឹក្សា ពិនិត្យ និងអនុម័តក្នុងរយៈពេល៧ ថ្ងៃយ៉ាងយូរ។

ដោយយោងទៅតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មាត្រា៣០ និងមាត្រា៣១ បានចែងថា ក្រុមប្រឹក្សាឃុំ សង្កាត់ រៀបចំជ្រើសរើសឲ្យមានមេភូមិ ហើយមេភូមិត្រូវរៀបចំឲ្យមានអនុប្រធានភូមិ និងសមាជិកភូមិ១រូបជាជំនួយការ។ ដូចនេះមេភូមិគ្រាន់តែជាជំនួយការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ គ្មានការកំណត់អាណត្តិទេ ហើយមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ មិនបានបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋនោះទេ។ តើដំណើរការអនុវត្ត និងនីតិវិធី នៅក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់មានការប្រព្រឹត្តយ៉ាងដូចម្ដេច?

ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឲ្យមានមេភូមិម្នាក់ សម្រាប់ភូមិនីមួយៗក្នុងឃុំ សង្កាត់របស់ខ្លួន។ មេភូមិត្រូវមានតួនាទីភារកិច្ចដូចខាងក្រោម៖

- ជាតំណាងឲ្យប្រជាពលរដ្ឋទាំងអស់ក្នុងភូមិ
- ជាអ្នកទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់
- ទទួលការណែនាំ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់
- ចូលរួមក្នុងកិច្ចប្រជុំនានារបស់ឃុំ សង្កាត់នៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់តម្រូវដើម្បីផ្ដល់យោបល់អំពីកិច្ចការពាក់ព័ន្ធនឹងកំហុសរបស់ខ្លួន
- ធ្វើសេចក្ដីរាយការណ៍រួមបញ្ហាដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួនដើម្បីដាក់ជូនរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្ដល់ព័ត៌មានដែលពាក់ព័ន្ធហ្នឹងរហូតដល់ប្រជាជនប្រជាពលរដ្ឋរបស់ខ្លួន
- ទទួលខុសត្រូវចំពោះ ព្រឹត្តិការណ៍ដែលបានប្រគល់ឲ្យក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។

## ៣.៣. តួនាទី ភារកិច្ច

ក្រុមប្រឹក្សាឃុំ សង្កាត់ មានតួនាទី ជំរុញ និងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានា ដែលមានប្រកបដោយចីរភាព សម្រាប់បំពេញសេចក្ដីត្រូវការជាមូលដ្ឋាន ក្នុងឃុំ សង្កាត់របស់ខ្លួន បម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍ជាតិ ស្របតាមគោលនយោបាយទូទៅរបស់រដ្ឋ។

ហើយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានផ្ទេរឲ្យនូវ តួនាទី មុខងារ និងអំណាចមួយចំនួនសម្រាប់បម្រើប្រជាពលរដ្ឋ និងការអភិវឌ្ឍនៅមូលដ្ឋានរបស់ខ្លួន។

រដ្ឋបាលឃុំ សង្កាត់ មានតួនាទី ពីរប្រភេទគឺ៖ តួនាទីបម្រើកិច្ចការមូលដ្ឋានសម្រាប់បម្រើផលប្រយោជន៍ឃុំ សង្កាត់ និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។

### ៣.៣.១. ក្នុងឋានៈតំណាងឲ្យរាស្ត្រប្រជា

**តួនាទីបម្រើកិច្ចការមូលដ្ឋាន (ជាអ្នកតំណាងឲ្យប្រជាជននៅមូលដ្ឋាន)**[20] គឺធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ។ ហើយរៀបចំចាត់ចែងសេវាសាធារណៈ និងមើលការខុសត្រូវឲ្យកិច្ចការទាំងនោះដំណើរការបានល្អ។ លើសពីនេះទៅទៀតជំរុញយ៉ាងសកម្មនូវកិច្ចអភិវឌ្ឍឃុំ សង្កាត់ និងសុខុមាលភាព។ ជាពិសេសប្រើប្រាស់ធនធានឲ្យបានត្រឹមត្រូវ ដើម្បីបម្រើឲ្យសេចក្តីត្រូវការរបស់ឃុំ សង្កាត់ និងប្រជាជន។ ហើយមានភារកិច្ចបម្រើកិច្ចការនៅមូលដ្ឋាន ដូចជាគ្រប់គ្រងសេវាសាធារណៈដើម្បីឆ្លើយតបទៅ និងសេចក្តីត្រូវការរបស់ប្រជាជននៅក្នុងមូលដ្ឋានឲ្យបានត្រឹមត្រូវ។ លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ នៅក្នុងមូលដ្ឋាន និងជំរុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងសម្របសម្រួលកិច្ចសហប្រតិបត្តិការល្អ ជាមួយអង្គការសង្គមស៊ីវិលផ្សេងៗ និងជួយដោះស្រាយរាល់បាតុភូតនានា ដែលជាទំនាស់កើតមានឡើងក្នុងចំណោមប្រជាជននៅក្នុងមូលដ្ឋានរបស់ខ្លួន។

នៅក្នុងតួនាទីខាងលើនេះ ក្រុមប្រឹក្សាអាចធ្វើប្រតិភូកម្មអំណាច ទៅឲ្យមេឃុំ ចៅសង្កាត់ ជាអ្នកអនុវត្តផ្ទាល់បាន។ តែក្នុងករណីមានការដកមកវិញនូវអំណាចប្រតិភូកម្មនេះ គឺមិនអាចធ្វើឲ្យប៉ះពាល់ដល់សុពលភាពនៃកិច្ចការទាំងឡាយ ដែលបានធ្វើរួចហើយនោះទេ។ ហើយការធ្វើបែបនេះ ដើម្បីធានា នូវប្រក្រតីភាពការងាររដ្ឋបាល ហើយមេឃុំ ចៅសង្កាត់ក៏ត្រូវតែទទួលខុសត្រូវចំពោះមុខ ក្រុមប្រឹក្សាឃុំ សង្កាត់ផងដែរ។

រដ្ឋបាលឃុំសង្កាត់មានភារៈកិច្ច៖

- ធានារក្សាសន្តិសុខសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់នៅក្នុងការមើលការខុសត្រូវឲ្យកិច្ចការទាំងនោះដំណើរការបានល្អ
- ការលើកទឹកចិត្តឲ្យមានការបង្កើនផលសុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ

[20] មាត្រា៦១ អនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរមជ្ឈការអំណាច តួនាទី និងភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់

- ជំរុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌បេតិកភណ្ឌជាតិ
- សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឲ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក
- បំពេញកិច្ចការទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ

### ៣.៣.២. ក្នុងឋានៈតំណាងឲ្យរដ្ឋ

**តួនាទីជាភ្នាក់ងារតំណាងរដ្ឋ**[21] គឺក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្តតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានា។ ហើយក្រុមប្រឹក្សាមានសិទ្ធិសម្រេចលើបញ្ហានានា ដូចជាអនុម័តលើគម្រោងផែនការអភិវឌ្ឍឃុំ សង្កាត់ និងអនុម័តលើគម្រោងថវិកាឃុំ សង្កាត់។ លើសពីនេះទៅទៀតអនុម័តបទបញ្ជាផ្ទៃក្នុង និងដីកាឃុំ សង្កាត់ និងកិច្ចការផ្សេងៗទៀតដែលកំណត់ដោយរដ្ឋ

មន្ត្រីក្រសួងមហាផ្ទៃ។ ក្រុមប្រឹក្សាឃុំ សង្កាត់អាចទទួលប្រតិភូកម្ម អំណាចពី ក្រសួង ស្ថាប័ននានាដើម្បីអនុវត្តការងារក្នុងនាមរដ្ឋ។ ក្នុងករណីនេះ អាជ្ញាធរអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាព និងផ្គត់ផ្គង់មធ្យោបាយ សម្ភារ ថវិកា សម្រាប់ការអនុវត្ត ឧទាហរណ៍ៈ ការចុះ ឈ្មោះអ្នកបោះឆ្នោតនៅក្នុងឃុំ សង្កាត់ជាដើម។

ដូចនេះ ការធ្វើវិមជ្ឈការនៅឃុំ សង្កាត់នេះ គឺឃុំ សង្កាត់មិនគ្រាន់តែមានតួនាទីបម្រើកិច្ចការមូលដ្ឋានរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែឃុំ សង្កាត់មានតួនាទីជាភ្នាក់ងារតំណាងរដ្ឋថែមទៀតផង។ ចាប់តាំងពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅថ្ងៃទី០២ កុម្ភៈ ឆ្នាំ២០០២ មកទល់ពេលបច្ចុប្បន្ននេះ មានរយៈពេលជាច្រើនឆ្នាំណាស់មកហើយដែរ ពាក្យថាច្រកចេញចូលតែមួយ សម្រាប់រដ្ឋបាលឃុំ សង្កាត់ គឺមិនទាន់មានការអនុវត្តនោះទេ។

ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង តួនាទី និងភារកិច្ចទាំងអស់នោះ គឺគ្រាន់តែមានចែងនៅក្នុងច្បាប់ប៉ុណ្ណោះ ពិតមែនថា ក្រុមប្រឹក្សាឃុំ សង្កាត់បានធ្វើការងាររបស់ខ្លួនយ៉ាងច្រើន តែទាំងអស់នោះនៅមិនទាន់ធនល្មមទៅនឹងស្ថានភាពជាក់ស្តែង ដែលមាននៅក្នុងមូលដ្ឋាននោះទេ។ ជាក់ស្តែងគេ អាចលើកយក ប្រធានបទមួយមកចោទជាបញ្ហាថា តើគ្រាន់តែការដោះស្រាយទំនាស់ដីធ្លីមាននៅក្នុងមូលដ្ឋាន ហើយអាជ្ញាធរបានដឹងយ៉ាងច្បាស់ ហេតុអ្វីបានជាពួកគេមិនអាចដោះស្រាយទៅបានអញ្ចឹង? តើអាជ្ញាធរមូលដ្ឋានពិតជាបម្រើដល់សេចក្តីសុខរបស់ប្រជាពលរដ្ឋបានទេ? តើប្រជាពលរដ្ឋអាចមានភាពកក់ក្តៅចំពោះអាជ្ញាធររបស់ខ្លួនបានដែរឬទេ?

[21] មាត្រា៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ទំនាស់ដីធ្លី ត្រូវបានកើតឡើងជាបន្តបន្ទាប់នៅមូលដ្ឋាន ដែលបញ្ហាទាំងនេះធ្វើឲ្យប្រជាពលរដ្ឋមានកង្វល់ និងពោលពេញទៅដោយការភ័យខ្លាច នៅពេលដែលមានបញ្ហាទំនាស់កើតឡើងចំពោះពួកគាត់។ ហើយវាជាភាពកំសោយមួយរបស់សមត្ថកិច្ចនៅតាមមូលដ្ឋាន ក្នុងការធានាឲ្យប្រជាពលរដ្ឋ រស់នៅដោយសុខដុមរមនាទេ។ ជាទូទៅ ប្រជាពលរដ្ឋដែលរស់នៅលើដីធ្លី គឺតែងតែមានការដឹងឮពីអាជ្ញាធរ នៅតាមមូលដ្ឋានរបស់ពួកគាត់ ប៉ុន្តែនៅពេលដែលមានបញ្ហាកើតឡើង ចំពោះរាស្ត្រប្រជា អាជ្ញាធរមានសមត្ថកិច្ចហាក់មិនសូវអើពើ និងដោះស្រាយចំពោះបញ្ហានោះទេ គឺហាក់ដូចជាបង្ហាញ ថាពួកគាត់មិនបានដឹងឮអ្វីទាល់តែសោះ។

## ៣.៤.ការត្រួតពិនិត្យលើរដ្ឋបាលឃុំ សង្កាត់

### ៣.៤.១. ការត្រួតពិនិត្យលើអង្គការឃុំ សង្កាត់

- អភិបាលរាជធានី ខេត្តទទួលបានប្រតិភូកម្មអំណាចពីរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្នុងការតាមដាន ការត្រួតពិនិត្យ និងការគាំទ្រលើការប្រើប្រាស់អំណាច និងការបំពេញតួនាទី ភារកិច្ចរបស់រដ្ឋបាលឃុំ សង្កាត់ រួមទាំងការពិនិត្យនីត្យានុកូលភាពលើដីកា និងសេចក្តីសម្រេចរបស់ រដ្ឋបាលឃុំ សង្កាត់ ។
- ឃុំ សង្កាត់ណាដែលមិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើអន្តរាគមន៍ដើម្បីឲ្យមាន ការបំពេញភារកិច្ចដែលច្បាប់បានតម្រូវនោះជាបន្ទាន់ ។
- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានសិទ្ធិរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ (មាត្រា៥៧ និង៥៨ នៃច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់)

  ក្នុងករណីៈ
- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃធ្វើអន្តរាគមន៍ហើយ តែមិនទទួលបានលទ្ធផលចំពោះភារកិច្ចដែលច្បាប់បានតម្រូវក្នុងអំឡុងពេល ៦ខែ ហើយភារកិច្ចដែលច្បាប់បានតម្រូវនោះជាទូទៅក្រុមប្រឹក្សាឃុំ សង្កាត់នោះមិនអាចបំពេញបាន
- ក្រុមប្រឹក្សាឃុំ សង្កាត់ មិនត្រូវធ្វើសកម្មភាពផ្ទុយពីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងនយោបាយរបស់រដ្ឋាភិបាល

### ៣.៤.២. ការត្រួតពិនិត្យលើសេចក្តីសម្រេច

សេចក្តីសម្រេចឃុំ សង្កាត់ គឺជាបទដ្ឋានគតិយុត្តដែលបង្កើតឡើង ដើម្បីអនុវត្តដីការបស់ខ្លួន ឬលិខិតបទដ្ឋាននានារបស់រដ្ឋ ឬចែងអំពី ការបង្កើត ការតែងតាំងការរៀបចំ ឬការគ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចអនុវត្តក្នុងរង្វង់ដែនដីរបស់ខ្លួន ។[22]

[22] ក្រសួងមហាផ្ទៃ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ ទំព័រ២១

សេចក្តីសម្រេចមានលក្ខណៈប្រហាក់ប្រហែល និងដីកាឃុំ សង្កាត់ដែរ ប៉ុន្តែមានឋានានុក្រមទាបជាងដីកា និងខ្ពស់ជាងលិខិតរដ្ឋបាលសាមញ្ញធម្មតាផ្សេងៗទៀតក្នុងឃុំ សង្កាត់។

សេចក្តីសម្រេចឃុំ សង្កាត់ មិនត្រូវផ្ទុយនិងច្បាប់ និងលិខិតបទដ្ឋាននានា និងដីកា របស់ខ្លួនឡើយ។ សេចក្តីសម្រេចឃុំ សង្កាត់ត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។

ក្នុងករណីប្រធានសក្តិ និងបន្ទាន់បំផុតដែលមិនអាចកោះប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បាន មេឃុំ ចៅសង្កាត់ អាចចេញសេចក្តីសម្រេច ដើម្បីដោះស្រាយស្ថានភាពបន្ទាន់នោះ ។ សេចក្តីសម្រេចនេះ និងត្រូវបានដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់នៅកិច្ចប្រជុំបន្ទាប់ ដើម្បីពិនិត្យឡើងវិញអំពីភាពត្រឹមត្រូវ តាមច្បាប់ ។

# ជំពូកទី៤
# បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី៤
# បញ្ហាប្រឈម និងដំណោះស្រាយ

## ៤.១ បញ្ហាប្រឈម

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះ រដ្ឋបាលឃុំ សង្កាត់បានដំណើរការតាមបែបប្រព័ន្ធ វិមជ្ឈការ។ ហើយវិមជ្ឈការ នៅថ្នាក់ឃុំ សង្កាត់នេះ និងនាំមកនូវវិបត្តិមួយចំនួនដូចជា ៖

### ៤.១.១ ការចូលរួម និងភាពជាម្ចាស់

ការពិគ្រោះយោបល់ និងការការចូលរួម គឺជាគោលការណ៍មួយក្នុងចំណោម គោលការណ៍ទាំង៩ ក្នុងការអនុវត្តតាមបែបប្រជាធិបតេយ្យ។ កន្លងមកទោះបីជាមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំងពីគ្រប់អ្នកពាក់ព័ន្ធ រួមទាំងក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការផ្សព្វផ្សាយតាមរូបភាពណាក៏ដោយ ក៏ការចូលរួមនៅកិច្ចការក្នុងមូលដ្ឋាននៅមានកម្រិតនៅឡើយ ពិសេស ជនក្រីក្រ ស្ត្រី យុវជន និងជនងាយរងគ្រោះ ជនជាតិដើមភាគតិចក្នុងការចូលរួមក្នុងការលើកឡើងនូវបញ្ហា និងតម្រូវការជាអាទិភាពរបស់ខ្លួនសម្រាប់ដាក់ចូលក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលឃុំ សង្កាត់ ដើម្បីធានានូវការដោះស្រាយបញ្ហា និងតម្រូវការទាំងនោះ ។

### ៤.១.២ ធនធានហិរញ្ញវត្ថុ

ក្រុមប្រឹក្សាឃុំ សង្កាត់ទទួលបានចំណូល តែពីប្រភពមូលនិធិឃុំ សង្កាត់ ពីប្រភពទុនចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងប្រភពដៃគូរអភិវឌ្ឍតាមរយៈគម្រោង កម្មវិធីនានាប៉ុណ្ណោះ។ ចំណូលផ្ទាល់ដែលរួមមានប្រភពចំណូលសារពើពន្ធ ប្រភពចំណូលមិនមែនសារពើពន្ធ និងកម្រៃសេវាផ្សេងៗនៅមិនទាន់មានការសិក្សា និងពិចារណានៅឡើយ។ ទន្ទឹមនេះក្រុមប្រឹក្សាឃុំ សង្កាត់មិនទាន់ទទួលបានចំណូលណាមួយសម្រាប់ការអនុវត្តមុខងារជាជម្រើសនានានៅឡើយ ក្រៅពីថវិកាប្រតិបត្តិការដែលស្ថិតក្រោមថវិកាឃុំ សង្កាត់។ បញ្ហាទាំងនេះមានការស្មុកស្មាញដែលទាមទារឲ្យមានការសិក្សាស៊ីជម្រៅ និងមានការឯកភាពគ្នាក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងរាជរដ្ឋាភិបាល។ អវត្តមាននៃប្រភពចំណូលផ្ទាល់របស់ឃុំ សង្កាត់វានឹងធ្វើឲ្យប៉ះពាល់ដល់ប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលឃុំ សង្កាត់ដែលជាគ្រឹះនៃប្រជាធិបតេយ្យ។

### ៤.១.៣ ធនធានមនុស្ស និងការអភិវឌ្ឍសមត្ថភាព

បន្ទាប់ពីរៀបចំរចនាសម្ព័ន្ធថ្មីស្របតាមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់មន្ត្រីទាំងអស់ទាមទារឲ្យមានវិជ្ជាជីវៈច្បាស់លាស់ ដើម្បីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តការងារស្របទៅតាមអាណត្តិរបស់ខ្លួន។ ដោយសារនៅថ្នាក់ឃុំ សង្កាត់មានតែបុគ្គលិកម្នាក់គត់គឺ ស្មៀនឃុំ សង្កាត់ ហេតុការបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាពកន្លងមក ត្រូវបានធ្វើឡើងសម្រាប់ទាំងក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់។

ដូចនេះហើយនៅរាល់អាណត្តិថ្មីនៃក្រុមប្រឹក្សាឃុំ សង្កាត់ការបណ្តុះបណ្តាលឡើងវិញគឺប្រការចៀសមិនផុត ដែលធ្វើឲ្យរាជរដ្ឋាភិបាលត្រូវប្រើប្រាស់ធនធានជាច្រើន ទៅលើការអភិវឌ្ឍសមត្ថភាព។

### ៤.១.៤ ប្រព័ន្ធ និងរចនាសម្ព័ន្ធ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បានតម្រូវឲ្យមានការរៀបចំរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ ដែលមានសិទ្ធិអំណាច ស្វ័យភាពការទទួលខុសត្រូវ មុខងារ ធនធាន និងសមត្ថភាព សមស្របដើម្បីដោះស្រាយសេចក្តីត្រូវការ និងការអនុវត្តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ប៉ុន្តែការអនុវត្តតាមបែបវិមជ្ឈការនេះ រាជរដ្ឋាភិបាល បានរៀបចំប្រព័ន្ធ និងរចនាសម្ព័ន្ធសម្រាប់រដ្ឋបាលឃុំ សង្កាត់ក៏ពិតមែន ក៏ប្រព័ន្ធ និងរចនាសម្ព័ន្ធនេះមិនទាន់ដំណើរការដោយរលូន និងប្រកបដោយប្រសិទ្ធភាពនៅឡើយទេ។ លើសពីនេះទៅទៀតប្រព័ន្ធកសាងផែនការ និងប្រព័ន្ធរៀបចំផែនការនៅមិនទាន់ស៊ីសង្វាក់គ្នា ដែលទាមទារឲ្យមានការពិនិត្យ និងកែសម្រួលឲ្យបានសមស្រប។ ហើយប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងប្រព័ន្ធតាមដាន និងវាយតម្លៃរួមទាំងប្រព័ន្ធរបាយការណ៍នៅមិនទាន់បានរៀបចំនៅ ឡើយ។

## ៤.២ ដំណោះស្រាយ

### ៤.២.១ ការចូលរួម និងភាពជាម្ចាស់

យើងត្រូវតែយកចិត្តទុកដាក់បន្ថែមទៀតដល់ការជំរុញលើកទឹកចិត្តឲ្យស្ត្រី និង ជនងាយរងគ្រោះបានលើកបញ្ហាតម្រូវការចាំបាច់ជាក់ស្តែង របស់ពួកគាត់ នៅពេលដែលចូលរួមលើកមតិយោបល់នៅក្នុងអង្គប្រជុំ។ ជាពិសេសកិច្ចប្រជុំប្រចាំខែ របស់ក្រុមប្រឹក្សាគួរចល័ត ការប្រជុំតាមភូមិ (ឧទាហរណ៍ៈ ខែមករា នៅភូមិ "ក" និង ខែកុម្ភៈ នៅភូមិ "ខ" ដើម្បីងាយស្រួលដល់ប្រជាពលរដ្ឋចូលរួម ហើយត្រូវអញ្ជើញជនបង្គោល អ្នកពាក់ព័ន្ធផ្សេង និងប្រជាពលរដ្ឋ ចាស់ព្រឹទ្ធាចារ្យបានចូលរួមស្តាប់ និងផ្តល់យោបល់ដល់អង្គប្រជុំ ដើម្បីដឹងច្បាស់ និងទទួលយកអនុសាសន៍ ពីបញ្ហាប្រឈមនានាដែលបានកើតឡើងនៅក្នុងមូលដ្ឋាន ដើម្បីងាយស្រួលក្នុងការ ដោះស្រាយចាត់វិធានការទាន់ពេលវេលា និងចំគោលដៅច្បាស់លាស់។

### ៤.២.២ ធនធានហិរញ្ញវត្ថុ

- ត្រូវរៀបចំឲ្យមានប្រភពចំណូលផ្ទាល់នៃថវិកាឃុំ សង្កាត់ តាមរយៈការរៀបចំលិខិតបទដ្ឋានគតិយុត្តចាំបាច់នានាសម្រាប់ឃុំ សង្កាត់ដើម្បីឲ្យមានភាពសមាមាត្រគ្នា។
- ពង្រឹងការប្រមូល ការគ្រប់គ្រង និងការចាត់ចែង ប្រភពចំណូលពីសោហ៊ុយ និងការអនុវត្ត។
- ការងារ ជាភ្នាក់ងារ របស់ឃុំ សង្កាត់លើមូលដ្ឋាននៃការសិក្សាពិចារណា មុខងារភ្នាក់ងារដែលបានធ្វើប្រតិភូកម្មកន្លងមក និងការធ្វើប្រតិភូកម្មមួយចំនួនទៀតបន្ថែម។

- ពង្រឹងសមត្ថភាពរបស់ឃុំ សង្កាត់ក្នុងការរៀបចំ ការអនុម័ត និងការអនុវត្តថវិកា របស់ខ្លួនឲ្យមាន តម្លាភាព គណនេយ្យភាព នៅក្នុងភារកិច្ចការងាររបស់ខ្លួន។
- ដំណើរកសាងសាលាឃុំ សង្កាត់ និងការបំពាក់មធ្យោបាយសម្ភារៈ ធ្វើការរបស់ឃុំ សង្កាត់តាមជំហានៗដែលបានកំណត់ ដើម្បីធានានូវប្រសិទ្ធភាពការងារ។

### ៤.២.៣ ធនធានមនុស្ស និងការអភិវឌ្ឍសមត្ថភាព

បង្កើតឲ្យមានការរៀបចំយុត្តិសាស្ត្រសម្រាប់ការបណ្តុះបណ្តាល ដោយឈរលើមូលដ្ឋាននៃការត្រួតពិនិត្យ និងវាយតម្លៃ យ៉ាងច្បាស់លាស់អំពីការ វិវត្ត រីកចម្រើននៃសមត្ថភាពរបស់ឃុំ សង្កាត់

- រៀបចំបណ្តុះបណ្តាលមន្ត្រីសំខាន់ៗនៅថ្នាក់ឃុំ សង្កាត់
- រៀបចំយន្តការសមស្របសម្រាប់ការបង្កើនសមត្ថភាពគ្រប់ថ្នាក់អំពីវិមជ្ឈការ
- បង្កើនការអប់រំសាធារណៈជនឲ្យបានកាន់តែទូលំទូលាយថែមទៀត
- រៀបចំធ្វើអត្ថបទណែនាំ សៀវភៅកាន់ដៃអំពីរដ្ឋបាលមូលដ្ឋាន និងសន្ទានុក្រម ដែលលើកឡើងអំពីគោលការណ៍សំខាន់ៗនៃអភិបាលកិច្ចឃុំ សង្កាត់ដោយភាសាសាមញ្ញ ខ្លី ងាយយល់ ដោយឈរលើមូលដ្ឋានច្បាប់ ដើម្បីងាយស្រួលឲ្យថ្នាក់មូលដ្ឋានធ្វើស្វ័យសិក្សា ស្វែងយល់ និងអនុវត្ត គោលនយោបាយឲ្យមានប្រសិទ្ធភាព។

### ៤.២.៤ ប្រព័ន្ធ និងរចនាសម្ព័ន្ធ

ជំរុញឲ្យមានការយកចិត្តទុកដាក់បន្ថែមទៀតដល់ការពង្រឹងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឲ្យក្លាយជារដ្ឋបាលមូលដ្ឋានថ្មីមួយទៀត សម្តៅលើកកម្ពស់កិច្ចសហប្រតិបត្តិការ របស់ឃុំ សង្កាត់ក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានឲ្យបានកាន់តែទូលំទូលាយ និងប្រកបដោយប្រសិទ្ធភាព ព្រោះរដ្ឋបាលទាំងនោះអាចមានលទ្ធភាពម្ចាស់ការ បំពេញការងាររបស់ខ្លួនដោយ ខ្លួនឯងបានជាជំហានៗ

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សាលាឃុំ សង្កាត់ដែលជាទីកន្លែងធ្វើការរបស់មន្ត្រីមូលដ្ឋានថ្នាក់ក្រោមជាតិនាពេលបច្ចុប្បន្ន។ រាជរដ្ឋាភិបាលកម្ពុជាបានវិនិយោគទាំងធនធានមនុស្ស និងថវិកាជាច្រើនដើម្បីជំរុញកម្ពុជាបោះជំហានទៅមុខជាមួយនឹងក្តីសង្ឃឹម និងទំនុកចិត្តនៅក្នុងដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានចាប់ផ្តើមតាំងពីឆ្នាំ ២០០២ ជាពិសេសការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ការអនុវត្តតាមបែបវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ គឺជាកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ហើយវាមានគោលបំណងផ្តល់នូវសិទ្ធិអំណាចដល់ប្រជាពលរដ្ឋ សហគមន៍មូលដ្ឋាន ជាពិសេសក្រុមដែលតំណាងឲ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងក្រុមជនងាយរងគ្រោះនានាអាចមានសិទ្ធិចូលរួមពង្រឹងការចាត់ចែង ការប្រើប្រាស់ថវិកា និងការផ្តល់សេវាសាធារណៈនៅមូលដ្ឋានឲ្យមានប្រសិទ្ធភាព តាមរយៈការលើកកម្ពស់នូវភាពងាយទទួលបានព័ត៌មាន និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការពិនិត្យតាមដានលើការងារ ថវិកា និងការបំពេញការងាររបស់រដ្ឋបាលនៅមូលដ្ឋាន ហើយវាក៏ជាដំណើរការ នៃការផ្សារភ្ជាប់ទំនាក់ទំនងដ៏ល្អប្រសើររវាងប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់មូលដ្ឋានផងដែរ។ លើសពីនេះទៅទៀតវាក៏ជាមធ្យោបាយមួយដែលបន្សុីគ្នារវាង គោលការណ៍ទាំងឡាយ នៃអភិបាលកិច្ច ដែលក្នុងនោះរាល់ការធ្វើ សេចក្តីសម្រេចចិត្ត និងការអនុវត្តសកម្មភាពជាសាធារណៈនានារបស់រដ្ឋបាលឃុំ សង្កាត់ ត្រូវបានប្រកាន់យកតាមកិច្ចដំណើរតាមបែបប្រជាធិបតេយ្យ ហើយជាទូទៅ កិច្ចដំណើរការនេះ រួមមានរាល់សកម្មភាពទាំងឡាយណាដែលផ្តល់ឱកាសឲ្យប្រជាពលរដ្ឋ និងតំណាងរបស់ខ្លួនអាចការពារនូវផលប្រយោជន៍របស់ខ្លួន និងពិនិត្យតាមដានលើការបំពេញការងាររបស់ក្រុមប្រឹក្សា មន្ត្រីរដ្ឋបាល និងអ្នកផ្តល់សេវាកម្មនានាដែលជាអ្នកអនុវត្តសេចក្តីសម្រេចចិត្តទាំងឡាយពាក់ព័ន្ធ សិទ្ធិ និងធនធាន ហើយការផ្តល់សេវាកម្មនៅមូលដ្ឋានគឺត្រូវតែសមស្របទៅតាមតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន។ ជាពិសេសការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ឃុំ សង្កាត់ តាមបែបវិមជ្ឈការ គឺជាការរៀបចំនូវយន្តការនានានៃការប្រាស្រ័យទាក់ទងគ្នាដ៏ច្បាស់លាស់ និងមានប្រសិទ្ធភាពរវាងតួអង្គចំនួនពីរក្រុម ពោលគឺ ក្រុមប្រជាពលរដ្ឋ និងក្រុមរដ្ឋបាលឃុំ សង្កាត់ ដែលត្រូវមានការឆ្លើយតប និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។

ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ឃុំ សង្កាត់ គឺជាចលនាមួយយ៉ាងសំខាន់ក្នុងការចូលរួមផ្តល់មតិយោបល់រៀបចំផែនការ ផ្សព្វផ្សាយនូវគោលការណ៍ និងអនុវត្តផែនការ យ៉ាងមានប្រសិទ្ធភាព និងតម្លាភាពពីព្រោះពួកគាត់នៅជាប់ជាមួយប្រជាពលរដ្ឋ គាត់ដឹងនូវរាល់បញ្ហាដែលកើតមានឡើងក្នុងឃុំ សង្កាត់ របស់គាត់។ ដូចនេះ បើមូលដ្ឋានគ្រឹះរឹងមាំ វានឹងនាំជាតិរឹងមាំ គឺដោយសារប្រជាជនគ្រប់រូបមាន គុណធម៌ សីលធម៌ សេចក្តីថ្លៃថ្នូរ ចូលរួមបំពេញភារកិច្ច កាតព្វកិច្ច ឲ្យបានពេញលេញនៅក្នុងមូលដ្ឋានរបស់ខ្លួន ហើយចំណុចចាប់

ផ្តើមដើម្បីឈានទៅរកភាពជោគជ័យនៅមូលដ្ឋាន គឺផ្តើមចេញពីខ្លួនយើងម្នាក់ៗ ព្រោះប្រជាពលរដ្ឋ មិនចូលរួមនៅក្នុងដំណើរការអភិវឌ្ឍនៅមូលដ្ឋានទេ គឺគ្មានថ្ងៃឃុំ សង្កាត់ និងប្រទេសជាតិមានការរីកចម្រើន និងអភិវឌ្ឍន៍ទៅមុខបានលឿនឡើយ។

ជារួមការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិឃុំ សង្កាត់តាមបែបវិមជ្ឈការ ប្រាកដជាផ្តល់នូវផលប្រយោជន៍ដ៏មហាសាលដល់ ប្រជាជនកម្ពុជា ព្រោះថានេះជានយោបាយតែទម្រង់ដ៏ល្អមួយរបស់រាជរដ្ឋាភិបាល សំដៅពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ហើយក៏មានការលើកកម្ពស់ការចូលរួម និងភាពជាម្ចាស់នៅមូលដ្ឋាន។ ជាពិសេសការចូលរួមចំណែកក្នុងការអនុវត្តគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ដំណើរការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិឃុំ សង្កាត់តាមបែបវិមជ្ឈការនេះ ទោះជាមានអត្ថប្រយោជន៍ជាច្រើន ប៉ុន្តែវាក៏មានបញ្ហាមួយចំនួន ដែលត្រូវយកមកសិក្សាផងដែរ ព្រោះវាប៉ះពាល់ការអនុវត្តនៅក្នុងឃុំ សង្កាត់។ លិខិតបទដ្ឋានគតិយុត្តជាច្រើនត្រូវបានរៀបចំ និងដាក់ឲ្យប្រើប្រាស់ក៏ ពិតមែន ប៉ុន្តែនៅខ្វះខាតលិខិតបទដ្ឋានគតិយុត្តចាំបាច់មួយចំនួនទៀត ដូចជា យុទ្ធសាស្ត្រស្តីពីការផ្ទេរមុខងារដល់ រដ្ឋបាលឃុំ សង្កាត់ យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលឃុំ សង្កាត់លក្ខន្តិកៈដោយឡែកសម្រាប់គ្រប់គ្រងបុគ្គលិក រដ្ឋបាលឃុំ សង្កាត់ គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធ និងការប្រមូលចំណូលរបស់ឃុំ សង្កាត់។ ទន្ទឹមនេះ លិខិតមួយចំនួនមិន ទាន់ស៊ីសង្វាក់ និងមិនទាន់ស្របតាមគោលនយោបាយវិមជ្ឈការឃុំ សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ លើសពីនេះទៅទៀតក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់មិនសូវយកចិត្តទុកដាក់ខ្ពស់រាល់បាតុភាព និងបណ្តឹងគ្រប់ប្រភេទ របស់ប្រជាពលរដ្ឋទេ និងធ្វើការសម្រុះសម្រួលដោះស្រាយទំនាស់ដោយមានការអូសបន្លាយពេលវេលា និងធ្វើឲ្យទំនាស់នោះមានសភាពធ្ងន់ធ្ងរឡើងៗ។ ចំណែក ការប្រជុំរបស់ក្រុមប្រឹក្សា នៅតាមភូមិនានាមួយៗ គឺមានលក្ខណៈមិនទៀងទាត់នោះទេ ដែលធ្វើឲ្យ ប្រជាពលរដ្ឋពិបាកក្នុងការបង្ហាញពី ឬលើកឡើងពីតម្រូវការ និងផលវិបាករបស់ខ្លួនដើម្បីឲ្យមានការដោះស្រាយជូនពួកគាត់ ជាពិសេសគម្រោងអភិវឌ្ឍឃុំ សង្កាត់ មិនសូវទទួលបានលទ្ធផលល្អ ព្រោះមិនមានការផ្តល់ការស្នង់មតិរបស់ប្រជាពលរដ្ឋទាក់ទងទៅ និងការអភិវឌ្ឍនោះ ដោយសារតែប្រជាពលរដ្ឋ គឺជាអ្នកពាក់ព័ន្ធ និងទទួលនូវសេវាទាំងអស់នោះ។

# អនុសាសន៍

# អនុសាសន៍

ដោយផ្អែកលើលទ្ធផលខាងលើដែលស្ថិតនៅក្នុងសេចក្តីសន្និដ្ឋាន ហេតុដូចនេះក្នុងនាមអ្នកស្រាវជ្រាវ សុំលើកនូវសំណូមពរមួយចំនួនដូចជា ៖

- បង្កើតច្បាប់ ឬចេញអនុក្រឹត្យ ស្តីពីការប្រមូលចំណូលពន្ធដោយផ្ទាល់របស់ឃុំ សង្កាត់។
- ជំរុញឲ្យមានការប្រជុំចល័តជាមួយប្រជាពលរដ្ឋនៅតាមភូមិនីមួយៗប្រចាំខែឲ្យទៀងទាត់។
- បង្កើនការដោះស្រាយវិវាទជូនប្រជាពលរដ្ឋនៅពេលដែលមានវិវាទ។
- ផ្ទេរនូវសិទ្ធិអំណាចជាច្រើនទៀតដល់ឃុំ សង្កាត់ដែលជាប្រយោជន៍ដល់ប្រជាពលរដ្ឋ។
- មន្ត្រីត្រូវតែប្រកាន់ឥរិយាបថថាខ្លួនជាអ្នកបម្រើដល់ប្រជាពលរដ្ឋ។
- មានលក្ខណៈដោយឡែកសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាល។
- អភិវឌ្ឍន៍សមត្ថភាពបុគ្គលិករដ្ឋបាលឃុំ សង្កាត់ឲ្យទាន់បច្ចុប្បន្នភាព។
- រាល់សំណូមពររបស់ប្រជាពលរដ្ឋត្រូវតែមានការឆ្លើយតប។
- ផ្តល់ឱកាសឲ្យប្រជាពលរដ្ឋបានលើកឡើងនូវបញ្ហា និងតម្រូវការរបស់ពួកគាត់នៅពេលប្រជុំ។
- ត្រូវមានការស្ទង់មតិរបស់ប្រជាពលរដ្ឋជាមុនសិនមុន និងសម្រេចគម្រោងអភិវឌ្ឍឃុំ សង្កាត់។
- ពង្រឹង និងបង្កើនសមត្ថភាពរបស់បន្ត្រីនៅក្នុងរដ្ឋបាលឃុំ សង្កាត់ដើម្បីឲ្យការបំពេញការងារ និងតួនាទីប្រកបដោយប្រសិទ្ធភាព។
- ជំរុញឲ្យមានវេទិកាសាធារណៈដើម្បីឲ្យប្រជាពលរដ្ឋបានលើកឡើងនូវតម្រូវការ និងបញ្ហាដែលពួកគាត់ជួបប្រទះ ដើម្បីរិះរកវិធានការដោះស្រាយជូនពួកគាត់

# ឯកសារយោង

# ឯកសារយោង

## ក. ច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃ២១ ខែកញ្ញា ឆ្នាំ១៩៩៣ ប្រកាសឲ្យប្រើនៅថ្ងៃ ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ។
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, នស/រកម/០៣០១/០៥, ១៩ មីនា ២០០១។
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់, នស/រកម/១២១៥/០១៥, ១៥ ធ្នូ ២០១៥។
- ព្រះរាជក្រឹត្យចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ១៩០៨។
- ព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩១៩។
- អនុក្រឹត្យស្តីពីមូលនិធិឃុំ សង្កាត់លេខ១៦ អនក្របក, ២៥ កុម្ភៈ ២០០២។
- អនុក្រឹត្យស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់លេខ ២២ អនក្របក២៥ មីនា ២០០២។


## ខ. សៀវភៅ និង បទបង្ហាញ


- សៀវភៅ ការគ្រប់គ្រងរដ្ឋបាលដែនដី របស់សាស្ត្រាចារ្យ ហៀង សាង និង អនុបណ្ឌិត ប៉េង ឆុង បោះពុម្ពលើកទី៣ ឆ្នាំ២០១៨
- សៀវភៅ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ របស់ក្រសួងមហាផ្ទៃបោះពុម្ព ខែកក្កដា ឆ្នាំ២០១៧។
- កៅ មុយថង. ២០១០. ការគ្រប់គ្រងរដ្ឋបាលដែនដី, បោះពុម្ពលើកទី១. ភ្នំពេញ៖ គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ។


## គ. គេហទំព័រ


- គេហទំព័រ https://km.m.wikipedia.org/wiki/ឃុំ_សង្កាត់នៃកម្ពុជា
- គេហទំព័រ https://data.opendevelopmentmekong.net/km/library_record/book-record-of-names-and-numbers-of-capital-province-municipality-district-khan-commune-sangkat-and
- គេហទំព័រ https://kohsantepheapdaily.com.kh/article/1390795.html

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១.ឧបសម្ព័ន្ធរូបភាព

- ឧបសម្ព័ន្ធទី១ ៖ ការកសាងហេដ្ឋារចនាសម្ព័ន្ធនៅតាមឃុំ សង្កាត់
- ឧបសម្ព័ន្ធទី២ ៖ ការផ្តល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋនៅតាមឃុំ សង្កាត់

## ២.ឧបសម្ព័ន្ធគតិយុត្តិ

- ឧបសម្ព័ន្ធទី១៖ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, នស/រកម/០៣០១/០៥, ១៩ មីនា ២០០១
- ឧបសម្ព័ន្ធទី២៖ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់, នស/រកម/១២១៥/០១៥, ១៥ ធ្នូ ២០១៥។
- ឧបសម្ព័ន្ធទី៣៖ អនុក្រឹត្យស្តីពីមូលនិធិឃុំ សង្កាត់លេខ១៦ អនក្របក, ២៥ កុម្ភៈ ២០០២។
- ឧបសម្ព័ន្ធទី៤៖ អនុក្រឹត្យស្តីពីការផ្ទេរិមជ្ឈការអំណាច តួនាទី និងភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់លេខ ២២ អនក្រុបក២៥ មីនា ២០០២។

# ឧបសម្ព័ន្ធរូបភាព












សកម្មភាពនៃការកសាងហេដ្ឋារចនាសម្ព័ន្ធនៅតាមឃុំ សង្កាត់








សកម្មភាពនៃការផ្តល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានឃុំ សង្កាត់

# ឧបសម្ព័ន្ធគតិយុត្ត

# ឧបសម្ព័ន្ធទី១

នស / រកម / ០៣០១ / ០៥

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤នៃរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ ពីសម្តេចនាយករដ្ឋមន្ត្រី និង ពីសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី០១ខែ កុម្ភៈ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី៤ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៤១/ ០០៣ / ២០០១ កបធ.ច ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ : ៚

# ច្បាប់

# ស្ដីពី

# ការគ្រប់គ្រងរដ្ឋបាល

# ឃុំ សង្កាត់

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាតាមនយោបាយវិមជ្ឈការ ។

**មាត្រា ២.-**

ឃុំ សង្កាត់ជានីតិបុគ្គល ។

**មាត្រា ៣.-**

ប្រព័ន្ធនៃអភិបាលកិច្ចមូលដ្ឋានត្រូវអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ។

**មាត្រា ៤.-**

អំណាចដឹកនាំនិងគ្រប់គ្រងឃុំ សង្កាត់បានមកដោយការបោះឆ្នោតជាទូទៅជាសកល ដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ក្នុងក្របខ័ណ្ឌនៃឃុំ សង្កាត់នីមួយៗ ។

**មាត្រា ៥.-**

ឃុំ សង្កាត់គ្រប់គ្រងកិច្ចការមូលដ្ឋានក្នុងដែនដីរបស់ខ្លួនដោយផ្អែកទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

អំណាចបញ្ញត្តិ អំណាចប្រតិបត្តិក្នុងការគ្រប់គ្រងមូលដ្ឋានត្រូវផ្តល់ឱ្យឃុំ សង្កាត់ ហើយអំណាចនេះត្រូវអនុវត្តស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ ។

**មាត្រា ៦.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ក្នុងករណីមិនប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ត្រូវសំរេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងករណីដែលមានការប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ត្រូវ៖

សំរេចដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ផ្អែកលើសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧.-**

កាលបើមានផលវិបាកណាមួយកើតឡើង ក្រោយពេលដែលឃុំ សង្កាត់ ត្រូវបានបង្កើត លុបចោលឬកែសម្រួល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសដើម្បីដោះស្រាយផលវិបាកនោះស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៨.-**

ឃុំ សង្កាត់ណាដែលមិនអាចដំណើរការរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានដោយករណីប្រធានសក្តិ រាជរដ្ឋាភិបាលត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា។

បន្ទាប់ពីបានរាយការណ៍ជូនរដ្ឋសភារួចហើយ រាជរដ្ឋាភិបាលត្រូវចាត់ឱ្យក្រសួងមហាផ្ទៃរៀបចំគ្រប់គ្រងឃុំ សង្កាត់ទាំងនោះជាបណ្តោះអាសន្ន ហើយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះនឹងត្រូវដំណើរការ នៅពេលស្ថានការណ៍ឃុំ សង្កាត់ទាំងនេះមានប្រក្រតីភាពឡើងវិញ ។

## ជំពូកទី ២
## ក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ៩.-**

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយហៅថាក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបំរើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ១០.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោត ដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនស្របទៅតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ល។

**មាត្រា ១១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង ។

ក្នុងតំណាក់កាលអន្តរកាលនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ដែលផុតអាណត្តិមានភារកិច្ចសំរួលកិច្ចការប្រចាំថ្ងៃតែប៉ុណ្ណោះ ។

**មាត្រា ១២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកចំនួនពី ៥ ទៅ ១១រូប ផ្អែកតាមប្រជាសាស្ត្រនិងភូមិសាស្ត្ររបស់ខ្លួន ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាតាមឃុំ សង្កាត់នីមួយៗត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានកំណត់រួចហើយ អាចធ្វើការផ្លាស់ប្តូរបានដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាស្រ័យដោយការផ្លាស់ប្តូរនៃប្រជាសាស្ត្រនិងភូមិសាស្ត្រ ។

សមាជិកបន្ថែមនៃក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសតាមនីតិវិធីដូចសមាជិកដទៃទៀតដែរ ។

**មាត្រា ១៣.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានម្នាក់ហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ច :

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ធានាឱ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ធានាឱ្យសម័យប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដំណើរការបានត្រឹមត្រូវទៅតាមវិធាននិងបទបញ្ជាដូចបានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ និងបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា២៣ នៃច្បាប់នេះ
- រក្សារបៀបរៀបរយនិងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ ។ល។

មាត្រា ១៤.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិនិងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញលក្ខខ័ណ្ឌសំខាន់ៗដូចខាងក្រោម :

- មានសញ្ជាតិខ្មែរពីកំណើត
- ចេះអាននិងសរសេរអក្សរខ្មែរ
- បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមលក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

មាត្រា ១៥.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ។

មាត្រា ១៦.-

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយក្នុងចំណោមករណីដូចខាងក្រោម :

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច
- សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ
- សមាជិកត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ តាមលក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៨៤នៃច្បាប់នេះ ៚

- ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលត្រូវរំសាយ

- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

កាលបើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយត្រូវបាត់បង់សមាជិកភាព ត្រូវជ្រើសរើសបេក្ខជនដែលមានឈ្មោះបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ ។

**មាត្រា ១៧.-**

ត្រូវរៀបចំធ្វើការបោះឆ្នោតឡើងវិញក្នុងរយៈពេល ១២០ថ្ងៃយ៉ាងយូរ ដើម្បីធ្វើការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីណាមួយដូចខាងក្រោម :

- ឃុំ សង្កាត់ដែលបង្កើតថ្មីតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរំសាយចោលតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៥៧ និងមាត្រា ៥៨ នៃច្បាប់នេះ ។

ការបោះឆ្នោតឡើងវិញដូចមានចែងខាងលើនេះត្រូវបាត់ចែងធ្វើឡើង អនុលោមទៅតាមបែបបទនិងនីតិវិធីដែលបានចែងក្នុងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះមានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានរយៈពេលមិនលើសពី ១៨០ថ្ងៃ ។

ក្នុងរយៈពេលនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវតែងតាំងសមាសភាពនិងកំណត់អំពីសមត្ថកិច្ច របៀបរបបដឹកនាំគ្រប់គ្រងឃុំ សង្កាត់នោះ រហូតដល់មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

**មាត្រា ១៨.-**

ការកែប្រែព្រំប្រទល់របស់ឃុំ សង្កាត់ណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការកែប្រែនោះ ពុំបណ្ដាលឱ្យផ្លាស់ប្ដូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ។ល។

ការបង្កើតឃុំ សង្កាត់ថ្មីណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការបង្កើតនោះពុំបណ្តាលឱ្យមានផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សានៃឃុំ សង្កាត់ដែលពាក់ព័ន្ធ ។

ក្នុងករណីឃុំ សង្កាត់ដែលត្រូវបង្កើតថ្មី ដែលត្រូវលុបចោល ដែលត្រូវកែប្រែព្រំប្រទល់ ហើយបណ្តាលឱ្យមានការផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ ត្រូវចូលជាធរមានសំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាអាណត្តិបន្ទាប់ ។

**មាត្រា ១៩.-**

ក្នុងអំឡុងពេល ១៤ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ត្រូវចាត់ឱ្យមានការប្រជុំជាលើកដំបូងនៃក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមអធិបតីភាពមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់និងប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់និងចៅសង្កាត់រង ។

**មាត្រា ២០.-**

មុនចាប់ផ្តើមការងារ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំនិងអនុម័តបទបញ្ជាផ្ទៃក្នុងដើម្បីកំណត់នូវវិធានទាំងឡាយសំរាប់អង្គប្រជុំនិងរបៀបរបបធ្វើការងាររបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីគោលការណ៍នានាសំរាប់ជាមូលដ្ឋានដល់ការរៀបចំបទបញ្ជាផ្ទៃក្នុងខាងលើនេះ ។

**មាត្រា ២១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំយ៉ាងតិចណាស់ចំនួនមួយដងក្នុងមួយខែ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំក្នុងសាលាឃុំ ឬសាលាសង្កាត់របស់ខ្លួន ឬក្នុងករណីចាំបាច់អធិបតីនៃអង្គប្រជុំអាចជ្រើសយកទីកន្លែងណាមួយក្នុងឃុំ សង្កាត់របស់ខ្លួនដើម្បីប្រជុំ ។ល។

**មាត្រា ២២.-**

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ នឹងយកជាការបាន លុះត្រាតែមានចំនួនលើស ពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលចូលរួម ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការបោះឆ្នោតអនុម័តដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាទាំងមូល ដើម្បីសំរេចបញ្ហាណាមួយដូចខាងក្រោម :

- អនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- អនុម័តលើគំរោងថវិកាឃុំ សង្កាត់
- កំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាននិងកំរៃសេវាផ្សេងៗ
- អនុម័តបទបញ្ញាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងពេលអនុម័ត ប្រសិនបើមានសំឡេងឆ្នោតស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព ។

**មាត្រា ២៣.-**

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើជាសាធារណៈនិងមានលក្ខណៈប្រជាធិបតេយ្យ ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រជុំជាសម្ងាត់បាន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីរបៀបរបបប្រជុំខាងលើនេះ ។

**មាត្រា ២៤.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានសេរីភាពក្នុងការបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បានឡើយ ។៚

# ជំពូកទី ៣
## រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

**មាត្រា ២៥.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ ។

**មាត្រា ២៦.-**

មេឃុំ ចៅសង្កាត់មានអ្នកជំនួយការដូចខាងក្រោម :

ចំពោះមេឃុំ អ្នកជំនួយការមានពីររូប :

-ជំទប់ទី ១ មួយរូប

-ជំទប់ទី ២ មួយរូប ។

ចំពោះចៅសង្កាត់ អ្នកជំនួយការមានពីររូប :

-ចៅសង្កាត់រងទី ១ មួយរូប

-ចៅសង្កាត់រងទី ២ មួយរូប ។

**មាត្រា ២៧.-**

មេឃុំ ចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានាដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានាតាមការចាំបាច់ ។

គណៈកម្មាធិការខាងលើនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឱ្យធ្វើជាប្រធានក៏បាន ។

**មាត្រា ២៨.-**

ឃុំ សង្កាត់ត្រូវមានបុគ្គលិកក្របខ័ណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃមួយរូបធ្វើជាស្មៀនឃុំ សង្កាត់ ។

ស្មៀនឃុំ សង្កាត់តែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលមានភារកិច្ចជួយកិច្ចការឃុំ សង្កាត់ និងធានានិរន្តរភាពកិច្ចការរដ្ឋបាលក្នុងឃុំ សង្កាត់ ។ល។

ស្មៀនឃុំ សង្កាត់ត្រូវផ្លាស់ប្តូរក្នុងករណីមានសំណើរបស់មេឃុំ ចៅសង្កាត់ អនុលោមតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២៩.-**

ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋដើម្បីជួយកិច្ចការរបស់ខ្លួន តាមសេចក្តីត្រូវការនិងការចាំបាច់នៃការងារនិងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់ ។

**មាត្រា ៣០.-**

ក្នុងគោលដៅលើកកំពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់ សំរាប់ភូមិនីមួយៗ ចំណុះឃុំ សង្កាត់របស់ខ្លួន ។

មេភូមិត្រូវរៀបចំចាត់តាំងឱ្យមានអនុប្រធានមួយរូបនិងសមាជិកមួយរូបជាជំនួយការ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិនិងការតែងតាំងជំនួយការមេភូមិ ។

**មាត្រា ៣១.-**

មេភូមិមានភារកិច្ច :

- អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ប្រគល់ឱ្យ ដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិ
- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិរបស់ខ្លួន
- ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ដើម្បីចាត់ចែងនិងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំបន្ថែមអំពីរបៀបរបបធ្វើការងារនិងភារកិច្ចរបស់ភូមិ ឱ្យបានសមស្រប ។ល។

**មាត្រា ៣២.–**

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវជ្រើសរើសចេញពីបេក្ខ-ជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេបង្អស់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់មានអាណត្តិស្មើនឹងអាណត្តិរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៣៣.–**

ជំទប់ទី ១ ចៅសង្កាត់រងទី ១ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ២ ។

ជំទប់ទី ២ ចៅសង្កាត់រងទី ២ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ៣ ។

**មាត្រា ៣៤.–**

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែមួយដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈទាំងអស់ក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាពីក្នុងបញ្ជីតែមួយនោះឱ្យទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី២ ឬចៅសង្កាត់រងទី ២ ។

**មាត្រា ៣៥.–**

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែពីរដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាជាបេក្ខជន ដែលមានឈ្មោះលេខរៀងបន្ទាប់ពីបេក្ខជនដែលមានឈ្មោះលេខរៀងលំដាប់លើគេបង្អស់នៃបញ្ជីដែលបានទទួលសម្លេងឆ្នោតគាំទ្រលំដាប់ទីមួយ ឱ្យទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ និងជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះលេខរៀងលើគេបង្អស់ នៃបញ្ជីដែលបានទទួលសម្លេងគាំទ្រលំដាប់ទី ២ ឱ្យទទួលតំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។ ល.ក.

**មាត្រា ៣៦.-**

តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវបាត់បង់ក្នុងករណីសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សាឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។

**មាត្រា ៣៧.-**

មុខតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មុខតំណែងមេឃុំ ចៅសង្កាត់និងមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ កាលបើមុខតំណែងណាមួយត្រូវបាត់បង់ មុខតំណែងទាំងអស់ខាងលើរបស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៅក្នុងបញ្ជីរួមជាមួយអតីតប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ ដែលបានបាត់បង់ពីមុខតំណែងនោះ ឱ្យទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់និងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មី ជំនួសកន្លែងដែលទំនេរតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីដែលបញ្ជីបេក្ខជនត្រូវកាន់កាប់តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់អស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចេញពីក្នុងបញ្ជីបេក្ខជនជាមួយ ផ្អែកតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦ នៃច្បាប់នេះនិងបាត់ឱ្យសមាជិកក្រុមប្រឹក្សារូបនេះទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ជំនួសប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះ ការបាត់បង់ពីមុខតំណែងនិងការទទួលតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៨.-**

តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបាត់បង់ពីមុខតំណែង ក្នុងករណីដែលសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សា ឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។ល។

ក្នុងករណីតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបានបាត់បង់ មុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៃបញ្ជីបេក្ខជនរួមជាមួយជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ឱ្យទទួលតំណែងជំនួសជំទប់ ឬចៅសង្កាត់រងដែលបានបាត់បង់ពីមុខតំណែងនិងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មីជំនួសកន្លែងដែលទំនេរ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីបញ្ជីបេក្ខជនដែលត្រូវកាន់កាប់តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ អស់សមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសបេក្ខជនពីក្នុងបញ្ជីនោះបញ្ចូលជាសមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ និងប្រគល់ឱ្យសមាជិកក្រុមប្រឹក្សារូបនោះទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ជំនួសតំណែងជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះនិងល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ការបាត់បង់មុខតំណែងនិងការទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៩.–**

មេឃុំ ចៅសង្កាត់បំពេញតួនាទីភារកិច្ចដូចខាងក្រោម :

- អនុវត្តសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អនុវត្តនូវបទប្បញ្ញត្តិនិងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពការងារជូនក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនយ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ផ្តល់យោបល់ផ្សេងៗនិងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំផែនការហិរញ្ញវត្ថុនិងក្នុងការចាត់ចែងអនុវត្តនូវតួនាទី មុខងារ សិទ្ធិអំណាចរបស់ក្រុម

ប្រ.

ប្រឹក្សាឃុំ សង្កាត់ ព្រមទាំងកិច្ចការផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនប្រគល់ឱ្យ ។

**មាត្រា ៤០.-**

ជំទប់ ឬចៅសង្កាត់រងជាជំនួយការរបស់មេឃុំ ចៅសង្កាត់ក្នុងការអនុវត្តភារកិច្ចដែលមេឃុំ ចៅសង្កាត់ប្រគល់ឱ្យនិងជំនួសមេឃុំ ចៅសង្កាត់ទៅតាមឋានានុក្រមនៃជំទប់ ចៅសង្កាត់រង នៅពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន ។

ជំទប់ ឬចៅសង្កាត់រង ត្រូវធ្វើការបែងចែកភារកិច្ចដូចខាងក្រោម :

ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈនិងសណ្តាប់ធ្នាប់សាធារណៈ ។

មេឃុំ ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមពីលើភារកិច្ចដែលបានបែងចែកខាងលើនេះដល់ជំទប់ ឬចៅសង្កាត់រងរបស់ខ្លួន ។

## ជំពូកទី ៤

## តួនាទី មុខងារនិងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

**មាត្រា ៤១.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញនិងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចីរភាព សំរាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនិងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ ។

**មាត្រា ៤២.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទគឺ :

- តួនាទីបំពេញកិច្ចការមូលដ្ឋានសំរាប់បំរើផលប្រយោជន៍ឃុំ សង្កាត់និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន ។

- តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។៚

មាត្រា ៤៣.-

ក្នុងតួនាទីបំពេញកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ច :

- ធានាការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ
- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនិងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក
- បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។

មាត្រា ៤៤.-

ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាពនិងផ្តត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកា សំរាប់អនុវត្ត ។

ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ ។

មាត្រា ៤៥.-

រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសំរេចលើវិស័យទាំងឡាយដូចខាងក្រោម :

- ព្រៃឈើ
- ប្រៃសណីយ៍និងទូរគមនាគមន៍
- ការពារប្រទេស ល.។.

មាត្រា ៥២.-

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់ នៅតែទទួលខុសត្រូវលើកិច្ចការដែលបានធ្វើប្រតិភូកម្មនោះ ។

ការដកហូតនូវអំណាចដែលបានធ្វើប្រតិភូកម្ម មិនធ្វើឱ្យប៉ះពាល់ដល់សុពលភាពនៃកិច្ចការដែលបានធ្វើរួចហើយនោះឡើយ ។

## ជំពូកទី ៥
## ការតាមដាន ការត្រួតពិនិត្យនិងការធ្វើអន្តរាគមន៍

មាត្រា ៥៣.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវកំណត់នីតិវិធីផ្សេងៗសំរាប់ធ្វើការតាមដាននិងត្រួតពិនិត្យអំពីសកម្មភាពទូទៅរបស់ឃុំ សង្កាត់ដើម្បី :

- ពិនិត្យមើលអំពីនីត្យានុកូលភាពនៃការគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទី ភារកិច្ច របស់ឃុំ សង្កាត់នីមួយៗ
- ពិនិត្យមើលការវិវត្តន៍អំពីសមត្ថភាពរបស់ឃុំ សង្កាត់នានា
- វាយតំលៃប្រមាណអំពីការធ្វើអន្តរាគមន៍និងការជួយឧបត្ថម្ភគាំទ្រចំពោះឃុំ សង្កាត់ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទីភារកិច្ច ។

ក្នុងការតាមដាន ការត្រួតពិនិត្យនិងការធ្វើការអន្តរាគមន៍ចំពោះឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចវិលែកអំណាចដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខណ្ឌ ឱ្យជួយកិច្ចការនេះទៅតាមសំណូមពរការងារ ។

មាត្រា ៥៤.-

ឃុំ សង្កាត់ណាដែលមិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើអន្តរាគមន៍ដើម្បីឱ្យមានការបំពេញភារកិច្ចដែលច្បាប់បានតម្រូវនោះជាបន្ទាន់ ។ល។

ភារកិច្ចដែលច្បាប់បានតម្រូវ គឺជាភារកិច្ចមួយដែលក្រុមប្រឹក្សាឃុំ សង្កាត់ មានកាតព្វកិច្ចបំពេញតាមល័ក្ខខ័ណ្ឌទាំងឡាយនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានពាក់ព័ន្ធ ឬបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់ ។

**មាត្រា ៥៥.-**

ការតាមដាន ត្រួតពិនិត្យនិងធ្វើអន្តរាគមន៍រួមមានការងារ :

- ស៊ើបអង្កេតនិងវាយតំលៃ
- ធ្វើសេចក្តីណែនាំជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបំពេញភារកិច្ចដែលច្បាប់បានតម្រូវ
- ធ្វើជំនួសក្នុងការបន្តបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ។

**មាត្រា ៥៦.-**

ការធ្វើអន្តរាគមន៍ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៥៤ នៃច្បាប់នេះត្រូវមានលក្ខណៈសមហេតុផលនិងស្របទៅតាមទំហំនៃកិច្ចការដែលក្រុមប្រឹក្សាឃុំ សង្កាត់ មិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ដោយភ្ជាប់ជាមួយនូវការណែនាំនិងការគាំទ្រសំខាន់ចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាចបំពេញភារកិច្ចដែលច្បាប់បានតម្រូវជាធម្មតា ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានសិទ្ធិចុះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយបុគ្គល ឬអង្គការណាមួយ ឬធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌឱ្យបំពេញការងារចាំបាច់ដើម្បីធ្វើអន្តរាគមន៍ក្នុងនាមខ្លួនចំពោះកិច្ចការណាមួយ ។

**មាត្រា ៥៧.-**

កាលបើការធ្វើអន្តរាគមន៍មិនទទួលបានលទ្ធផលចំពោះភារកិច្ចដែលច្បាប់បានតម្រូវណាមួយ ឬមួយចំនួនក្នុងអំឡុងពេល ៦ខែ ហើយភារកិច្ចដែលច្បាប់បានតម្រូវជាទូទៅក្រុមប្រឹក្សាឃុំ សង្កាត់ក៏មិនអាចបំពេញបាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ ហើយធ្វើការបោះឆ្នោតឡើងវិញទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ល។

### មាត្រា ៥៨.-

ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ណាធ្វើសកម្មភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ផ្ទុយនឹងនយោបាយរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ នោះជាបន្ទាន់ ហើយត្រូវធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះឡើងវិញ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះនិងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

### មាត្រា ៥៩.-

ត្រូវបង្កើតឱ្យមានអង្គភាពមួយចំណុះក្រសួងមហាផ្ទៃដើម្បីធ្វើជាសេនាធិការអំពីការងាររដ្ឋបាលមូលដ្ឋាន ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពនេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៦
## ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

### មាត្រា ៦០.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ អនុម័តនិងអនុវត្តនូវផែនការអភិវឌ្ឍន៍ឃុំសង្កាត់ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធីនិងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

### មាត្រា ៦១.-

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរបស់ជាតិ ។

### មាត្រា ៦២.-

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឆ្នាំទី ១ នៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវពិនិត្យឡើងវិញដើម្បីផ្តល់ទិន្នន័យថ្មីៗជារៀងរាល់ឆ្នាំ ដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។ ៚.។.

- វិធានការធ្វើឱ្យបានល្អប្រសើរចំពោះវិស័យនានាដែលមានការខ្វះចន្លោះក្នុងការអនុវត្តកន្លងមក

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តសេចក្តីរាយការណ៍នេះក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីបំណាច់ឆ្នាំសារពើពន្ធនីមួយៗ ។

**មាត្រា ៧០.-**

សេចក្តីរាយការណ៍ប្រចាំឆ្នាំដូចមានចែងក្នុងមាត្រា ៦៩នៃច្បាប់នេះ ក្រោយពីបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ :

- ចម្លងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តម្កល់ទុកជាសាធារណៈ
- ចម្លងចែកជូនអង្គការ សមាគមនិងសាធារណជនសំខាន់ៗដោយគិតត្រឹមថ្លៃដើម ។

**មាត្រា ៧១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិនិត្យពិចារណាទៅលើមតិយោបល់ផ្សេងៗដែលបានផ្តល់ចំពោះសេចក្តីរាយការណ៍ដូចមានចែងក្នុងមាត្រា ៦៩ និងមាត្រា ៧០នៃច្បាប់នេះ ហើយត្រូវទទួលយកនូវមតិយោបល់ល្អៗ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**មាត្រា ៧២.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវពិគ្រោះពិភាក្សាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីចេញសេចក្តីណែនាំអនុវត្តជាក់ស្តែងនូវបទប្បញ្ញត្តិនានា ដែលបានចែងក្នុងជំពូកទី ៦ នៃច្បាប់នេះ ។

## ជំពូកទី ៧
## ហិរញ្ញវត្ថុឃុំ សង្កាត់

**មាត្រា ៧៣.-**

ឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុ ថវិកានិងទ្រព្យសម្បត្តិផ្ទាល់ ។ ៤ៗ.

- បទដ្ឋានហិរញ្ញវត្ថុនិងការអនុវត្តជាក់ស្តែងផ្នែកគណនេយ្យ
- ការចាត់ចែង គ្រប់គ្រងទ្រព្យសម្បត្តិ
- តំរូវការផ្សេងៗ ក្នុងការធ្វើសវនកម្ម
- ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព ប្រសិទ្ធិភាពនិងការទទួលខុសត្រូវ ។

ប្រព័ន្ធនៃការគ្រប់គ្រង ការតាមដាននិងការត្រួតពិនិត្យហិរញ្ញវត្ថុឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨៣.-**

របបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានពិភាក្សាឯកភាពលើគោលការណ៍ជាមួយក្រសួងមហាផ្ទៃ ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ៨៤.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទទួលវិន័យដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

វិន័យរួមមាន :

- ស្តីបន្ទោសក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានកំណត់ហេតុច្បាស់លាស់
- ករណីនៅតែបន្តប្រព្រឹត្តកំហុស ត្រូវកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភ ។

វិន័យដែលតម្រូវឱ្យកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភដូចចែងខាងលើអាចអនុវត្តបាន លុះត្រាតែមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសេចក្តីស្នើសុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រាក់ឧបត្ថម្ភដែលកាត់នេះត្រូវបានមកជាប្រយោជន៍នៃថវិកាឃុំ សង្កាត់ ។ល។

ក្នុងករណីបានអនុវត្តបភាពវិន័យទាំងពីរខាងលើរួចហើយ តែសាមីខ្លួននៅតែមិនរាងចាល ក្រុមប្រឹក្សាឃុំ សង្កាត់អាចបញ្ឈប់ជននោះពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដោយការបោះឆ្នោតអនុម័តតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ហើយត្រូវធ្វើការជ្រើសរើសសមាជិកថ្មីមកជំនួសតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ទទួលវិន័យ ត្រូវជ្រើសយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឬមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីអនុវត្តបភាពវិន័យខាងលើនេះ ។

មន្ត្រីដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំខាងលើនេះពុំមានសិទ្ធិអនុម័តឡើយ ។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**មាត្រា ៨៥.-**

ដើម្បីមានមូលដ្ឋានសំរាប់រៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់និងគ្រប់គ្រងឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសអំពីចំនួន ឈ្មោះនិងព្រំប្រទល់របស់ឃុំ សង្កាត់ ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ ។

**មាត្រា ៨៦.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ១ នេះ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវរៀបចំឡើងវិញនូវមេភូមិនានាចំណុះឃុំ សង្កាត់របស់ខ្លួនទៅតាមបែបបទនីតិវិធីដូចមានចែងក្នុងមាត្រា ៣០នៃច្បាប់នេះ ។

**មាត្រា ៨៧.-**

ដើម្បីបង្កលក្ខណៈសម្បត្តិដល់ការគ្រប់គ្រងឃុំ សង្កាត់តាមប្រព័ន្ធវិមជ្ឈការត្រូវបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយឈ្មោះថា "គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់" ដែលមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន ។ល។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតបន្ទាប់ពីច្បាប់នេះបានចូលជាធរមាន ហើយត្រូវបញ្ចប់អាណត្តិរបស់ខ្លួនឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចចែកចេញជាអនុគណៈកម្មការតាមការចាំបាច់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ត្រូវយកអង្គភាពដែលបានបង្កើតឡើងស្របតាមមាត្រា ៥៩នៃច្បាប់នេះធ្វើជាលេខាធិការដ្ឋាន ។

**មាត្រា ៨៨.–**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់មានសមត្ថកិច្ចធ្វើសេចក្តីស្នើយោបល់ទៅក្រសួងមហាផ្ទៃនិងរាជរដ្ឋាភិបាលអំពីបញ្ហានានាដូចខាងក្រោម :

- សិក្សាស្រាវជ្រាវកំណត់ឡើងវិញនូវព្រំប្រទល់ឃុំ សង្កាត់ទាំងអស់ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- បែងចែកមុខងារ សិទ្ធិអំណាចនិងភារកិច្ចផ្សេងៗ រវាងរាជរដ្ឋាភិបាលនិងឃុំ សង្កាត់ព្រមទាំងរៀបចំឱ្យមានកិច្ចសហការសំរបសំរួលរវាងឃុំ សង្កាត់ ពីរឬច្រើន ។
- បណ្តុះបណ្តាល បង្កើនសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់
- រៀបចំប្រាក់ចំណូលនិងសារពើពន្ធសំរាប់ឃុំ សង្កាត់
- គាំទ្រផ្នែកបច្ចេកទេសដល់ឃុំ សង្កាត់
- វិះរកមធ្យោបាយសំរាប់ផ្តល់ព័ត៌មាននិងគំរង់ទិសរដ្ឋបាលសាធារណៈអំពីកិច្ចដំណើរការនៃប្រព័ន្ធគ្រប់គ្រងឃុំ សង្កាត់តាមបែបប្រជាធិបតេយ្យនិងវិមជ្ឈការ
- ផ្តល់យោបល់ដល់រាជរដ្ឋាភិបាលអំពីការអនុវត្តនយោបាយវិមជ្ឈការក្រោមអំណាចនៃច្បាប់នេះនិងផ្តល់យោបល់លើការកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំព្រាងលិខិតបទដ្ឋានសំរាប់អនុវត្តច្បាប់នេះ
- រួមយោបល់ទៅលើអនុក្រឹត្យដែលមានការពាក់ព័ន្ធដល់ការងារនៅថ្នាក់ឃុំ សង្កាត់ ល.។.

- កំណត់របបគ្រប់គ្រងរដ្ឋបាលអន្តរកាលចំពោះឃុំ សង្កាត់ដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអនុវត្តនយោបាយវិមជ្ឈការ ។

**មាត្រា ៨៩.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយផ្អែកតាមសេចក្តីស្នើយោបល់របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចស្នើបង្កើតឃុំ សង្កាត់ លុបចោលឃុំ សង្កាត់ កែប្រែព្រំប្រទល់ឃុំ សង្កាត់ ផ្លាស់ប្តូរឈ្មោះឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៦ និងមាត្រា ១៧នៃច្បាប់នេះ សំរាប់ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ២ ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ៩០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។/.

រាជធានីភ្នំពេញថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១

ក្នុងព្រះបរមនាមនិងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

**ហត្ថលេខា**

**ជា ស៊ីម**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**ហត្ថលេខា**

ស ខេង   យូ ហុកគ្រី

លេខ : ៧០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ២១ ខែ ០៧ ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវឌី សាវី**

# ឧបសម្ព័ន្ធទី២

នស/រកម/១២១៥/ ០១៥

# ព្រះរាជក្រម

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

រដ្ឋសភា
ចូល លេខ ...
ថ្ងៃទី ... ឆ្នាំ២០១... ម៉ោង ...
បញ្ជូនទៅ ...

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ១៥៨/០០៦/២០១៥ កបធ.ច ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ក្រសួងព្រះបរមរាជវាំង

# ច្បាប់
## ស្តីពី
# ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះមានគោលដៅកំណត់បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ច្បាប់នេះត្រូវអនុវត្តចំពោះឃុំ សង្កាត់ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.–**

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយ ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួន តាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ស្របទៅតាមនីតិវិធីដូចមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៣.–**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវធ្វើឡើងរៀងរាល់ ០៥ (ប្រាំ) ឆ្នាំ ម្តង ។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវរៀបចំធ្វើឡើងនៅថ្ងៃជាមួយគ្នា ។

កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

នាយករដ្ឋមន្ត្រីត្រូវប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ០៤ (ប្រាំបួន) ខែ យ៉ាងតិច មុនថ្ងៃបោះឆ្នោត ។

ការបោះឆ្នោតត្រូវធ្វើនៅថ្ងៃអាទិត្យ តែមួយថ្ងៃ ។

**មាត្រា ៤.–**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកាន់កាប់មុខតំណែងរបស់ខ្លួនរហូតទាល់តែមានក្រុមប្រឹក្សាថ្មីដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងចូលកាន់តំណែងជំនួស ។

**មាត្រា ៥.–**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ដោយអ្នកបោះឆ្នោតដែល ៖

–បានចុះឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ

–មានសិទ្ធិបោះឆ្នោតបានតែមួយសន្លឹកប៉ុណ្ណោះ តាមរយៈការបោះឆ្នោតជាសម្ងាត់ ។

អ្នកបោះឆ្នោតម្នាក់ៗមានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ តែមួយប៉ុណ្ណោះ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ៦.-**

ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗដូចបានចែងក្នុងមាត្រា ១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យក្នុងរយៈពេលយ៉ាងតិច ០៤ (ប្រាំបួន) ខែមុនថ្ងៃបោះឆ្នោត ។

## ជំពូកទី ២
## ការគ្រប់គ្រងការបោះឆ្នោត
## ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ៧ .-**

ការចាត់ចែង រៀបចំ និងគ្រប់គ្រងបញ្ជីបោះឆ្នោត និងការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៨.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវដាក់ចេញនូវបទបញ្ជា និងនីតិវិធីសម្រាប់ចាត់ចែងរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ផ្អែកតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៩.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានអំណាច មុខងារ និងភារកិច្ចដូចខាងក្រោម ៖

-រៀបចំ និងផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត

-ពិនិត្យរៀបចំបញ្ជីបោះឆ្នោតជារៀងរាល់ឆ្នាំ

-ការពារសុវត្ថិភាព និងរក្សាបញ្ជីបោះឆ្នោត

-សម្រេចលើការចុះបញ្ជីបេក្ខជន

-ពិនិត្យតាមដានយុទ្ធនាការឃោសនាបោះឆ្នោត

-គ្រប់គ្រងនីតិវិធីបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត

-គ្រប់គ្រងនីតិវិធីរាប់សន្លឹកឆ្នោត និងចាត់ចែងការរាប់សន្លឹកឆ្នោត

-ប្រកាសលទ្ធផលនៃការបោះឆ្នោត

-ការពារសុវត្ថិភាពក្នុងដំណើរការបោះឆ្នោត ដំណើរការរាប់សន្លឹកឆ្នោត និងការពារសុវត្ថិភាពសម្ភារ ឧបករណ៍ គ្រឿងសង្ហារិម សម្រាប់ដំណើរការបោះឆ្នោតទាំងមូល

ROYAUME DU CAMBODGE · LE MINISTERE DU PALAIS ROYAL

-បណ្តុះបណ្តាលមន្ត្រីបោះឆ្នោត និងណែនាំដល់បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ អំពីនីតិវិធីផ្សេងៗសម្រាប់ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ

-ធានាឲ្យសាធារណជនទូទៅ មានការយល់ដឹងអំពីគោលបំណងនៃការបោះឆ្នោត

-ធានាឲ្យជនគ្រប់រូបមានសិទ្ធិចូលរួម ប្រកបដោយសុវត្ថិភាព និងគ្មានការភ័យខ្លាច ឬការបំភិតបំភ័យក្នុងដំណើរការបោះឆ្នោត

-រៀបចំនីតិវិធីនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ប្រកបដោយតម្លាភាព និងដោយមានការចូលរួមពីអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយ

-ធានាឲ្យមានទំនាក់ទំនងទៀងទាត់ រវាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាមួយបេក្ខជន ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍

-អនុវត្តតាមការកំណត់ និងនីតិវិធីផ្សេងៗដែលទាក់ទងដល់ការត្រួតពិនិត្យ ការគ្រប់គ្រង ហិរញ្ញវត្ថុដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សម្រេចលើបណ្តឹងតវ៉ាទាក់ទងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ លើកលែងតែបណ្តឹងតវ៉ាទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ

-ធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា និងព្រឹទ្ធសភា ស្តីពីការគ្រប់គ្រង ការប្រព្រឹត្តទៅ និងលទ្ធផលនៃការបោះឆ្នោត ក្នុងអំឡុងពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត

-អនុវត្តការងារដទៃទៀតតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

## មាត្រា ១០.-

អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលទទួលខុសត្រូវចំពោះការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងការងារដទៃទៀត ត្រូវផ្តល់កិច្ចសហការដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីរក្សាសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងសម័យបោះឆ្នោត និងក្រោយសម័យបោះឆ្នោត ។

## មាត្រា ១១.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសិទ្ធិតែងតាំងគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ឬគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ឬគណៈកម្មការការិយាល័យបោះឆ្នោតក្នុងរយៈពេលមានកំណត់ នៅពេលណាមួយបន្ទាប់ពីការបោះឆ្នោត ក្នុងគោលបំណងគ្រប់គ្រង និងចាត់ចែងការបោះឆ្នោតឡើងវិញ ឬបោះឆ្នោតសាជាថ្មី ។

ROYAUME DU CAMBODGE
MINISTÈRE DU PALAIS ROYAL

# ជំពូកទី ៣
# ការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោត

## មាត្រា ១២.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធានាឲ្យមានបញ្ជីបោះឆ្នោត សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ដែលបានបង្កើតឡើងតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ២២ និងមាត្រា ២៣ នៃច្បាប់នេះ ។

ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប្រជាពលរដ្ឋត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

-មានសញ្ជាតិខ្មែរ

-មានអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត

-មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត

-មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬមិនត្រូវបានដកសិទ្ធិបោះឆ្នោត

-ពុំមែនជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅដោយមានលិខិតបញ្ជាក់ ពីក្រសួងស្ថាប័នមានសមត្ថកិច្ច ។

បែបបទ និងនីតិវិធីនៃការចុះឈ្មោះបោះឆ្នោត និងការរៀបចំបញ្ជីបោះឆ្នោត ដូចមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបានយកមកអនុវត្តដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ លើកលែងតែមាត្រា ៤៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

## មាត្រា ១៣.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ផ្លូវការ ៩០ (កៅសិប) ថ្ងៃយ៉ាងតិច មុនថ្ងៃបោះឆ្នោត។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៤
# ប្រព័ន្ធបោះឆ្នោត និងការបែងចែកអាសនៈ

## មាត្រា ១៤.-

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រដោយបែងចែកអាសនៈតាមមធ្យមភាគខ្ពស់បំផុត ដូចមានចែងក្នុងមាត្រា ១៦ និងមាត្រា ២០ នៃច្បាប់នេះ ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសចេញពីក្នុងបញ្ជីបេក្ខជនរបស់គណបក្សនយោបាយដែលត្រូវបានជាប់ឆ្នោតនៅក្នុងឃុំ សង្កាត់នោះ ។

## មាត្រា ១៥.-

ចំនួនអាសនៈនៃក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវស្មើគ្នានឹងចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវបានកំណត់ដោយអនុក្រឹត្យ អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ។

## មាត្រា ១៦.-

អាសនៈនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបែងចែកដោយផ្អែកលើចំនួនអាសនៈ និងលទ្ធផលនៃការបោះឆ្នោត តាមជំហានទាំងឡាយដូចខាងក្រោម ៖

**ជំហានទីមួយ** : កំណត់ចំនួនកូតាដែលតម្រូវឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈមួយ ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបមកចែកនឹងចំនួនអាសនៈសរុបរបស់ក្រុមប្រឹក្សា តាមរូបមន្តដូចខាងក្រោម ៖

$$ក_{ត} = \frac{ស_{ស}}{អ_{ស}}$$

ក្នុងនោះ ៖

–$ក_{ត}$ : តាងឲ្យកូតាជាផលចែកដោយមិនគិតសំណល់ចែក

–$ស_{ស}$ : តាងឲ្យចំនួនសន្លឹកឆ្នោតបានការសរុប ដែលបានបោះឲ្យបញ្ជីបេក្ខជន នៃគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

–$អ_{ស}$: តាងឲ្យចំនួនអាសនៈសរុបនៅក្នុងក្រុមប្រឹក្សា ។

**ជំហានទីពីរ** : កំណត់ចំនួនអាសនៈជាបឋម ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួលដោយយកចំនួនសន្លឹកឆ្នោតបានការដែលបញ្ជីបេក្ខជន នៃគណបក្សនយោបាយនីមួយៗបានទទួលមកចែកនឹងកូតា តាមរូបមន្តដូចខាងក្រោម ៖

$$អ_{ទ} = \frac{ស_{ប}}{ក_{ត}}$$

ក្នុងនោះ ៖

–$អ_{ទ}$ : ជាផលចែកដោយមិនគិតសំណល់ចែក តាងឲ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗមានសិទ្ធិទទួលបាន មុនពេលធ្វើប្រមាណវិធីចាំបាច់ណាមួយនៅក្នុងជំហានទីបី

–$ស_{ប}$ : តាងឲ្យចំនួនសន្លឹកឆ្នោតបានការ ដែលបានបោះឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ

–$ក_{ត}$ : តាងឲ្យកូតាដែលបានកំណត់នៅក្នុងជំហានទីមួយ ។

បន្ទាប់ពីគណនាគ្រប់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ក្នុងជំហានទីពីរហើយ ប្រសិនគ្មានអាសនៈនៅសល់ដើម្បីបែងចែកបន្តទៀតនោះ ចំនួនអាសនៈសម្រេចត្រូវកំណត់យកតែម្តង ។

ក្នុងករណីមានអាសនៈនៅសល់ត្រូវបន្តបែងចែក បន្ទាប់ពីធ្វើការគណនាសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ អាសនៈដែលនៅសល់ទាំងនេះត្រូវផ្តល់ឲ្យទៅតាមរបៀបដែលបានកំណត់ក្នុងជំហានទីបី ។

**ជំហានទីបី** : អាសនៈដែលនៅសល់ត្រូវបែងចែកដោយកំណត់យកមធ្យមភាគខ្ពស់បំផុត តាមរូបមន្តដូចខាងក្រោម ៖

$$ម_{ធ} = \frac{ស_{ប}}{អ_{ទ}+១}$$

ក្នុងនោះ ៖

–$ម_{ធ}$ : តាងឲ្យមធ្យមភាគខ្ពស់បំផុត

–$ស_{ប}$ : តាងឲ្យចំនួនសន្លឹកឆ្នោតបានការដែលបានបោះឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ

–$អ_{ទ}$ : តាងឲ្យចំនួនអាសនៈ ដែលបែងចែកឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ។

ក្នុងករណីនៅសល់អាសនៈចំនួនមួយដែលត្រូវបែងចែក បន្ទាប់ពីបានគណនាតាមរូបមន្តក្នុងជំហានទីបី សម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានលក្ខណសម្បត្តិទាំងអស់អាសនៈនោះត្រូវបែងចែកទៅឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ក្នុងករណីនៅសល់អាសនៈច្រើនជាងមួយដែលត្រូវបែងចែក ត្រូវអនុវត្តតាមរូបមន្តនៅក្នុងជំហានទីបី ហើយអាសនៈចំនួនមួយត្រូវបែងចែកទៅឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់បំផុត ។ បន្ទាប់មកត្រូវអនុវត្តតាមរូបមន្តនេះម្តងទៀតដោយបង្កើនតម្លៃ អ៖ ចំនួន ១ ចំពោះបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានទទួលអាសនៈចំនួនមួយក្នុងការអនុវត្តរូបមន្តលើកទីមួយ។ ដូច្នេះអាសនៈចំនួនមួយត្រូវផ្តល់ទៅឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុតក្នុងការអនុវត្តរូបមន្តលើកទីពីរ ។ ក្នុងករណីនៅសល់អាសនៈ ត្រូវបែងចែកបន្តទៀតនោះ ការគណនាត្រូវធ្វើតាមរបៀបដដែលដោយបែងចែកម្តងមួយអាសនៈ ជាបន្តបន្ទាប់រហូតដល់អស់អាសនៈដែលនៅសល់ ។

## មាត្រា ១៧.–

អ្នកជាប់ឆ្នោតទាំងអស់ ត្រូវបានស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោតតាមចំនួនស្មើគ្នានឹងចំនួនអាសនៈនៃបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោត តាមការគណនាក្នុងមាត្រា ១៦ នៃច្បាប់នេះ ។

ឈ្មោះអ្នកជាប់ឆ្នោតត្រូវស្រង់តាមលំដាប់លេខរៀងពីលើមកក្រោម តាមបញ្ជីបេក្ខជន នៃគណបក្សនយោបាយជាប់ឆ្នោតនីមួយៗ ។

## មាត្រា ១៨.–

ឃុំ សង្កាត់ណាដែលមានបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយគត់ដែលត្រូវបានយល់ព្រមឲ្យចុះបញ្ជី ឃុំ សង្កាត់នោះក៏ត្រូវធ្វើការបោះឆ្នោតដែរ ។

ឈ្មោះបេក្ខជន ត្រូវស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយនោះ តាមលំដាប់លេខរៀងពីលើមកក្រោមរហូតដល់គ្រប់អាសនៈនៅក្នុងក្រុមប្រឹក្សា ។

## មាត្រា ១៩.–

ឈ្មោះបេក្ខជនណា ដែលបានស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោតក្នុងឃុំ សង្កាត់ និងត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រួចហើយ បេក្ខជននោះត្រូវលុបឈ្មោះចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយ ។

## មាត្រា ២០.–

ក្នុងករណីគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈ ដែលខ្លួនទទួលបានគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបែងចែកអាសនៈ ដែលបោះបង់ចោលនោះទៅឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយផ្សេងទៀតដែលមានអាសនៈនៅក្នុងក្រុមប្រឹក្សា ក្នុងអំឡុងពេលយ៉ាងយូរ ១៤ (ដប់បួន) ថ្ងៃ ដោយធ្វើប្រមាណវិធីតាមជំហានទាំងឡាយដូចខាងក្រោម ៖

**ជំហានទីមួយ** : កំណត់ចំនួនកូតាដែលតម្រូវឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានមួយអាសនៈ ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឲ្យបញ្ជីបេក្ខជន នៃគណបក្សនយោបាយទាំងអស់ ដែលបានទទួលអាសនៈក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដកចេញចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជន នៃគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ មកចែកជាមួយនឹងចំនួនអាសនៈដែលបោះបង់ចោល តាមរូបមន្តដូចខាងក្រោម ៖

$$\text{ក}'_{\text{ត}} = \frac{\text{ស}'_{\text{ស}}}{\text{អ}'_{\text{ប}}}$$

ក្នុងនោះ ៖

–$\text{ក}'_{\text{ត}}$ : តាងឲ្យកូតាជាផលចែកដោយមិនគិតពីសំណល់ចែក

–$\text{ស}'_{\text{ស}}$ : តាងឲ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានទទួលអាសនៈក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដកចេញនូវចំនួនសន្លឹកឆ្នោតបានការសរុបបោះឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលបានបោះបង់ចោលអាសនៈមួយ ឬច្រើន

–$\text{អ}'_{\text{ប}}$ : តាងឲ្យចំនួនអាសនៈ ដែលបានបោះបង់ចោល ។

**ជំហានទីពីរ** : កំណត់ចំនួនអាសនៈជាបឋមដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួល ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជន នៃគណបក្សនយោបាយនីមួយៗបានទទួល មកចែកនឹងកូតាដែលបានគិតក្នុងជំហានទីមួយ តាមរូបមន្តដូចខាងក្រោម ៖

$$\text{អ}'_{\text{១}} = \frac{\text{ស}_{\text{ប}}}{\text{ក}'_{\text{ត}}}$$

ក្នុងនោះ ៖

–$\text{អ}'_{\text{១}}$ : តាងឲ្យចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយបានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ណាមួយក្នុងជំហានទីបី

–$\text{ស}_{\text{ប}}$ : តាងឲ្យចំនួនសន្លឹកឆ្នោតបានការសរុប បោះឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ

–$\text{ក}'_{\text{ត}}$ : តាងឲ្យកូតាដែលបានកំណត់ក្នុងជំហានទីមួយ ។

បន្ទាប់ពីបានធ្វើការគណនាក្នុងជំហានទីពីរ សម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលមានអាសនៈក្នុងក្រុមប្រឹក្សា លើកលែងតែបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលបោះបង់ចោលអាសនៈ ក្នុងករណីគ្មានអាសនៈនៅសល់ដើម្បីបែងចែកបន្តទៀត ចំនួនអាសនៈសម្រេច

## ជំពូកទី ១៥
## អន្តរប្បញ្ញត្តិ

**មាត្រា ១៩៤.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំបញ្ជីបោះឆ្នោតថ្មី សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ៤ ស្របតាមបទប្បញ្ញត្តិនៃមាត្រា ១៦៧ មាត្រា ១៦៨ និងមាត្រា ១៦៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

## ជំពូកទី ១៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៩៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយច្បាប់នេះ ។

**មាត្រា ១៩៦.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១៥

នស/រកម.០៥១៥.០១២

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ:១១៣៤ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ឧបសម្ព័ន្ធទី៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី ចូលនិតិយុំ សង្កាត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលបានប្រកាសអោយប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែមិនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី៣១ ខែធ្នូឆ្នាំ២០០១ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០២
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៥ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- យោងតាមស្មារតីអង្គប្រជុំលើកទី៨របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់ បែបបទ នីតិវិធី នៃការគ្រប់គ្រងមូលនិធិឃុំ សង្កាត់ដែលបានបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។ មូលនិធិឃុំ សង្កាត់ហៅកាត់ថា " មូលនិធិ " ។

**មាត្រា ២.-**

មូលនិធិមានគោលបំណង ដូចខាងក្រោម:

- ធ្វើអោយឃុំ សង្កាត់ អាចរ៉ាប់រងការទទួលខុសត្រូវជាទូទៅ លើការងាររដ្ឋបាលមូលដ្ឋាន និងជំរុញកិច្ចអភិវឌ្ឍន៍នៅមូលដ្ឋានស្របទៅនឹងមាត្រា៤២ មាត្រា៤៣ និង មាត្រា៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- កាត់បន្ថយភាពខុសគ្នាអំពី សក្តានុពលក្នុងការប្រមូលចំណូលផ្ទាល់រវាងឃុំ សង្កាត់នានា ដោយសារស្ថានភាពអាចនឹងផ្សេងគ្នា លើល័ក្ខខ័ណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ច សង្គម និង ប្រជាសាស្ត្រ
- ជួយលើកទឹកចិត្តដល់ការកសាងសមត្ថភាពសំរាប់ការងារអភិបាលកិច្ចល្អរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៣.-**

គណនីមូលនិធិឃុំ សង្កាត់ត្រូវបើកនៅរតនាគារជាតិ ។

គណនីមូលនិធិឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំង:

ក-ផ្នែកចំណូល:

- ការចូលរួមមួយចំណែក ពីចំណូលចរន្តនៃថវិការដ្ឋ
- ការចូលរួមពីជំនួយឥតសំណង និងការខ្ចីដែលបានមកពីម្ចាស់ជំនួយ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា
- ការចូលរួមពីប្រភពផ្សេងៗទៀត ។

ខ-ផ្នែកចំណាយ:

- ការផ្ទេរប្រចាំឆ្នាំ ទៅក្នុងថវិកាឃុំ សង្កាត់

ចំណូលនៃមូលនិធិទាំងឡាយណាដែលមិនបានផ្ទេរក្នុងឆ្នាំ ត្រូវយោងទៅឆ្នាំបន្ទាប់ ។

## ជំពូកទី ២

## ការគ្រប់គ្រងមូលនិធិឃុំ សង្កាត់

**មាត្រា ៤.-**

ក្រុមប្រឹក្សាភិបាលមួយត្រូវបានបង្កើតឡើង ដោយអោយឈ្មោះថា ក្រុមប្រឹក្សាភិបាលមូលនិធិឃុំ សង្កាត់ ហៅកាត់ថា " ក្រុមប្រឹក្សាភិបាលមូលនិធិ " ។

ក្រុមប្រឹក្សាភិបាលមូលនិធិនេះ មានភារៈទទួលខុសត្រូវដូចខាងក្រោម :

- ផ្តល់យោបល់ ជូនរាជរដ្ឋាភិបាលអំពីចំណែកនៃចំណូលចរន្ត ដែលត្រូវចូលរួមក្នុងមូលនិធិ
- តាមដានលំហូរធនធានទៅក្នុងមូលនិធិដែលបានមកពីជំនួយឥតសំណង និងការខ្ចី ព្រមទាំងលើកគោលដៅជូនរាជរដ្ឋាភិបាលក្នុងការគៀងគរធនធានពីក្រៅប្រទេស
- អនុម័តលើរូបមន្តបែងចែកធនធាននៃមូលនិធិ ព្រមទាំងស្នើឡើងនូវអនុសាសន៍ជូនរាជរដ្ឋាភិបាលអំពីការផ្លាស់ប្តូររូបមន្តដែលមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ
- អនុម័ត និងធ្វើការកែសំរួលប្រចាំឆ្នាំនូវចំណាត់ថ្នាក់នៃឃុំ សង្កាត់ ដើម្បីវិភាជន៍ដល់សមាសភាគនៃមូលនិធិដូចមានចែងនៅក្នុងមាត្រា១២ នៃអនុក្រឹត្យនេះ
- អនុម័តផែនការប្រចាំឆ្នាំលើការបែងចែកធនធាននៃមូលនិធិដោយផ្អែកលើចំណាត់ថ្នាក់និងរូបមន្តខាងលើ
- ប្រកាសជូនឃុំ សង្កាត់នូវធនធានត្រូវទទួលបានប្រចាំឆ្នាំ និងធ្វើការព្យាករណ៍ធនធានដែលឃុំ សង្កាត់ ត្រូវទទួលបានសំរាប់រយៈពេលបីឆ្នាំទៅមុខ
- តាមដានការផ្ទេរធនធានមូលនិធិជាក់ស្តែងទៅឃុំ សង្កាត់ ប្រៀបធៀបទៅនឹងផែនការបែងចែកប្រចាំឆ្នាំ
- អនុម័តលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៃមូលនិធិ

ក្រុមប្រឹក្សាភិបាលត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ក្នុងរង្វង់មួយខែ ចាប់ពីថ្ងៃនៃការបង្កើតរបស់ខ្លួន។

**មាត្រា ៥.-**

ក្រុមប្រឹក្សាភិបាលមូលនិធិមានសមាសភាពដូចខាងក្រោម:

- តំណាងក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន
- តំណាងក្រសួង មហាផ្ទៃ មួយរូប ជាសមាជិក
- តំណាងក្រសួង ផែនការ មួយរូប ជាសមាជិក
- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មួយរូប ជាសមាជិក
- តំណាងក្រុមប្រឹក្សាឃុំ សង្កាត់ដែលមកពីតំបន់មានកំរិតអភិវឌ្ឍន៍ខុសៗគ្នា ជ្រើសរើសដោយក្រសួងមហាផ្ទៃ ចំនួនបីរូប ជាសមាជិក

**មាត្រា ៦.-**

ក្រុមប្រឹក្សាភិបាលមូលនិធិមានលេខាធិការដ្ឋានមួយ ដែលត្រូវបង្កើតឡើងក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ លេខាធិការដ្ឋាននេះ មានភារៈទទួលខុសត្រូវដូចខាងក្រោម:

- សម្របសម្រួល និងធ្វើកំណត់ហេតុរាល់កិច្ចប្រជុំ ពិភាក្សារបស់ក្រុមប្រឹក្សាភិបាលមូលនិធិ
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាពប្រចាំត្រីមាសស្តីពីប្រតិបត្តិការនៃមូលនិធិ

- ផ្តល់រាល់ការគាំទ្រផ្នែកបច្ចេកទេសដល់ក្រុមប្រឹក្សាភិបាលមូលនិធិ ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានភារៈទទួលខុសត្រូវដូចខាងក្រោម:

- បញ្ជាការផ្ទេរធនធានទាំងអស់ ពីគណនីមូលនិធិទៅគណនីប្រាក់បញ្ញើរបស់ឃុំ សង្កាត់នីមួយៗ បន្ទាប់ពីបានផ្ទៀងផ្ទាត់ថាឃុំ សង្កាត់ដែលត្រូវទទួលនោះបំពេញបាននូវល័ក្ខខ័ណ្ឌនានាដូចមានចែងនៅក្នុងមាត្រា១៧នៃអនុក្រឹត្យនេះ
- តាមដានការផ្ទេរមូលនិធិ និងការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់លើការប្រើប្រាស់ធនធានមូលនិធិ
- ផ្តល់ដល់ក្រុមប្រឹក្សាភិបាលមូលនិធិនូវពត៌មានលំអិតតាមកាលកំណត់ស្តីពីការផ្ទេរ និងប្រើប្រាស់ធនធាននៃមូលនិធិ ។

ក្នុងការបំពេញភារកិច្ចខាងលើ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើសកម្មភាពស្របតាមគោលការណ៍នានាដែលបានពិភាក្សាព្រមព្រៀងគ្នារបស់ក្រុមប្រឹក្សាភិបាលមូលនិធិ ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ដើម្បី:

- តាមដាន និងបញ្ជាក់លើការបំពេញបានត្រឹមត្រូវនូវល័ក្ខខ័ណ្ឌប្រើប្រាស់មូលនិធិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានបញ្ជាក់ក្នុងមាត្រា១៧ នៃអនុក្រឹត្យនេះ
- តាមដានការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការប្រើប្រាស់ធនធានមូលនិធិ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវរៀបចំបទប្បញ្ញត្តិទាំងឡាយដើម្បីណែនាំដល់ អភិបាលខេត្ត ក្រុង ក្នុងការបំពេញមុខងារខាងលើ ។

## ជំពូកទី ៣
## ការធ្វើហិរញ្ញប្បទាន ការបែងចែក និង ការប្រើប្រាស់មូលនិធិ

**មាត្រា ៩.-**

អនុលោមតាមមាត្រា៧៧ នៃ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ កំរិតនៃការផ្ទេរពីចំណូលចរន្តនៃថវិកាជាតិរដ្ឋទៅក្នុងគណនីមូលនិធិត្រូវគ្រោងឡើងសំរាប់ថេរៈវេលាយ៉ាងតិចចំនួន៣ឆ្នាំថវិកា ។

ឆ្នាំថវិកា២០០២ កំរិតនៃការផ្ទេរពីថវិការដ្ឋបានកំណត់ក្នុងមាត្រា២០ ជំពូក៥ អន្តរប្បញ្ញត្តិនៃ អនុក្រឹត្យនេះ ។

ឆ្នាំថវិកា២០០៣ និង ២០០៤ កំរិតនៃការផ្ទេរពីថវិការដ្ឋទៅក្នុងគណនីមូលនិធិ បានគ្រោងឡើងជាភាគរយដូចខាងក្រោម:

- ឆ្នាំថវិកា២០០៣: មិនតិចជាង២.០% (ពីរភាគរយ) នៃចំណូលចរន្ត
- ឆ្នាំថវិកា២០០៤: មិនតិចជាង២.៥% (ពីរក្បៀសប្រាំភាគរយ) នៃចំណូលចរន្ត ។

រាជរដ្ឋាភិបាលត្រូវពិគតូរដល់ការបង្កើនភាគរយនេះនៅពេលមានសំណើពីក្រុមប្រឹក្សាភិបាលមូលនិធិ ។

**មាត្រា ១០.-**

ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវកំណត់គោលដៅប្រចាំឆ្នាំ ដើម្បីគៀងគរការចូលរួមពីក្រៅប្រទេសទៅក្នុងមូលនិធិ ។ គណនីប្រាក់បញ្ញើមួយជារូបិយប័ណ្ណរបស់មូលនិធិឃុំ សង្កាត់ ត្រូវបានបើកនៅធនាគារជាតិនៃកម្ពុជា ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីទទួលធនធានពីជំនួយឥតសំណង និងការខ្ចីដែលម្ចាស់ជំនួយ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានាចូលរួម ។

ចំណូលរបស់មូលនិធិឃុំ សង្កាត់ក្នុងគណនីនៅធនាគារជាតិនៃកម្ពុជា ត្រូវផ្ទេរជាប្រាក់រៀលទៅគណនីរបស់មូលនិធិនៅរតនាគារជាតិនៅពេលណាដែលត្រូវការ ។

**មាត្រា ១១.-**

ចំណែកនៃធនធានមូលនិធិសរុបដែលអាចផ្ទេរទៅឃុំ សង្កាត់នីមួយៗ ត្រូវកំណត់ដោយរូបមន្តមួយ ។ រូបមន្តនេះត្រូវស្របទៅនឹងគោលបំណងនៃមូលនិធិ ដូចមានចែងនៅក្នុងមាត្រា២ នៃអនុក្រឹត្យនេះ ។

ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវអនុម័តរូបមន្តនិងប្រកាសពីចំនួនធនធានដែលឃុំ សង្កាត់នីមួយៗនឹងទទួលបានសំរាប់ឆ្នាំបន្ទាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី០១ ខែតុលា នៃឆ្នាំថវិកា ។

**មាត្រា ១២.-**

ធនធានសរុបនៃមូលនិធិត្រូវបានបែងចែកជាពីរសមាសភាគដូចខាងក្រោម :

- សមាសភាគរដ្ឋបាលទូទៅ មិនត្រូវច្រើនជាង ១ ភាគ ៣ នៃធនធានមូលនិធិសរុប
- សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន មិនត្រូវតិចជាង ២ ភាគ ៣ នៃធនធានមូលនិធិសរុប ។

ក្រុមប្រឹក្សាភិបាលមូលនិធិ ត្រូវកំណត់វិធីក្នុងការបែងចែកធនធានមូលនិធិសរុបដល់សមាសភាគទាំងពីរតាមកំរិតកំណត់ខាងលើ ។

**មាត្រា ១៣.-**

ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវរៀបចំចំណាត់ថ្នាក់ឃុំ សង្កាត់ ជា ២ ប្រភេទ:

ប្រភេទទី១: រួមមានឃុំ សង្កាត់ដែលក្រុមប្រឹក្សាភិបាលមូលនិធិយល់ឃើញថាមានសមត្ថភាព និងលទ្ធភាពក្នុងការប្រើប្រាស់ធនធានមូលនិធិដែលបានផ្ទេរសំរាប់ចំណាយអភិវឌ្ឍន៍ល្អប្រសើរ និងមានប្រសិទ្ធភាព ។

ប្រភេទទី២: រួមមាន ឃុំ សង្កាត់ដែលគ្មាននៅក្នុងប្រភេទទី១ ។

ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវរៀបចំ និងអនុម័តនូវផែនការពហុឆ្នាំដើម្បីបង្កើនជាបណ្តើរៗចំនួនឃុំ សង្កាត់ទៅក្នុងប្រភេទទី១ ។

ផ្អែកលើផែនការខាងលើ និងអោយបានមុនថ្ងៃទី០១ខែតុលារៀងរាល់ឆ្នាំ ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវពិនិត្យចំនួនឃុំ សង្កាត់ដែលមានលក្ខណសម្បត្តិសមស្របគួរបញ្ចូលក្នុងប្រភេទទី១ ។

## មាត្រា ១៤._

ធនធានទាំងឡាយ នៃសមាសភាគទាំងពីររបស់មូលនិធិត្រូវបានបែងចែក និង ប្រើប្រាស់តាមការកំណត់ខាងក្រោម:

ក) ធនធាននៃសមាសភាគរដ្ឋបាលទូទៅ

- អាចប្រើប្រាស់ដោយឃុំ សង្កាត់នៅក្នុងប្រភេទទី១ និងប្រភេទទី២
- ត្រូវបែងចែកតាមសមាមាត្រនៃចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ
- អាចអនុវត្តដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការចំណាយប្រតិបត្តិការ ឬវិនិយោគផ្នែករដ្ឋបាលដែលសមស្របដូចបានកំណត់នៅក្នុងមាត្រា ១៥ នៃអនុក្រឹត្យនេះ ។

ខ) ធនធាន នៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន

- អាចប្រើប្រាស់បានតែក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងប្រភេទទី១
- ត្រូវគណនាចេញជាបីចំណែក: ចំណែកស្មើគ្នាជាមូលដ្ឋាន ចំណែកសមាមាត្រទៅនឹងប្រជាពលរដ្ឋ និងចំណែកសមាមាត្រទៅនឹងសន្ទស្សន៍ភាពក្រីក្រនៃឃុំ សង្កាត់នីមួយៗ
- អនុវត្តដោយក្រុមប្រឹក្សាឃុំ សង្កាត់ចំពោះតែលើចំណាយអភិវឌ្ឍន៍ ដូចបានកំណត់នៅក្នុងមាត្រា១៥ នៃអនុក្រឹត្យនេះ ។

ក្រសួងផែនការត្រូវផ្តល់អោយក្រុមប្រឹក្សាភិបាលមូលនិធិអោយបានមុនថ្ងៃទី០១ ខែកញ្ញា នៃឆ្នាំនីមួយៗនូវការប៉ាន់ស្មានចុងក្រោយអំពី :

- ចំនួនប្រជាពលរដ្ឋសរុប នៃ ឃុំ សង្កាត់ នីមួយៗ
- សន្ទស្សន៍ភាពក្រីក្រនៃឃុំ សង្កាត់នីមួយៗ

## មាត្រា ១៥._

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រើប្រាស់ថវិកាផ្ទេរពីមូលនិធិឃុំ សង្កាត់សំរាប់ចំណាយមួយផ្នែកឬ ទាំងស្រុងលើវិនិយោគ និងប្រតិបត្តិការ ដែលឆ្លុះបញ្ចាំងនៅក្នុងថវិកាដែលបានអនុម័តដោយក្រុមប្រឹក្សាឃុំ សង្កាត់ និងមិនផ្ទុយទៅនឹងច្បាប់ និងលិខិតបទដ្ឋានទាំងឡាយជាធរមាន ។

ការចំណាយរដ្ឋបាល គឺជាចំណាយប្រតិបត្តិការ និងវិនិយោគដោយរដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តន៍ភារកិច្ចរដ្ឋបាលទូទៅរបស់ខ្លួន ។ ចំណាយនេះរួមមាន :

- ប្រាក់បំណាច់ សំរាប់ក្រុមប្រឹក្សា ឃុំ សង្កាត់
- បៀវត្សមន្ត្រី ឃុំ សង្កាត់ និង ចំណាយផ្សេងៗដល់មន្ត្រី បុគ្គលិកទាំងនោះ
- ការទិញ ឬ ការជួលទីតាំងសំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់
- សម្ភារឹម និង ឧបករណ៍ការិយាល័យឬ មធ្យោបាយសំភារៈរដ្ឋបាល សំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់

- ការជួសជុល និង ការថែទាំមធ្យោបាយសំភារៈរដ្ឋបាល
- ថ្លៃប្រើប្រាស់ទឹក និង អគ្គិសនី
- ទិញ ឬ ជួលយានជំនិះ
- ប្រេងឥន្ធនៈ ប្រេងរំអិល និងការ ថែទាំយានជំនិះ
- ចំណាយផ្សេងៗ

ចំណាយអភិវឌ្ឍន៍គឺជាចំណាយប្រតិបត្តិការ និង ចំណាយវិនិយោគដោយរដ្ឋបាលឃុំ សង្កាត់សំរាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន (លើកលែងមធ្យោបាយសំភារៈរដ្ឋបាល) និងការផ្តល់សេវាសេដ្ឋកិច្ចសង្គមនៅឃុំ សង្កាត់ (លើកលែង រដ្ឋបាល) ។ ចំណាយទាំងនោះរួមមាន :

- ការអង្កេត គំនូសប្លង់ ការសាងសង់ ការជួសជុល និង ការថែទាំផ្លូវ ផ្សារ មណ្ឌលសុខភាព សាលារៀន មជ្ឈមណ្ឌល សហគមន៍ សំណង់ប្រព័ន្ធធារាសាស្ត្រ ឃ្លាំងស្តុកកសិផល ប្រព័ន្ធផ្គត់ផ្គង់ទឹក និង ថាមពល និង ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច សង្គម ផ្សេងទៀត ។

- ចំណាយលើមន្ត្រីបុគ្គលិកនិងចំណាយចរន្តដែលពាក់ព័ន្ធនឹងប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងការផ្តល់សេវា

- ចំណាយគាំទ្រកម្មវិធីអភិវឌ្ឍន៍សហគមន៍ ដែលចាត់ចែងដោយអង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋាន និងអង្គការជួយសហគមន៍ រួមបញ្ចូលទាំងយុទ្ធនាការផ្តល់ពត៌មាន និង អប់រំសំរាប់ស្ត្រី និង យុវជននៅមូលដ្ឋាន ការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ និងកម្មវិធីដទៃទៀតដែលមានឥទ្ធិពលដល់សុខុមាលភាពសង្គម និងប្រជាពលរដ្ឋនៅមូលដ្ឋាន ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវចេញសេចក្តីណែនាំលំអិតមួយ ដោយផ្សារភ្ជាប់ទៅនឹងបទបញ្ញត្តិស្តីពីថវិកាឃុំ សង្កាត់ ដើម្បីធ្វើយ៉ាងណាអោយប្រភេទរដ្ឋបាលនិងអភិវឌ្ឍន៍មានភាពស្របទៅនឹងចំណាត់ថ្នាក់ចំណាយនៅក្នុងថវិកា ។

## ជំពូកទី ៤
## នីតិវិធីនៃការផ្ទេរ និង លំហូរចំណូលទទួលបានពីធនធានមូលនិធិ

### មាត្រា ១៦.-

ឃុំ សង្កាត់ទាំងអស់ត្រូវមានគណនីប្រាក់បញ្ញើមួយនៅរតនាគារខេត្ត ក្រុង ឬ នៅធនាគារពាណិជ្ជណាមួយដែលមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

អនុលោមតាមមាត្រា៧នៃអនុក្រឹត្យនេះ និងតាមសំណើរបស់ក្រសួងមហាផ្ទៃ រតនាគារជាតិត្រូវផ្ទេរថវិកាវិភាជន៍ដែលបានអនុម័តប្រចាំឆ្នាំទៅគណនីរបស់ឃុំ សង្កាត់នីមួយៗ នៅរតនាគារខេត្ត ក្រុង ឬ ធនាគារពាណិជ្ជ ។

ថវិកាផ្ទេរប្រចាំឆ្នាំត្រូវធ្វើឡើងជាបីលើកៈ ការផ្ទេរលើកទី១គឺ ៥០%(ហាសិបភាគរយ) នៃចំនួនផ្ទេរសរុប អោយបានមុនថ្ងៃទី ០១ ខែមីនា លើកទី២គឺ ៣០%(សាមសិបភាគរយ) នៃចំនួនផ្ទេរសរុប អោយបានមុនថ្ងៃទី ០១ខែមិថុនា និងលើកទី៣ ចំនួននៅសល់ ២០%(ម្ភៃភាគរយ) ត្រូវផ្ទេរអោយបានមុនថ្ងៃទី ០១ ខែកញ្ញា ។

**មាត្រា ១៧.–**

ដើម្បីទទួលបានការផ្ទេរ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបញ្ជាក់ថាខ្លួនបានៈ

- អនុវត្តតាមវិធីចូលរួមក្នុងដំណើរការ ធ្វើផែនការ ថវិកា និង ការងារប្រតិបត្តិ
- បំពេញរបាយការណ៍ហិរញ្ញវត្ថុ ស្តីពីការអនុវត្តន៍ថវិកា និង ផែនការអភិវឌ្ឍន៍របស់ខ្លួន ។
- ប្រមូលទុនចូលរួមរបស់មូលដ្ឋាន ព្រមទាំងធនធានដទៃទៀតរបស់មូលដ្ឋានដើម្បីបំពេញបន្ថែមលើការផ្ទេរ ពីមូលនិធិ នៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន។

ក្នុងរយៈពេល ២០ ថ្ងៃ ពីថ្ងៃទទួលបានពាក្យសុំផ្ទេរថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អភិបាលខេត្ត ក្រុង ក្នុងនាមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវៈ

- ផ្ទៀងផ្ទាត់លើការអនុវត្តន៍ល័ក្ខខ័ណ្ឌទាំងឡាយដើម្បីទទួលបានធនធានមូលនិធិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្តល់យោបល់ ទៅក្រសួងមហាផ្ទៃ លើការបំពេញបានសព្វគ្រប់នៃការផ្ទេរធនធាន

ក្នុងករណីដែលក្រុមប្រឹក្សាឃុំ សង្កាត់មិនបំពេញបានចំពោះល័ក្ខខ័ណ្ឌ អភិបាលខេត្ត ក្រុងត្រូវជួយផ្តល់យោបល់ និងណែនាំ សកម្មភាព កែតំរូវ និងផ្តល់ជំនួយបច្ចេកទេសចាំបាច់ ។ បន្ទាប់មកអភិបាលខេត្ត ក្រុង ត្រូវស្នើយោបល់ទៅក្រសួងមហាផ្ទៃ ដើម្បីផ្អាកការផ្ទេរសិនរហូតដល់កង្វះខាតដែលស្នើអោយកែតំរូវខាងលើត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់បំពេញតាមត្រឹមត្រូវ ។

ក្នុងករណីមានបាតុភាពមិនចុះសំរុងគ្នារវាងក្រុមប្រឹក្សាឃុំ សង្កាត់និងអភិបាលខេត្ត ក្រុងនោះ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ជូនបញ្ហានេះទៅក្រុមប្រឹក្សាភិបាលមូលនិធិដើម្បីពិនិត្យ និងសំរេច ។ ការសំរេចរបស់ក្រុមប្រឹក្សាភិបាលមូលនិធិចាត់ទុកជា សេចក្តីសំរេចចុងក្រោយបង្អស់ ។

## ជំពូកទី ៥

## អន្តរប្បញ្ញត្តិ

**មាត្រា ១៨.–**

ក្នុងពេលដែលក្រុមប្រឹក្សាភិបាលមូលនិធិមិនទាន់បង្កើតឡើង គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវធានាអនុវត្តមាត្រា ៤ នៃអនុក្រឹត្យនេះ ដោយមានអនុគណៈកម្មការកិច្ចការហិរញ្ញវត្ថុជាជំនួយការ ។

**មាត្រា១៩.-**

ក្នុងអាណត្តិរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវធ្វើអនុសាសន៍ និងរាយការណ៍ជាទៀងទាត់ជូន គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ស្តីពីប្រតិបត្តិការរបស់មូលនិធិ ។ បទប្បញ្ញត្តិ ព្រមទាំងសេចក្តីណែនាំ ឬបទបញ្ជាទាំងឡាយដែលទាក់ទងទៅនឹងប្រតិបត្តិការ របស់មូលនិធិត្រូវដាក់ជូន គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ពិនិត្យសំរេច ។

ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវរៀបចំ និងដាក់ជូន គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ អនុម័តផែនការពហុឆ្នាំ ក្នុងរយៈពេល៦ខែបន្ទាប់ពីត្រូវបានបង្កើតឡើង ដើម្បីបង្កើនជាបណ្តើរៗនូវចំនួនឃុំទៅក្នុងប្រភេទទី១ ។

**មាត្រា ២០.-**

សំរាប់ឆ្នាំថវិកា២០០២ ការផ្ទេរពីថវិការដ្ឋទៅក្នុងមូលនិធិឃុំ សង្កាត់ មានចំនួន ២០.០០០.០០០.០០០៛ (ម្ភៃពាន់លានរៀល) ។

**មាត្រា ២១.-**

ឃុំ សង្កាត់ដែលត្រូវបញ្ចូលទៅក្នុងប្រភេទទី១ ក្នុងឆ្នាំថវិកា ២០០២ គឺឃុំ សង្កាត់ទាំងឡាយណាដែលមានផែនការអភិវឌ្ឍន៍របស់ខ្លួន មានសមត្ថភាព លទ្ធភាព ក្នុងការប្រើប្រាស់មូលនិធិសំរាប់អភិវឌ្ឍន៍បានល្អប្រសើរ និងមានប្រភពហិរញ្ញប្បទានជាក់លាក់ ។

**មាត្រា ២២.-**

ឆ្នាំថវិកា២០០២ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានទទួលការផ្ទេរមូលនិធិលើកទី១ និងលើកទី២ ដោយមិនបាច់បំពេញល័ក្ខខ័ណ្ឌ ។ ក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំ និងទំរង់របាយការណ៍សំរាប់អនុវត្តការផ្ទេរលើកទី៣ អោយបានមុនថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០២ ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា២៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា២៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ អភិបាលខេត្ត ក្រុង ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ស ខេង យូ ហុកគ្រី

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*កន្លែងទទួល*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ឯកសារ-កាលប្បវត្តិ*

# ឧបសម្ព័ន្ធទី៤

ឆ្នាំទី ២ លេខ ១២ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០២ រាជកិច្ច ទំព័រ ៧០៦

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរសិទ្ធិអំណាច តួនាទី និង ភារកិច្ច នៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃ ទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃ ទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ។
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៥ ចុះថ្ងៃ ទី ១៨ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។
- យោងតាមស្មារតីនៃអង្គប្រជុំរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ កាលពីថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០២ ។
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## សំរេច

# ជំពូកទី១
# ការប្រគល់អំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់
# និងអភិបាលកិច្ចរបស់ឃុំ សង្កាត់

មាត្រា ១.-

ឃុំ សង្កាត់ជានីតិបុគ្គល ។

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាឃុំ សង្កាត់មួយ ។

ឃុំ សង្កាត់មានមុខងារ អំណាច និងករណីយកិច្ចក្នុងការគ្រប់គ្រង និង ធ្វើអភិបាលកិច្ចក្នុងឃុំ សង្កាត់របស់ខ្លួនស្របនឹងរដ្ឋធម្មនុញ្ញ ច្បាប់ អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋាននានាជាធរមាន។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានជ្រើសតាំងឡើង ដោយការបោះឆ្នោតស្របតាមល័ក្ខខ័ណ្ឌនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋទាំងអស់នៅក្នុង ឃុំ សង្កាត់របស់ខ្លួន។

មាត្រា ២.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្តល់លិខិតជាលាយល័ក្ខអក្សរដល់ក្រសួងមហាផ្ទៃ និង ចម្លងជូនអភិបាលខេត្ត ក្រុងនីមួយៗនូវ ៖

- បញ្ជីឈ្មោះបេក្ខជនរបស់គណបក្សនយោបាយដែលបានជាប់ឆ្នោតជាផ្លូវការតាមឃុំ សង្កាត់នីមួយៗ
- ឈ្មោះរបស់បេក្ខជនដែលត្រូវបានប្រកាសថាជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- ឈ្មោះរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ទី១ ចៅសង្កាត់រងទី១ និង ជំទប់ទី២ ចៅសង្កាត់រងទី២ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានជ្រើសចេញពីបញ្ជីឈ្មោះបេក្ខជនដែលបានជាប់ឆ្នោតជាផ្លូវការ
- ឈ្មោះសមាជិកថ្មីដើម្បីជំនួសសមាជិកនៃក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានបោះបង់ចោលការងារ ឬ បានបញ្ឈប់ពីតំណែងក្នុងករណីដែលមានសមាជិកណាម្នាក់នៃក្រុមប្រឹក្សាឃុំ សង្កាត់បានបោះបង់ចោលការងារ ឬ បានបញ្ឈប់ពីតំណែង ។

មាត្រា ៣.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវរៀបចំឱ្យមានកិច្ចប្រជុំដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ១៤ថ្ងៃ យ៉ាងយូរបន្ទាប់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ។

បែបបទ នីតិវិធី និង កិច្ចដំណើរការនៃការប្រជុំលើកដំបូងនេះត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមការអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៤.-**

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានងារជាផ្លូវការថា " ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ " ។

មេឃុំមានងារជាផ្លូវការថា "មេឃុំ" និង ចៅសង្កាត់មានងារជាផ្លូវការថា "ចៅសង្កាត់ " ។

ជំទប់មានងារជាផ្លូវការថា "ជំទប់" និង ចៅសង្កាត់រង មានងារជាផ្លូវការថា "ចៅសង្កាត់រង " ។

សមាជិកដែលបានជាប់ឆ្នោត ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មានងារជាផ្លូវការថា " សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ " ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រងមានងារជាផ្លូវការតែក្នុងអំឡុងពេលដែលសាមីខ្លួនកាន់តំណែងនោះប៉ុណ្ណោះ ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានងារជាផ្លូវការតែក្នុងអំឡុងពេលដែលសាមីខ្លួននៅជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ប៉ុណ្ណោះ ។

**មាត្រា ៥.-**

ឃុំ សង្កាត់នីមួយៗត្រូវមានស្មៀនឃុំ សង្កាត់មួយរូប ។

ស្មៀនឃុំ សង្កាត់ត្រូវបានតែងតាំង និងត្រូវបានប្រើប្រាស់ក្នុងរចនាសម្ព័ន្ធរដ្ឋបាលរបស់ក្រសួងមហាផ្ទៃ ។

ស្មៀនឃុំ សង្កាត់ត្រូវជួយ និង ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយអនុលោមទៅតាមតួនាទី និងមុខងារដែលបានកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមការអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៦.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងសំរាប់ដំណើរការ និង ចាត់ចែងកិច្ចប្រជុំព្រមទាំងអនុវត្តភារកិច្ចរបស់ខ្លួន ។

បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំផ្អែកលើមូលដ្ឋាននៃសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមការអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៧.-**

សាលាឃុំ សង្កាត់ គឺជាការិយាល័យរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងជាទីចាត់ការរដ្ឋបាលរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

សាលាឃុំ សង្កាត់ត្រូវបើកធ្វើការឱ្យបានទៀងទាត់តាមពេលម៉ោងធ្វើការប្រចាំថ្ងៃស្របតាមម៉ោងធ្វើការរបស់ក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ។

ក្នុងកំឡុងពេលម៉ោងធ្វើការប្រជាពលរដ្ឋមានសិទ្ធិ ÷

- ធ្វើទំនាក់ទំនង និង ធ្វើកិច្ចការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ទទួលពត៌មានអំពីសំណើ និង ការងារនានាពីក្រុមប្រឹក្សាឃុំ សង្កាត់

- មើល និង អានឯកសាររបស់ឃុំ សង្កាត់
- ចូលរួមយោបល់ ឬ តវ៉ាលើបញ្ហាណាមួយ ។

**មាត្រា ៨.-**

ឃុំ សង្កាត់គឺជាម្ចាស់លើលិខិត និង ឯកសារទាំងអស់ដែលបានប្រគល់ត្រឹមត្រូវដល់ ÷

- ការិយាល័យរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- គណៈកម្មាធិការណាមួយរបស់មេឃុំ ចៅសង្កាត់ ឬក្រុមប្រឹក្សាឃុំ សង្កាត់
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬមន្ត្រីនៅការិយាល័យក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៩.-**

ឃុំ សង្កាត់គឺជាម្ចាស់លើរាល់លិខិត និង ឯកសារដែលរៀបចំឡើងដោយក្រុមប្រឹក្សា ឃុំ សង្កាត់ ឬក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ និង ជាម្ចាស់កម្មសិទ្ធិលើតែមប្រិ៍ ត្រាឃុំ សង្កាត់ ព្រមទាំងឧបករណ៍ផ្សេងៗ ទៀតទាំងអស់របស់ឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាទុកដាក់ឯកសារ លិខិតស្នាម តែមប្រិ៍ ត្រា អោយបានត្រឹមត្រូវ និង គង់វង្ស ។

**មាត្រា ១០.-**

ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវរៀបចំឱ្យមានក្ដារខៀនពត៌មានសាធារណៈនៅសាលាឃុំ សង្កាត់របស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសកន្លែងដែលសមស្របដើម្បីដាក់ក្ដារខៀនពត៌មានសាធារណៈនៅតាមភូមិ ។

ទីកន្លែងដែលដាក់ក្ដារខៀនពត៌មានសាធារណៈត្រូវមានការយល់ព្រមពីម្ចាស់កម្មសិទ្ធិ ប្រសិនបើកន្លែងនោះមានអ្នកកាន់កាប់រួចហើយ ។

ក្ដារខៀនពត៌មានសាធារណៈត្រូវសរសេរ ឬ បិទប្រកាសជូនដំណឹងជាផ្លូវការ និង ពត៌មានដទៃទៀតរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ការសរសេរ ឬ ការបិទប្រកាសពត៌មានជាសាធារណៈ ត្រូវរក្សាទុកអោយបានរយៈ យ៉ាងតិច១០ថ្ងៃ ។

**មាត្រា ១១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ជាតំណាង និង ជាអ្នកបំរើអោយផលប្រយោជន៍ទូទៅរបស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

ក្រុមប្រឹក្សាត្រូវលើកស្ទួយ និង សំរបសំរួលក្នុងការអភិវឌ្ឍន៍ឃុំ សង្កាត់ ដោយត្រូវរកប្រភពជំនួយឥតសំណង និង គៀងគរសមត្ថភាព និង ធនធានពី ÷

- ក្នុងឃុំ សង្កាត់របស់ខ្លួនផ្ទាល់
- រាជរដ្ឋាភិបាល និង ក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល

មាត្រា ៦៦.-

ឃុំ សង្កាត់ត្រូវចាត់ចែងនិងប្រើប្រាស់ធនធានដែលមាន ដើម្បីជ្រើសរើសនិងអនុវត្តសកម្មភាពរបស់ខ្លួន។

មាត្រា ៦៧.-

មុខងារ និង តួនាទីចំបងរបស់ឃុំ សង្កាត់គឺត្រូវសម្របសម្រួល និង ជំរុញឱ្យមានការអភិវឌ្ឍន៍ក្នុងឃុំ សង្កាត់របស់ខ្លួន ដោយត្រូវជ្រើសរើសវិធីសាស្ត្រសមស្រប និង មានប្រសិទ្ធិភាព ដើម្បីអនុវត្ត និង ផ្តល់សេវាកម្មអោយស្របតាមជំរើសដែលបានសំណូមពរដោយស្ថាប័នខាងលើ ។

មាត្រា ៦៨.-

ប្រសិនបើមុខងារ ឬ សេវាដែលឃុំ សង្កាត់ទទួលបានសិទ្ធិអំណាចដើម្បីអនុវត្ត កំពុងត្រូវបានផ្តល់អោយដោយភ្នាក់ងារ ឬ អង្គការដទៃទៀត ដោយមិនគិតក្នុងបន្ទុកចំណាយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់គួរទទួលស្គាល់កិច្ចការទាំងនេះ ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រើប្រាស់ធនធានរបស់ខ្លួន ដើម្បីធ្វើការអភិវឌ្ឍន៍នៅកន្លែងដែលមិនទាន់មានអ្នកជួយគាំទ្រ ។

មាត្រា ៦៩.-

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវសិក្សា និង កំណត់ឱ្យបានជាក់លាក់ថែមទៀតអំពីការបែងចែកមុខងាររវាងរដ្ឋបាលថ្នាក់កណ្តាល និង ឃុំ សង្កាត់ ។

ការបែងចែកខាងលើត្រូវមានគោលដៅដើម្បីធានាប្រសិទ្ធិភាពនៃការអនុវត្តន៍។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវធ្វើការបែងចែករវាងសេវាកម្មដែលត្រូវផ្តល់ដោយរដ្ឋបាលថ្នាក់កណ្តាល ភ្នាក់ងារនានារបស់រដ្ឋ អង្គការជាតិ អន្តរជាតិ និង វិស័យឯកជន ជាមួយសេវាកម្មដែលត្រូវផ្តល់ដោយឃុំ សង្កាត់ ។

មាត្រា ៧០.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវទទួលខុសត្រូវក្នុងការរៀបចំ ការអនុម័ត និង ការអនុវត្តន៍ផែនការអភិវឌ្ឍន៍ និង ផែនការថវិកាឃុំ សង្កាត់របស់ខ្លួន ។

ការរៀបចំ ការអនុម័ត និង ការអនុវត្តន៍ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវអនុលោមទៅតាមបទប្បញ្ញតិនានាដែលបានសម្រេចដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

មាត្រា ៧១.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ និង ប្រើប្រាស់ថវិកាដោយអនុលោមទៅតាមបទប្បញ្ញតិពាក់ព័ន្ធនានាដែលបានសម្រេចដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

# ជំពូកទី៧

## អន្តរប្បញ្ញត្តិ

**មាត្រា ៧២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិនិត្យឡើងវិញរាល់សកម្មភាពនៃការចាត់ចែង និង កិច្ចព្រមព្រៀងទាំងឡាយដែលបានរៀបចំឡើងក្នុងនាមឃុំ សង្កាត់ ឬ ដោយឃុំ សង្កាត់ផ្ទាល់ ឬ ភូមិមុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់លើកទីមួយនេះ ។

ការចាត់ចែង ឬ កិច្ចព្រមព្រៀងទាំងនោះរួមមានការផ្ទេរអំណាច ឬ សិទ្ធិពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ឬ ការធ្វើសហប្រតិបត្តិការ ឬ ការជួយគាំទ្រពីកម្មវិធី និង អង្គការនានា ។

ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវធ្វើការពិភាក្សាជាមួយគ្រប់ក្រសួង ស្ថាប័ន គំរោងកម្មវិធី និង អង្គការដែលពាក់ព័ន្ធដើម្បី ÷

- បញ្ជាក់ថាកិច្ចព្រមព្រៀង ឬ ការចាត់ចែងដែលកំពុងអនុវត្ត ពិតជាបានអនុវត្តនៅក្នុងឃុំ សង្កាត់ ឬភូមិ របស់ខ្លួន
- ពិនិត្យឡើងវិញនូវកិច្ចព្រមព្រៀង ឬ ការចាត់ចែងណា ដែលផ្ទុយនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង គោលនយោបាយវិមជ្ឈការ ឬ ផ្ទុយពីគោលការណ៍ណែនាំរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ដើម្បីស្នើសុំធ្វើការកែសម្រួលអោយបានសមស្រប ។

**មាត្រា ៧៣.-**

ក្នុងអាណត្តិរបស់ខ្លួន គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវទទួលខុសត្រូវក្នុងការសម្របសម្រួលជាមួយក្រសួងស្ថាប័ននានា របស់រាជរដ្ឋាភិបាល ដើម្បីកំណត់ និង បែងចែកភារកិច្ចជាក់លាក់រវាងរដ្ឋបាលថ្នាក់កណ្តាល ថ្នាក់ ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ។

**មាត្រា ៧៤.-**

គណកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវពិនិត្យបញ្ជាក់ថា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និង លិខិតបទដ្ឋានណាដែលមានភាពសមស្រប ឬ មិនសមស្របទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង គោលនយោបាយវិមជ្ឈការ ។

ច្បាប់ ព្រះរាជក្រឹ្យ អនុក្រឹត្យ និង លិខិតបទដ្ឋានណាដែលមិនសមស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង គោលនយោបាយវិមជ្ឈការ គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវរៀបចំបែបបទ និង នីតិវិធីធ្វើវិសោធនកម្ម ឬ កែសំរួលអោយបានសមស្រប ។

**មាត្រា ៧៥.-**

គ្រប់ក្រសួង និង ស្ថាប័ននានារបស់រដ្ឋាភិបាលត្រូវ ÷

– បញ្ជាក់ថាច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និង លិខិត បទដ្ឋាន ទាំងអស់ដែលពាក់ពន្ធ័នឹងក្រសួង និង ស្ថាប័នរបស់ខ្លួនកំពុង អនុវត្តនៅតាមឃុំ សង្កាត់ និង ភូមិ ត្រូវតែសមស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង គោលនយោបាយវិមជ្ឈការ ។

– ពិនិត្យឡើងវិញនូវច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និង លិខិតបទដ្ឋានដែលផ្ទុយនឹងគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីដាក់ជូនគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ពិនិត្យ និង ស្នើសុំធ្វើ វិសោធនកម្មជាបន្ទាន់ ។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**មាត្រា ៧៦.–**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧៧.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាបន័ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង យូ ហុកគ្រី